# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងសង្កាត់ ស្រយ៉ូវ
# ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២



រៀបចំដោយ : ក្រុមហ៊ុនផ្តល់សេវាកម្មSBK R&D

សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកកំពង់ស្វាយ

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)

ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC) , ADB_Loan , GAFSP_Grant និងSCF_ADB

# មាតិកា


**អារម្ភកថា** ........ VII
**សេចក្តីផ្តើម** ........ 1
**ជំពូក១៖ ព័ត៌មានស្តីពីស្ថានភាពសង្កាត់ស្រយ៉ូវ** ........ 3
**១.១.ស្ថានភាពសង្កាត់** ........ 3
១.១.១.ទីតាំងរដ្ឋបាលសង្កាត់ ........ 3
១.១.២.ប្រជាសាស្ត្រ ........ 5
ក.ចំនួនប្រជាជន ........ 5
ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន ........ 7
គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ........ 8
ឃ.របររកទទួលទាន ........ 8
ង.ចំណូលស្រុក និងចំណាកស្រុក ........ 10
១.១.៣.ស្ថានភាពសេដ្ឋកិច្ច ........ 11
ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ........ 11
ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ........ 11
គ.ស្ថានភាពបំណុល និងអាត្រាការប្រាក់ ........ 13
ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ ........ 14
ង.ចំណូលពីប្រភពផ្សេងៗ ........ 14
១.១.៤.ស្ថានភាពសិក្សាធិការ ........ 14
ក.ស្ថានភាពអប់រំ ........ 14
ខ.ស្ថានភាពអក្ខរកម្ម ........ 15
គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ........ 16
១.១.៦.ស្ថានភាពយេនឌ័រ ........ 19
**១.២.ស្ថានភាពភូមិសាស្ត្រ** ........ 21
១.២.១.ទីតាំងភូមិសាស្ត្រ ........ 21
១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល) ........ 28
១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ........ 29
១.២.៤.បរិក្ខាសាធារណ: ........ 31
ក.ស្ថានភាពប្រើប្រាស់អគ្គិសនី ........ 31
ខ.ប្រព័ន្ធទឹកស្អាត ........ 31

**១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ........ 32
១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រ ........ 32
ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ ........ 36
ខ.ដីកសិកម្ម ........ 37
ខ.១.ដីស្រែវស្សា ........ 37
ខ.២.ដីស្រែប្រាំង ........ 38
ខ.៣.ដីស្រែប្រាំងនិង ស្រែវស្សា ........ 40
ខ.៤.ដីចម្ការស្រោចស្រព ........ 41
គ.ផ្ទៃទឹក និងខ្សែទឹក ........ 42
គ.១.ស្ទឹងមានទឹកតាមរដូវ ........ 42
គ.២.បឹង ........ 42
គ.៣.អាងស្តុកទឹក ........ 43
គ.៤.ស្រះ ........ 44
១.៣.២.ផលិតកម្មកសិកម្ម ........ 45
ក.ផលិតកម្មដំណាំស្បៀង ........ 45
ខ.ផលិតកម្មដំណាំរួមផ្សំ ........ 46
គ.ផលិតកម្មខ្វស្សាហកម្ម ........ 47
១.៣.៣.ធនធានធម្មជាតិ ........ 47
ក.ធនធានព្រៃឈើ ........ 47
ខ.ធនធានជលផល ........ 47
គ.ធនធានរ៉ែ ........ 48
**១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ........ 48
១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ ........ 48
១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល ........ 49
១.៤.៣.ឧបសគ្គ និងឱកាស ........ 50
**ជំពូក២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត** ........ 51
**២.១.តម្រូវការសម្រាប់អនាគត** ........ 51
២.១.១.ផែនការអភិវឌ្ឍ សង្កាត់ ........ 51
ក.ផែនការអភិវឌ្ឍសង្កាត់៥ឆ្នាំ(២០១៨-២០២២) ........ 51

ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច ........ 54
២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២ ........ 55
២.១.៣.តម្រូវការដីធ្លីជាមូលដ្ឋាន ........ 56
ក.ដីលំនៅឋាន ........ 56
ខ.ដីកសិកម្ម ........ 57
គ.ដីព្រៃឈើ ........ 57
ឃ.ធនធានទឹក ........ 58
ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត ........ 58
ង.១.វិស័យអប់រំ ........ 58
ង.២.វិស័យសុខាភិបាល ........ 60
ង.៣.អគ្គិសនី ........ 60
ង.៤.ទីលានចាក់សំរាម ........ 61
ង.៥.ដីកប់ខ្មោច ........ 61
ង.៦.ស្រះ និងអណ្តូងទឹក ........ 61
**២.២.តំបន់រសើប** ........ 62
**២.៣.ការប្រឈម** ........ 63
២.៣.១.ការប្រឈមដោយធម្មជាតិ ........ 63
ក.កំណើនប្រជាជន ........ 63
ខ.គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ ........ 64
២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព ........ 64
**២.៤.ឱកាស** ........ 64
២.៤.១.ដោយអំណោយផលពីធម្មជាតិ ........ 64
២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ ........ 65
២.៤.៣.ដោយគម្រោងវិនិយោគ ........ 65
**២.៥.បញ្ហា មូលហេតុ និងដំណោះស្រាយ** ........ 66
**ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២** ........ 69
**៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង** ........ 69
៣.១.១.តម្រូវការដីទៅតាមប្រភេទ ........ 69
៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល ........ 69
**៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់** ........ 70

៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ ....70
៣.២.២.ផែនទីប្រើប្រាស់ដីអនាគត....72
៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត ....74
**៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី** ....80
**៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព** ....80
៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព ....80
ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម....80
ខ.ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត ....82
៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព ....82
**៣.៥.សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)** ....83

## បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃសង្កាត់ ....3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ ....6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ....7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម....8
តារាង 5៖ តារាងមុខរបរ....8
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ ....10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧ ....10
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក....11
តារាង 9៖ តារាងកម្រិតជីវភាពរបស់ប្រជាជន ....12
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងសង្កាត់ឆ្នាំ២០១៧ ....15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ ....16
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ....16
តារាង 13៖ សុខភាពមាតានិងទារក....17
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព(គ.ម) ....18
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រសង្កាត់ស្រយ៉ូវ....19
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ....22
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ ....27
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ....29
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន ....30
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី....31
តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក ....31
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន ....35

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ....46
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ....46
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ....47
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ....48
តារាង 27៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ ....49
តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ....50
តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជំរើសនៃការប្រាស់ដីធ្លីអនាគត ....51
តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ) ....55
តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ) ....56
តារាង 32៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលារៀននៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២ ....60
តារាង 33៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) ....66
តារាង 34៖ តារាងប្រើប្រាស់ដីនាពេលអនាគត ....71
តារាង 35៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត ....72
តារាង 36៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត ....72

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧ ....6
ដ្យាក្រាម 2៖ ចម្ងាយមធ្យមពីភូមិទៅមណ្ឌលសុខភាព ....19
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ ....29

## បញ្ជីផែនទី

ផែនទី 1៖ ផែនទីទីតាំងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ....4
ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលសង្កាត់ស្រយ៉ូវ ....5
ផែនទី 3៖ ផែនទីរយៈសង្កាត់ស្រយ៉ូវ ....21
ផែនទី 4៖ ផែនទីពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ ....22
ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រ សង្កាត់ស្រយ៉ូវ ....28
ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ សង្កាត់ស្រយ៉ូវ ....30
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញ សង្កាត់ស្រយ៉ូវ ....32
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិត សង្កាត់ស្រយ៉ូវ ....34
ផែនទី 9៖ ផែនទីគម្រោងអាទិភាពសង្កាត់ស្រយ៉ូវ ....54
ផែនទី 10៖ តំបន់រសើបសង្កាត់ស្រយ៉ូវ ....63
ផែនទី 11៖ បញ្ហា មូលហេតុ និងដំណោះស្រាយ ....68
ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគត ....73

## បញ្ជីរូបភាព


រូបភាព 1៖ សាលារៀន ..... 14
រូបភាព 2៖ មណ្ឌលសុខភាពក្នុងសង្កាត់ស្រយ៉ូវ ..... 18
រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ ..... 27
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍ ..... 30
រូបភាព 5៖ លំនៅឋានភូមិ ..... 37
រូបភាព 6៖ ដីស្រែវស្សា ..... 38
រូបភាព 7៖ ដីស្រែប្រាំង ..... 40
រូបភាព 8៖ ស្រែប្រាំង និងស្រែវស្សា ..... 41
រូបភាព 9៖ ដីចម្ការស្រោចស្រព ..... 41
រូបភាព 10៖ ស្ទឹងសែន ..... 42
រូបភាព 11៖ បឹង ..... 43
រូបភាព 12៖ អាងស្តុកទឹក ..... 43
រូបភាព 13៖ ស្រះ ..... 44

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺជាឧបករណ៍មួយដ៏សំខាន់ នៅក្នុងការជួយទៅដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបទៅដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រង និងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះ ក្រោយពេលមានផែនការប្រើប្រាស់ដីនេះ អាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ នៅក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ/សង្កាត់នេះ ទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ក្រុង និងធ្វើការអនុម័តនៅថ្នាក់រាជធានី/ខេត្តទៅតាមនីតិវិធី ដូចដែលធ្លាប់អនុវត្តនៅក្នុងការកសាង ផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមធ្វើការសម្រេច។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេស ស្តីពីផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ មានចក្ខុវិស័យរហូតដល់ឆ្នាំ ២០៣២ ដែលក្រុមការងាបានខិតខំប្រឹងប្រែងធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍអាស៊ី (ADB) និងកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុន ផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោង និងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកកំពង់ស្វាយ ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដី នៅក្នុងសង្កាត់ស្រយ៉ូវនេះ។ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវនេះ នឹងបានចូលរួមចំណែកទៅដល់ការអភិវឌ្ឍសង្កាត់ប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួម និងមានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់៕

ថ្ងៃ៦រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅសង្កាត់ស្រយ៉ូវ, ថ្ងៃទី០៦ ខែ១១ ឆ្នាំ ២០២០

**ប្រធានក្រុមប្រឹក្សាសង្កាត់ និងជា**

**ចៅសង្កាត់ស្រយ៉ូវ**

**សោម ធី**

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ដោយឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាល បានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្រ្តរៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្រ្តនីមួយៗ។

សង្កាត់ស្រយ៉ូវ ជាសង្កាត់មួយនៅក្នុងចំណោមសង្កាត់ទាំង ៨ ដែលស្ថិតក្នុងដែនរដ្ឋបាល ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ក្នុងនោះមានតំបន់លំនៅឋានមួយផ្នែក និងមួយផ្នែកទៀតជាតំបន់កសិកម្ម ដែលមានផ្ទៃដីសរុបចំនួន ២៨ ២៥៦,១៥ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹងសង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន និងឃុំព្រៃគុយ ស្រុកកំពង់ស្វាយ ខាងត្បូងជាប់នឹងឃុំច្រលួក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ខាងកើតជាប់នឹងឃុំកកោះ ស្រុកសន្ទុក និងខាងលិចជាប់នឹងឃុំកំពង់គោ ស្រុកកំពង់ស្វាយ និងសង្កាត់អូរកន្ធរ ក្រុងស្ទឹងសែន ហើយមានប្រជាជនសរុប ២០ ២២៣ នាក់ ក្នុងនោះស្រ្តី ១០ ៩៣៧ នាក់ និងមានប្រជាពលរដ្ឋចំនួន ៧៣,៩ ភាគរយជាកសិករ។ សង្កាត់ស្រយ៉ូវ មានទំហំផ្ទៃដីស្រែសរុប ២៤០៤០,២៥ហិកតា គឺជាផ្ទៃដី ដែលមានទំហំធំទូលាយដែលមានវិសាលភាពស្រូបអស់ ៨៥% នៃផ្ទៃដីសរុបរបស់សង្កាត់ និងជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍សង្កាត់ស្រយ៉ូវ ប្រកបដោយចីរភាព។

ក្នុងគោលដៅធានាការគ្រប់គ្រង និងអភិវឌ្ឍសង្កាត់ស្រយ៉ូវ ប្រកបទៅដោយចីរភាព គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងក្រុងស្ទឹងសែន ព្រមទាំងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ នៅក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ ដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេស ដោយអង្គភាពអនុវត្តគម្រោងនៅថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងនៅថ្នាក់ជាតិ (NIO) នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងមានការគាំទ្រ និងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍអាស៊ី បានរៀបចំផែនការប្រើប្រាស់ដីក្នុងសង្កាត់ស្រយ៉ូវ ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍសង្កាត់ពាក់ព័ន្ធការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ ឆ្លើយតបទៅនឹងកំណើនប្រជាសាស្រ្ត ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិប្រកបទៅដោយចីរភាព និងសមធម៌ ដែលក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍសង្កាត់ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសការប្រើប្រាស់ដីកសិកម្ម នៅក្នុងសង្កាត់ស្រយ៉ូវ ឱ្យអស់សក្តានុពលដែលមាន ក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលនៅសល់បន្ទាប់ពីការហូបចុក តាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវនេះ ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍសង្កាត់តាមអណត្តិនីមួយៗរបស់ខ្លួន។

ផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ ត្រូវបានធ្វើការរៀបចំឡើង ដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ទៅលើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលនៅឃុំ/សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើអនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ព្រមទាំងប្រកាសរួមស្តីពីនីតិវិធីលម្អិតសម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ដែលមានដំណើរការរៀបចំផែនការ ដូចមាន សង្ខេបនៅក្នុងដ្យាក្រាមខាងក្រោម។

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក១៖ ព័ត៌មានស្តីពីស្ថានភាពសង្កាត់ស្រយ៉ូវ

## ១.១.ស្ថានភាពសង្កាត់

សង្កាត់ស្រយ៉ូវមានរឿងដំណាលតៗគ្នាមកថា កាលដើមឡើយនៅលើទីតាំងនេះ មានបឹងមួយសម្បូរទៅដោយធនធានត្រី ដែលប្រជាពលរដ្ឋនៅតំបន់នោះតែងនាំគ្នាមកនេសាទ ជាពិសេសស្ទូចត្រី ហើយតែងជួបប្រទះត្រីឆ្កោរស៊ីនុយនាំឱ្យផ្លែសន្ទូចរលារបូតត្រីទាំងនោះ។ ដោយយល់ឃើញមានបញ្ហាចំពោះការស្ទូចត្រីរបស់ពួកគាត់ដែលជាហេតុនាំឱ្យរាល់ពេលមកស្ទូចត្រីនៅទីនេះពួកគាត់តែងដាក់ស្រយ៉ូវពត់ផ្លែសន្ទូចតាមខ្លួនដើម្បីពត់ផ្លែសន្ទូចឡើងវិញនៅពេលដែលជួបប្រទះការខូចខាតផ្លែសន្ទូចរបស់ពួកគាត់ធ្វើឱ្យដំណើរការស្ទូចត្រីអាចបន្តទៅទៀតបាន ដែលក្រោយមកមានមនុស្សមកតាំងលំនៅឋាននៅលើទីតាំងនេះផ្តុំគ្នាបន្តិចម្តងៗរហូតកើតបានជាភូមិមួយ ហើយត្រូវបានប្រជាពលរដ្ឋនាំគ្នាដាក់ឈ្មោះថា “ ភូមិស្រយ៉ូវ” តរៀងមករហូតដល់ពេលបច្ចុប្បន្ននេះ ក៏បានក្លាយទៅជា “ សង្កាត់ស្រយ៉ូវ“ តាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ៤៩៣ប្រ.ក/៣០-មេសា-២០០១។

### ១.១.១.ទីតាំងរដ្ឋបាលសង្កាត់

សង្កាត់ស្រយ៉ូវ មានទីតាំងស្ថិតនៅក្នុងក្រុងស្ទឹងសែន តាមបណ្តោយផ្លូវជាតិលេខ៦ ដែលមានចម្ងាយប្រហែល ៧គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ធំ។ សង្កាត់ស្រយ៉ូវមាន ១៣ភូមិ គឺភូមិរលួស ភូមិប្រម៉ាត់ដី ភូមិកំពង់សំរោង ភូមិពោធិ៍សែនស្នាយ ភូមិពោធិ៍តាអ៊ុន ភូមិត្រពាំងវែង ភូមិស្រយ៉ូវជើង ភូមិស្រយ៉ូវត្បូង ភូមិពុកយុក ភូមិម្នាវ ភូមិចំបក់ ភូមិកំរែង និងភូមិរកា ហើយមានផ្ទៃដីសរុបចំនួន ២៨ ២៦២,៨៨ ហិកតា និងមានព្រំប្រទល់រដ្ឋបាលៈ

- ខាងជើង ជាប់នឹង សង្កាត់អូរកន្ធរ សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ឃុំព្រៃគុយ ស្រុកកំពង់ស្វាយ និងឃុំត្បូងក្រពើ ស្រុកសន្ទុក
- ខាងត្បូង ទល់នឹង ឃុំកកោះ ស្រុកសន្ទុក និងឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- ខាងកើត ទល់នឹង ឃុំកកោះ ស្រុកសន្ទុក
- ខាងលិច ទល់នឹង ឃុំកំពង់គោ ស្រុកកំពង់ស្វាយ និងសង្កាត់អូរកន្ធរ ក្រុងស្ទឹងសែន

តារាង 1៖ ស្ថានភាពទូទៅនៃសង្កាត់

| **ខេត្ត** | **កំពង់ធំ** | **លេខកូដខេត្តៈ៦** |
|---|---|---|
| ក្រុង | ស្ទឹងសែន | លេខកូដស្រុកៈ ៦០៣ |
| សង្កាត់ | ស្រយ៉ូវ | លេខកូដឃុំៈ ៦០៣១០ |
| ចំនួនភូមិ១៣ | ១.ភូមិរលួស | លេខកូដភូមិៈ ៦០៣១០០១ |
| | ២.ភូមិប្រម៉ាត់ដី | លេខកូដភូមិៈ ៦០៣១០០២ |
| | ៣.ភូមិកំពង់សំរោង | លេខកូដភូមិៈ ៦០៣១០០៣ |
| | ៤.ភូមិពោធិ៍សែនស្នាយ | លេខកូដភូមិៈ ៦០៣១០០៤ |
| | ៥.ភូមិពោធិ៍តាអ៊ុន | លេខកូដភូមិៈ ៦០៣១០០៥ |
| | ៦.ភូមិត្រពាំងវែង | លេខកូដភូមិៈ ៦០៣១០០៦ |
| | ៧.ភូមិស្រយ៉ូវជើង | លេខកូដភូមិៈ ៦០៣១០០៧ |
| | ៨.ភូមិស្រយ៉ូវត្បូង | លេខកូដភូមិៈ ៦០៣១០០៨ |
| | ៩.ភូមិពុកយុក | លេខកូដភូមិៈ ៦០៣១០០៩ |

| | | |
|---|---|---|
| | ១០.ភូមិម្នាវ | លេខកូដភូមិៈ ៦០៣១០១០ |
| | ១១.ភូមិចំបក់ | លេខកូដភូមិៈ ៦០៣១០១១ |
| | ១២.ភូមិកំរ៉ែង | លេខកូដភូមិៈ ៦០៣១០១២ |
| | ១៣.ភូមិរកា | លេខកូដភូមិៈ ៦០៣១០១៣ |

*ប្រភពៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

ផែនទី 1៖ ផែនទីទីតាំងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន



ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលសង្កាត់ស្រយ៉ូវ




## ១.១.២.ប្រជាសាស្ត្រ

### ក.ចំនួនប្រជាជន

សង្កាត់ស្រយ៉ូវ ត្រូវបានចែកចេញជា ១៣ ភូមិ ដែលមានគ្រួសារសរុបចំនួន ៤ ៥១០ គ្រួសារ និងមានប្រជាជនសរុប ២០ ២២៣ នាក់ ក្នុងនោះស្ត្រី ១០ ៩៣៧ នាក់ ហើយប្រជាជនមានអាយុចាប់ពី១៨ឆ្នាំឡើងទៅចំនួន ១៤ ៣៧៨ នាក់ ក្នុងនោះស្ត្រី ៧ ២៨៣ នាក់។ នៅក្នុងសង្កាត់ស្រយ៉ូវ ភូមិដែលមានប្រជាជនច្រើនជាងគេគឺភូមិពុកយុក មានប្រជាជនចំនួន ៥១៧ គ្រួសារ ស្មើនឹង ១១,៥ ភាគរយ ប្រជាជនសរុបចំនួន ២ ៧៩៥ នាក់ ក្នុងនោះស្ត្រី ១ ៥៤៤ នាក់ និងប្រជាពលរដ្ឋមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ២ ២៤០ នាក់ ស្ត្រីចំនួន ១ ១៤៩ នាក់ ចំណែកភូមិដែលមានប្រជាជនតិចជាងគេ គឺភូមិប្រម៉ាត់ដី ដែលមានប្រជាជនចំនួន ១៧៧ គ្រួសារ ស្មើនឹង ៣,៩ ភាគរយ ប្រជាជនសរុប ៨០០ នាក់ ក្នុងនោះស្ត្រី ៥១១ នាក់។ ប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ៥៣២ នាក់ និងមានស្ត្រីចំនួន ៣៥២ នាក់ ។ ទន្ទឹមនេះ ក៏សង្កេតឃើញប្រជាជននៅក្នុងសង្កាត់ ស្ត្រីមានចំនួនច្រើនជាងបុរស ដូចមានក្នុងតារាងដែលក្រុមការងាបានរៀបចំសង្ខេបខាងក្រោម។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្ដាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | មនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| រលួស | ៣៣០ | ៧,៣ | ១៤៦៣ | ៧២៤ | ៧៣៩ | ៩៤៦ | ៤៧៣ | ៤៧៣ |
| ប្រម៉ាត់ដី | ១៧៧ | ៣,៩ | ៨០០ | ២៨៩ | ៥១១ | ៥៣២ | ១៨០ | ៣៥២ |
| កំពង់សំរោង | ២៧៧ | ៦,១ | ១២៨០ | ៦៣១ | ៦៤៩ | ៨៩១ | ៤៤៣ | ៤៤៨ |
| ពោធិសែនស្នាយ | ៣៥៣ | ៧,៨ | ១៥៩៧ | ៧៦៤ | ៨៣៣ | ១១១១ | ៥៣៤ | ៥៧៧ |
| ពោធិ៍តាអ៊ុន | ៣០៦ | ៦,៨ | ១៤២០ | ៦៨០ | ៧៤០ | ១១៣៩ | ៥៥៨ | ៥៨១ |
| ត្រពាំងវែង | ៣៤៥ | ៧,៦ | ១៥៥៩ | ៧៩៥ | ៧៦៤ | ១១៦៧ | ៥៩៧ | ៥៧០ |
| ស្រយ៉ូវជើង | ៤៩៦ | ១១ | ២១៩៧ | ១០១៩ | ១១៧៨ | ១២៦៣ | ៦៥៧ | ៦០៦ |
| ស្រយ៉ូវត្បូង | ៣២៤ | ៧,២ | ១៦៤៨ | ៨២១ | ៨២៧ | ១០៤៩ | ៥៤៧ | ៥០២ |
| ពុកយុក | ៥១៧ | ១១,៥ | ២៧៩៥ | ១២៥១ | ១៥៤៤ | ២២៤០ | ១០៩១ | ១១៤៩ |
| ម្នាវ | ៣៣៨ | ៧,៥ | ១៤៥៦ | ៧០២ | ៧៥៤ | ១០១៩ | ៤៨២ | ៥៣៧ |
| ចំបក់ | ២៥០ | ៥,៥ | ១២៣៤ | ៦១៣ | ៦២១ | ៧៥៦ | ៣៧៧ | ៣៧៩ |
| កំរែង | ២៣០ | ៥,១ | ៩២៤ | ៤៤៩ | ៤៧៥ | ៦០០ | ២៨១ | ៣១៩ |
| រកា | ៥៦៧ | ១២,៦ | ២៦៥០ | ១៣៤៨ | ១៣០២ | ១៦៦៥ | ៨៧៥ | ៧៩០ |
| **សរុប** | **៤៥១០** | **១០០** | **២០២២៣** | **១០០៦៩** | **១០៩៣៧** | **១៤៣៧៨** | **៧០៩៥** | **៧២៨៣** |

*ប្រភពៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ ២០១៧




*ប្រភពៈ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

បើយោងទៅតាមតារាងស្ថិតិប្រជាជនតាមក្រុមអាយុនៅឆ្នាំ២០១៧ នៅក្នុងសង្កាត់ស្រយ៉ូវ បានបង្ហាញឱ្យឃើញថាប្រជាជនពេញកម្លាំងពលកម្ម ដែលមានអាយុចាប់ពី ២៥ ឆ្នាំ ដល់ ៦០ ឆ្នាំ មានចំនួន ៨ ១៥៧ នាក់ ស្មើប្រហាក់ប្រហែល ៣៩ ភាគរយ នៃប្រជាជនសរុប គឺលើស ១/៣ បន្តិច ក្រៅពីនេះមានអាយុចាប់ពីកើតដល់ ២៤ ឆ្នាំ មានចំនួន ៩ ០២៩ នាក់ ស្មើប្រហាក់ប្រហែល ៤៣ ភាគរយ នៃប្រជាជនសរុប និងប្រជាជនមានអាយុចាប់ពី ៦១ ឆ្នាំឡើង ដែលជាអ្នកបានចូលនិវត្តន៍បាត់បង់សមត្ថភាពការងាមានចំនួន ៣ ៨២០នាក់ ស្មើប្រហាក់

ប្រហែល ១៨ ភាគរយ នៃប្រជាជនសរុប ។ ដូច្នេះសន្និដ្ឋានបានថា នៅក្នុងសង្កាត់ស្រយ៉ូវ មនុស្សពេញកម្លាំងពលកម្មមួយនាក់រកចំណូលបានគិតជាមធ្យមត្រូវចិញ្ចឹមមនុស្សជិតពីរនាក់បន្ថែម ។

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| បរិយាយ | ២០១៧ | | | ផ្សេងៗ |
|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | |
| អាយុពី០-២ឆ្នាំ | ៦៣៤ | ៣០៥ | ៣២៩ | កុមារ |
| អាយុពី៣-៤ | ៨៧៦ | ៣៣៩ | ៥៣៧ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៥៦១ | ២៧៩ | ២៨២ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៦១៣ | ២៩៣ | ៣២០ | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ១១៨៤ | ៥៦០ | ៦២៤ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ១២៣៧ | ៥៥៤ | ៦៨៣ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ១៥២៣ | ៦៤៤ | ៨៧៩ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ២៤០១ | ១១៧៣ | ១២២៨ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ២៧៣៤ | ១៤៥៤ | ១២៨០ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ២៩០៨ | ១៤០៥ | ១៥០៣ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦០ឆ្នាំ | ២៥១៥ | ១២១៩ | ១២៩៦ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ៣៨២០ | ១៨៤៤ | ១៩៧៦ | អាយុចូលនិវត្តន៍ |
| **សរុប** | **២១០០៦** | **១០០៦៩** | **១០៩៣៧** | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

### ខ.អត្រាកំណើន ដង់ស៊ីតេ និងរបាយប្រជាជន

ដោយយោងតាម CDB ឆ្នាំ២០១៧ បានឱ្យដឹងថា អត្រាកំណើនប្រជាជនជាមធ្យមក្នុងអំឡុងពេលចន្លោះពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧ មានចំនួន ១,១០ ភាគរយ ដោយសង្កេតឃើញថាមានការធ្លាក់ចុះខ្លាំងនៅឆ្នាំ ២០១៤ គឺមានអត្រាកំណើនប្រជាជនចំនួន -២,៤០ ភាគរយ ការធ្លាក់ចុះនេះ ដោយសារតែមានការផ្លាស់ប្តូរលំនៅឋានចេញ ចំណាកស្រុក ការពន្យាកំណើត មរណភាពកុមារ និងដោយសារកត្តាគ្រោះថ្នាក់ចរាចរណ៍ ជម្ងឺ។ល។ ប៉ុន្តែអត្រាកំណើននៅឆ្នាំ ២០១៥ មានការកើនឡើងខ្លាំងជាងគេ ដែលមានអត្រាកំណើនប្រជាជនចំនួន ៥,៩០ ភាគរយ ហើយការកើនឡើងនេះដោយសារមានការផ្លាស់ប្តូរទីលំនៅឋានចូលតាមរយៈអាពាហ៍ពិពាហ៍ និងការកើតថ្មី។ តែបើពិនិត្យទៅលើដំណើរទូទៅប្រជាជននៅឆ្នាំ២០១៩បានឱ្យដឹងថា អត្រាកំណើនជាមធ្យមក្នុងអំឡុង ១០ ឆ្នាំ (២០០៨-២០១៨) នៅខេត្តកំពង់ធំមានចំនួន 0,៦ ភាគរយ ប្រហាក់ប្រហែលអត្រាកំណើនខាងលើដែរ។ ដូច្នេះយើងបានកំណត់យកអត្រាកំណើនប្រជាជនជាមធ្យមប្រចាំឆ្នាំនៅក្នុងសង្កាត់ស្រយ៉ូវ ១,១០ ភាគរយ ជាបានការ ដើម្បីប្រើប្រាស់នៅក្នុងការព្យាករណ៍កំណើនប្រជាជនក្នុងសង្កាត់ ។

នៅក្នុងសង្កាត់ស្រយ៉ូវ ក្នុងឆ្នាំ២០១៧មានដង់ស៊ីតេប្រជាជនរស់នៅ ៧២,៩ នាក់/គម$^{២}$ ដោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើនតាំងលំនៅឋានជាលក្ខណៈរាយប៉ាយតាមភូមិ នៅតាមដងផ្លូវសំខាន់ៗនៅក្នុងសង្កាត់ជាពិសេសនៅតាមបណ្តោយផ្លូវជាតិលេខ៦។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្ដាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម |
|---|---|---|---|---|---|---|---|
| ចំនួនប្រជាជនសរុប | ១៩៩២៦ | ១៩៨៣៨ | ១៩៣៦២ | ២០៥០៤ | ២០៦០៤ | ២១០០៦ | |
| កំណើនមធ្យម(%) | | -០,៤៤ | -២,៤០ | ៥,៩០ | ០,៤៩ | ១,៩៥ | ១,១០ |

**☞ចំណាំ**

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង)x១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនីមួយៗ/ចំនួនឆ្នាំ)

### គ.ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងសង្កាត់ស្រយ៉ូវមានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ និងចំនួនតិចតួចកាន់សាសនាគ្រិស្ត ហើយប្រជាជនភាគច្រើនក្នុងសង្កាត់គោរពប្រពៃណី និងទំនៀមទម្លាប់បែបខ្មែរ ដូចជាពិធីរៀបមង្គលការប្រារព្ធពិធីបុណ្យទាននៅតាមវត្តអារាមនិងតាមផ្ទះ និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិនដូចជាពិធីសែនព្រេនដូនតា ពិធីបញ្ចុះសព និងភាគតិចបំផុតមានទំនៀមទម្លាប់បែបសាសនាគ្រិស្ត ដូចជាមានប្រារព្ធពិធីចូលព្រះវិហារគ្រិស្តនៅរៀងរាល់ថ្ងៃអាទិត្យជាដើម។ល។ និយាយរួមប្រជាជននៅក្នុងសង្កាត់ស្រយ៉ូវ តែងតែប្រារព្ធពិធីបុណ្យទាន តាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមកតាមជំនឿបែបខ្មែរ បែបចិន និងបែបគ្រិស្តសាសនា។

### ឃ.របររកទទួលទាន

បើយោងតាមទិន្នន័យពីមន្ទីរផែនការនៅឆ្នាំ ២០១៧ នៅក្នុងតារាងខាងក្រោមបានបង្ហាញឱ្យឃើញថានៅក្នុងសង្កាត់ស្រយ៉ូវ ប្រជាជនមានមុខរបរចម្បងចំនួន ១០ ៨១៥នាក់ ដែលនៅក្នុងនោះប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរកសិកម្មមានចំនួន ៧ ៩៨៨ នាក់ ស្មើនឹង ៧៣,៩ ភាគរយ ប្រកបមុខរបរសិប្បកម្មចំនួន ០២ នាក់ និងមុខរបរសេវាកម្មចំនួន ២ ៨២៥ នាក់ ស្មើនឹង ២៦,១ ភាគរយ ហើយមុខរបរទាំងអស់នោះ មានដូចជា៖ នេសាទត្រី ធ្វើស្រែ ចិញ្ចឹមសត្វ ឡើងត្នោត ដាំដំណាំបន្លែ កម្មករសំណង់ ស៊ីឈ្នួលដកស្ទូង ហាលស្រូវ ច្រកស្រូវ លីស្រូវ លក់ដូរ ជាងទង ជាងជួសជុលកង់ ម៉ូតូ រថយន្ត ជាងកាត់ដេរ ជាងកាត់សក់ ជាមន្ត្រីរាជការ អាជីវករលក់ដូរធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនធ្វើការមានជំនាញច្បាស់លាស់។

តារាង 5៖ តារាងមុខរបរ

| បរិយាយ | | ២០១៧ |
|---|---|---|
| សរុបអ្នកមានមុខរបរចម្បង | | ១០៨១៥ នាក់ |
| %សរុបអ្នកមានមុខរបរចម្បង | | ១០២,៤ % |
| %ស្រីមានមុខរបរចម្បង(គិតក្នុងស្រី១៨-៦០ឆ្នាំ) | | ៦០,៤ % |
| %ប្រុសមានមុខរបរចម្បង(គិតក្នុងប្រុស១៨-៦០ឆ្នាំ) | | ៩០,៤ % |
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | | **៧៩៨៨** នាក់ |
| **%អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៧៣,៩** % |
| **%ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៣០,១** % |
| ក្នុងនោះ៖ | %អ្នកមានមុខរបរធ្វើស្រែ | ៦៤,៥ % |

| បរិយាយ | | ២០១៧ |
|---|---|---|
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | ០,៣ % |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | ២,៧ % |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | ២,៨ % |
| | %អ្នកមានមុខរបរនេសាទ | ២,១ % |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | ១,៥ % |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | ០,០ |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសិប្បកម្ម** | | **០,០** |
| **%អ្នកបម្រើការងាក្នុងផ្នែកសិប្បកម្ម** | | **០,០** |
| **%ស្រីបម្រើការងាក្នុងផ្នែកសិប្បកម្ម** | | **០,០** |
| ក្នុងនោះ | %អ្នកបម្រើការងាសិប្បកម្មត្បាញរវៃ | ០,០ |
| | %អ្នកបម្រើការងាសិប្បកម្មផលិតពីផ្ដៅ វល្លិ ល្ពាក់.... | ០,០ |
| | %អ្នកបម្រើការងាសិប្បកម្មផលិតគ្រឿងសង្ហារឹម | ០,០ |
| | %អ្នកបម្រើការងាសិប្បកម្មចម្លាក់ធ្វើពីឈើ ថ្ម ស្ពាន់... | ០,០ |
| | %អ្នកបម្រើការងាសិប្បកម្មផលិតពីដែក អាលុយមីញ៉ូម | ០,០ |
| | %អ្នកបម្រើការងាសិប្បកម្មផលិតពីជ័រ ផ្លាស្ទីក .... | ០,០ |
| | %អ្នកបម្រើការងាសិប្បកម្មកែច្នៃឬវិចខ្ចប់គ្រាប់ធញ្ញជាតិ | ០,០ |
| | %អ្នកបម្រើការងាសិប្បកម្មផលិតផ្សេងៗ | ០,០ |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | ២៨២៥ នាក់ |
| **%អ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | ២៦,១ % |
| **%ស្រីបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | ១០,៦ % |
| ក្នុងនោះ | %អ្នកបម្រើការងាលក់ដូរ និងជំនួញ | ២,៧ % |
| | %អ្នកបម្រើការងាជាជាងជួសជុល | ០,៣ % |
| | %អ្នកបម្រើការងាក្នុងផ្នែកដឹកជញ្ជូន | ១,៦ % |
| | %អ្នកបម្រើការងាស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ៨,៨ % |
| | %អ្នកបម្រើការងាក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិក អង្គការ) | ៩,១ % |
| | %អ្នកបម្រើការងាជាមន្ត្រីរាជការ | ៣,៧ % |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

យោងទៅតាមទិន្នន័យពីមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា ប្រជាជនក្នុងសង្កាត់ស្រយ៉ូវ ក្រៅពីប្រកបមុខធ្វើស្រែ ដែលជាមុខរបរសំខាន់ហើយ ពួកគាត់តែងតែបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ដើម្បីទ្រទ្រង់ជីវភាពនៅក្នុងគ្រួសារឱ្យកាន់តែប្រសើរឡើង ហើយក្នុងនោះប្រជាជន ដែលមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្មចំនួន ២ ៨២២ នាក់ ស្មើនឹង ៨៤,២ ភាគរយ ក្នុងនោះមានស្ត្រីចំនួន ៩២៣ នាក់ ស្មើនឹង ២៧,៥ ភាគរយ អ្នកដែលមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្មចំនួន ៨៤៦ នាក់ ស្មើនឹង ១៥,៨ ភាគរយ ក្នុងនោះស្រី ២១៥ នាក់ ស្មើនឹង ៦,៤ ភាគរយ ចំណែកអ្នកប្រកបមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្មមិនមាននោះទេ។

ដូច្នេះតាមព័ត៌មានខាងលើបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋនៅក្នុងសង្កាត់ស្រយ៉ូវ ក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានមួយចំនួនប្រមាណជាងពាក់កណ្ដាល បានខិតខំប្រកបរបរទទួលទានបន្ទាប់បន្សំថែមទៀត មានដូចជាលក់ដូរ និងជំនួញ ផ្នែកដឹកជញ្ជូន និងកម្មករសំណង់។ល។ ចំណែកអ្នកដែលមានរបរផ្នែកសេវាកម្មជាចម្បងមានស្ទើរតែទាំងអស់បានខិតខំប្រកបរបរកសិកម្ម ដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោមនេះ៖

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| បរិយាយ | ២០១៧ | ២០១៧ចំនួន(នាក់) |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៨៤,២ % | ២៨២២ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ២៧,៥ % | ៩២៣ នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0 | 0 |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសិប្បកម្ម | 0,0 | 0 |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ១៥,៨ % | ៤៤៦ នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ៦,៤ % | ២១៥ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

### ង.ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឱ្យមានការផ្លាស់ប្ដូរលំនៅឋាន គឺដោយសារនៅភូមិចាស់ ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា៖ ស្ថានភាពដី នៅក្នុងតំបន់មូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយដីខូច ងាប់សារធាតុបម្រុង ហើយឡើងខ្សោះ ឬ ហិលជាដើម ខ្វះប្រភពទឹក ធ្វើឱ្យទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់ និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្ដូរលំនៅឋាន ប្រជាជនមួយចំនួនទៅរស់នៅទីប្រជុំឃុំ/សង្កាត់ ស្រុក/ក្រុង ខេត្ត/រាជធានី និងទៅធ្វើការងារនៅប្រទេសផ្សេងៗ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ គឺក្នុងគោលបំណងលើកស្ទួយជីវភាពគ្រួសារ។ យោងទៅតាមទិន្នន័យពីក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ បានបង្ហាញថា ប្រជាពលរដ្ឋដែលធ្វើការផ្លាស់លំនៅឋានចូលមានចំនួន ២៩ គ្រួសារ មនុស្សសរុប ១៨៧ នាក់ ក្នុងនោះមានស្ត្រី ៨៤ នាក់ និងប្រជាពលរដ្ឋដែលធ្វើការផ្លាស់លំនៅឋានចេញមានចំនួនមានចំនួន ៣២ គ្រួសារ មនុស្សសរុប ១៦១ នាក់ ក្នុងនោះស្រី ៧២ នាក់។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្ដូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ២៩ | ១៨៧ | ៨៤ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ៣២ | ១៦១ | ៧២ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

ដោយយោងទៅតាមទិន្នន័យមន្ទីរផែនការខេត្ត ឆ្នាំ២០១៧ បានបង្ហាញថា ប្រជាពលរដ្ឋធ្វើការចំណាកស្រុកមានចំនួនសរុប ២ ៨៥៥ នាក់ និងមានស្ត្រីចំនួន ១ ០២៦ នាក់។ នៅក្នុងនោះប្រជាជនដែលធ្វើការចំណាក

ស្រុកក្នុងប្រទេសមានចំនួន ១ ៩០៥ នាក់ ក្នុងនោះស្ត្រីចំនួន ៧៤១ នាក់ គឺជាចំណាកស្រុកមិនអចិន្ត្រៃយ៍នោះទេ ពួកគាត់ទៅធ្វើការនៅ ស្រុក ខេត្តផ្សេង ឬរាជធានីភ្នំពេញតែមួយរយៈប៉ុណ្ណោះ ពួកគាត់នឹងត្រលប់មកស្រុកជារើយៗ ចំណែក ចំណាកស្រុកទៅក្រៅប្រទេសមាន ចំនួន ៩៥០ នាក់ ស្រីចំនួន ២៨៥ នាក់ ពួកគាត់ទៅប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន និងប្រទេសកូរ៉េជាដើម ដោយពួកគាត់ទៅធ្វើការនៅទីនោះ តែមួយរយៈប៉ុណ្ណោះ និងត្រឡប់មកស្រុកកំណើតវិញបន្ទាប់ពីចប់កុងត្រាការងា។

ប្រជាជនធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុក និងខេត្តផ្សេងៗ ឬទៅប្រទេសជិតខាង ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងាគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្តាលស្វ័យប្រវត្តិធ្វើឱ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៩៖ ស្ថិតិប្រជាជនចំណាកស្រុក

| បរិយាយ | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ១៩៣១ | ១០៤៤ | ៨៨៧ | ១៩០៥ | ១១៦៤ | ៧៤១ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ១០២២ | ៧៦៤ | ២៥៨ | ៩៥០ | ៦៦៥ | ២៨៥ |
| **សរុប** | **២៩៥៣** | **១៨០៨** | **១១៤៥** | **២៨៥៥** | **១៨២៩** | **១០២៦** |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

### ១.១.៣.ស្ថានភាពសេដ្ឋកិច្ច

#### ក.ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថាគ្រួសារ ដែលមានជីវភាពគ្រាន់បើ និងគ្រួសារមានជីវភាពមធ្យម មានប្រភពចំណូលទី១ គឺលក់ស្រូវប្រាំង ប្រភពចំណូលទី២ គឺចំណាកស្រុក និងប្រភពចំណូលទី៣ គឺលក់ដូរ។ គ្រួសារមានជីវភាពក្រមានប្រភពចំណូលទី១ គឺលក់ស្រូវប្រាំង ប្រភពចំណូលទី២ គឺលក់ស្រូវ និងប្រភពចំណូលទី៣ គឺលក់កម្លាំងពលកម្ម និងលក់ដូរ។ និងក្រណាស់មានប្រភពចំណូលទី១ គឺលក់កម្លាំងពលកម្ម ប្រភពចំណូលទី២ គឺលក់កម្លាំងពលកម្ម និងប្រភពចំណូលទី៣ គឺលក់កម្លាំងពលកម្ម និងលក់ដូរ។

#### ខ.កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងទៅតាមតារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ ២០១៧ ដែលទទួលបានពីរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានខាងលើបានបង្ហាញឱ្យឃើញថានៅក្នុងឆ្នាំ២០១៧ ប្រជាពលរដ្ឋក្នុងសង្កាត់ស្រយ៉ូវ

មានកម្រិតជីវភាពរស់នៅចែកចេញជាបួនកម្រិត គឺ១)គ្រួសារបង្គួរ/គ្រាន់បើ មានចំនួន ១៥,៩ ភាគរយ ដែលជាគ្រួសារមានកម្រិតជីវភាពធូរធាជាងគេ មានដីចាប់ពី ៣,២៥ ហិកតា ២)គ្រួសារមធ្យមមានចំនួន ៦៧,៦ ភាគរយជាចំនួនច្រើនជាងគេ (លើសពាក់កណ្ដាល) ដែលមានដីកាន់កាប់ចាប់ពី ២,៥០ ហិកតា ៣)គ្រួសារក្រមានចំនួន ១០,២ ភាគរយ មានដីកាន់កាប់ពី ០,៦០ ហិកតា និង ៤)គ្រួសារក្រណាស់ដែលជាគ្រួសារក្រីក្របំផុត និងមានចំនួនតិចជាងគេត្រឹមតែ ៦,៣ ភាគរយ មានដីកាន់កាប់ពី ០,១៥ ហិកតា ចុះក្រោមរហូតដល់អ្នកគ្មានដី។

បើយោងទៅតាមការសាកសួរជាមួយនឹងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ បានបង្ហាញថាចំណូលប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាមធ្យមចំនួនចាប់ពី ២០ ០០០-២៥ ០០០ រៀល/គ្រួសារ/ថ្ងៃ ដូចនេះកម្រិតចំណូលប្រចាំឆ្នាំចាប់ពី ៧ ៣០០ ០០០- ៩១ ២៥០ ០០០ រៀល/គ្រួសារ/ឆ្នាំ ចំណែកការចំណាយប្រចាំឆ្នាំ មានដូចជា ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ សម្ភារៈសិក្សា និងថ្នាំសង្កូវ ព្រមទាំងការចំណាយផ្សេងៗទៀត ដែលស្មើនឹង ៥ ៤៧៥ ០០០-៧ ៣០០ ០០០ រៀល/គ្រួសា/ឆ្នាំ។

តារាង ១៖ តារាងកម្រិតជីវភាពរបស់ប្រជាជន

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/គ្មានដី | សរុប |
|---|---|---|---|---|---|
| ប្រៀបធៀបជា(%)<br>-តំបន់ទី-តំបន់ដីទំនាបមធ្យម ដំណាំស្រូវ លំនៅឋាន និង ដំណាំចម្រុះ | ១៥,៩% | ៦៧,៦% | ១០,២% | ៦,៣% | ១០០% |
| ទូទាំងសង្កាត់ | ១៥,៩% | ៦៧,៦% | ១០,២% | ៦,៣% | ១០០% |
| ចំនួនគ្រួសារ | ៧១៨ | ៣០៥១ | ៤៦០ | ២៨៤ | ៤៥១៣ |
| ទំហំគ្រួសារ | ៥នាក់/គ្រួសារ | ៦នាក់/គ្រួសារ | ៦នាក់/គ្រួសារ | ៧នាក់/គ្រួសារ | |
| កម្លាំងពលកម្ម | ៣នាក់/គ្រួសារ | ៣នាក់/គ្រួសារ | ៣នាក់/គ្រួសារ | ៣នាក់/គ្រួសារ | |
| ទំហំដីកាន់កាប់សរុប(ហ.ត) | ៣,២៥ | ២,៥០ | ០,៦០ | ០,១៥ | |
| ចំនួន និងប្រភេទក្បាលដី | ៤ | ៣ | ២ | ១ | |
| ដីលំនៅឋាន(ហ.ត) | ០,២៥ | ០,២០ | ០,១០ | ០,០៥ | |
| ដីស្រែ(ហ.ត) | ៣ | ២,៣ | ០,៥០ | ០ | |
| ប្រភេទពូជស្រូវដាំដុះ | ៥៤៥១, ផ្ការំដួល ប្រាំង,រាំងជ័យ, សែនក្រអូប, | ៥៤៥១, ផ្ការំដួលប្រាំង រាំងជ័យ សែនក្រអូប ផ្ការំដួល ខា៣ ចៅហ្វាយផ្កៅ | ៥៤៥១, ផ្ការំដួលប្រាំង រាំងជ័យ, សែនក្រអូប, ផ្ការំដួល ខា ៣,ចៅហ្វាយ ផ្កៅ | គ្មាន | |
| ធនធានកសិដ្ឋាន | | | | | |
| ដំណាំទី១៖ស្រូវ (ហ.ត) | ៣ (ហ.ត) | ២,៣(ហ.ត) | ០,៥(ហ.ត) | ០ | |
| ដំណាំទី២៖បន្លែ(ភូមិប្រម៉ាត់ដី ) | ០,១០(ហ.ត) | ០,១(ហ.ត) | ០,១(ហ.ត) | ០ | |
| ចំនួនគោ | ២ក/គ្រួ | ២ក/គ្រួ | ១ក/គ្រួ | ០ | |
| ចំនួនក្របី | ២ក/គ្រួ | ២ក/គ្រួ | ១ក/គ្រួ | ០ | |

| | | | | | |
|---|---|---|---|---|---|
| ការប្រើប្រាស់ ឧបករណ៍នៃសាទ | មង សន្ទូច លប ទ្រូ ព្រួល ឈ្នាង អង្រុត ស្នារ សម សាងផ្លែពីរ អួន សំណាញ់ | រ៉ូយ៉ាល់ លប ប្រើស១០០ សាងផ្លែពីរ អួនសំណាញ់ | មង សន្ទូច លប ទ្រូ ព្រួល ឈ្នាង អង្រុត ស្នារ សាងផ្លែពីរ អួនសំណាញ់ | បិទ បាច ចង សន្ទូច ស្ទូច | |
| ប្រភពចំណូលទី១៖ | ស្រូវប្រាំង | ស្រូវប្រាំង | ស្រូវប្រាំង | លក់កម្លាំងពលកម្ម | |
| ប្រភពចំណូលទី២៖ | ចំណាកស្រុក | ចំណាកស្រុក | ធ្វើស្រែ | លក់កម្លាំងពលកម្ម | |
| ប្រភពចំណូលទី៣៖ | លក់ដូរ | លក់ដូរ | លក់កម្លាំងពលកម្ម & លក់ដូរ | លក់កម្លាំងពលកម្ម & លក់ដូរ | |
| ការងាក្រៅពីកសិកម្ម(ប្រភេទពលកម្ម) | រោងចក្រ លក់ដូរ សំណង់ | រោងចក្រ លក់ដូរ សំណង់ | រោងចក្រ លក់ដូរ សំណង់ | តិចតួច | |
| ការប្រើប្រាស់ឥណទាន | ៨០% | ៧០% | ៥០% | ១០% | |

ប្រភព៖ *របាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមិថុនា ឆ្នាំ២០១៨*

### គ.ស្ថានភាពបំណុល និងអាត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងសង្កាត់ស្រយ៉ូវមានចំនួន ១០៦២គ្រួសារ ស្មើនឹងប្រមាណ ២៤ភាគរយ ដែលជាប់បំណុលពីមីក្រូហិរញ្ញវត្ថុ និងធនាគារ ដូចមានរាយខាងក្រោម៖

- អ្នកមានជីវភាពបង្គួរ៖មានលទ្ធភាពខ្ចីប្រាក់ពីធនាគារយកមកចងការបន្តនិងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរ ដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ។ល។
- អ្នកមានជីវភាពខ្សត់ខ្សោយក្រ៖ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ ឬមីក្រូហិរញ្ញវត្ថុឯកជន ដោយសារគ្មានទ្រព្យប្រចាំ តែត្រូវខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម។
- ចំណែកអ្នកក្របំផុត៖ ប្រកបរបរដោយលក់កម្លាំងពលកម្ម និងធ្វើចំណាកស្រុក។

សង្កាត់ស្រយ៉ូវមិនមានទីតាំងធនាគារឬទីតាំងស្ថាប័នមីក្រូហិរញ្ញវត្ថុនៅក្នុងសង្កាត់នោះទេ ប៉ុន្តែមានសេវាប្រាក់កម្ចីពីធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើននៅក្នុងមូលដ្ឋាន។ ចំពោះអាត្រាការប្រាក់វិញគិតតាមចំនួននៃប្រាក់កម្ចី បើកម្ចីនោះកាន់តែច្រើន អាត្រាការប្រាក់កាន់តែទាបរហូតដល់០,៩ភាគរយ តែបើកម្ចីកាន់តែតិចនោះ អាត្រាការប្រាក់កាន់តែខ្ពស់រហូតទៅដល់ ១,៨ភាគរយ ទាំងធនាគារនិងស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់មានអាត្រាការប្រាក់ គឺប្រហាក់ប្រហែលគ្នា ហើយប្រជាពលរដ្ឋទូទៅអាចទទួលសេវាកម្ចីពីធនាគារអេស៊ីលីដា កាណាឌីយ៉ា ប្រៃសណីយ៍ និងស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនដូចជា៖ ស្ថាបនា ហត្ថាកសិករ ប្រាសាក់ LOLC អេអឹមខេ បណ្ដាញសេដ្ឋកិច្ច អម្រឹត មហានគរ ចម្រើន សាមិក វីសិនហ្វាន់។ ចំណែកអ្នកខ្សត់ខ្សោយដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរ និងមធ្យម មានអត្រាការប្រាក់ខ្ពស់គឺចាប់ពី ១,៥ភាគរយ ទៅ ១០ភាគរយ ។

### ឃ.ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅនៅក្នុងសង្កាត់ស្រយ៉ូវ មានការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់សុទ្ធដើម្បីយកទៅពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញដី និងប្រើប្រាស់ទៅតាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុននិងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ។

### ង.ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងសង្កាត់ស្រយ៉ូវ ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស (ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃ ជាដើម
- និងចំណូលមួយចំនួនតូចទៀត បានមកពីគ្រួសារឬបងប្អូនដែលរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ។

## ១.១.៤.ស្ថានភាពសិក្សាធិការ

### ក.ស្ថានភាពអប់រំ

តាមផែនការអភិវឌ្ឍសង្កាត់ស្រយ៉ូវ ៥ឆ្នាំ (២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារា កុមារី គ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយឬក្មេងកំព្រា កុមារពិការក៏ដោយក្តី។ មកដល់ពេលបច្ចុប្បន្ន វិស័យអប់រំនៅក្នុងសង្កាត់ស្រយ៉ូវ មានការរីកចម្រើនដូចជា៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងសង្កាត់ផងដែរដូចជា៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាមតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ(អនក្ខរជន) ជាពិសេសមនុស្សមានវ័យចំណាស់ពួកគាត់ពុំសូវមានស្មារតីសិក្សារៀនសូត្រ ទោះបីមានការយកចិត្តទុកដាក់ជំរុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ។

រូបភាព 1៖ សាលារៀន

|  |  |
| --- | --- |
| សាលាបឋមសិក្សា | វិទ្យាល័យ |

នៅសង្កាត់ស្រយ៉ូវ មានកម្រិតសិក្សាចាប់ពីមត្តេយ្យសិក្សារហូតទៅដល់វិទ្យាល័យ (អនុវិទ្យាល័យ និងវិទ្យាល័យស្ថិតនៅក្នុងទីតាំងរួមគ្នា) ដែលនៅក្នុងនោះមានសាលាមត្តេយ្យចំនួន ០៨ កន្លែង ០៨ បន្ទប់ ១០ ថ្នាក់

គ្រូបង្រៀនចំនួន ១១នាក់ ជាស្ត្រី ហើយសិស្សដែលកំពុងរៀនមានចំនួន ២៧៥ នាក់ ក្នុងនោះស្រី ១៥១ នាក់ ។ សាលាបឋមសិក្សាវិញមានចំនួន ១១ កន្លែង ៤៧ បន្ទប់ ៥០ ថ្នាក់ គ្រូបង្រៀនចំនួន ៩៩ នាក់ ក្នុងនោះមានស្ត្រី ៥៣ នាក់ និងសិស្សកំពុងរៀនមានចំនួន ២ ៩៩៥ នាក់ ក្នុងនោះសិស្សស្រីចំនួន ១ ៤៩១ នាក់ ចំណែវិទ្យាល័យវិញមានចំនួន ០១ កន្លែង ២១ បន្ទប់ ២៣ ថ្នាក់ បង្រៀនមានចំនួន ៦៥ នាក់ ក្នុងនោះស្ត្រី ២៨ នាក់ និងសិស្សដែលកំពុងរៀនមានចំនួន ១១២៧ នាក់ មានស្រីចំនួន ៦២២ នាក់ ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងសង្កាត់ឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១.សាលាមត្តេយ្យ | ៨ | ៨ | ១០ | ២៧៥ | ១៥១ | ១១ | ១១ |
| ២.សាលាបឋមសិក្សា | ១១ | ៤៧ | ៥០ | ២៩៩៥ | ១៤៩១ | ៩៩ | ៥៣ |
| ៤.អនុវិទ្យាល័យ/វិទ្យាល័យ | ១ | ២១ | ២៣ | ១១២៧ | ៦២២ | ៦៥ | ២៨ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

ខ.ស្ថានភាពអក្ខរកម្ម

ដោយយោងទៅតាមទិន្នន័យពីមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញថា នៅក្នុងសង្កាត់ស្រយ៉ូវ មនុស្សមានអាយុពី ១៥-៤៥ឆ្នាំ មានចំនួន ៩ ៥៦៦ នាក់ ហើយនៅក្នុងចំណោមអ្នកទាំងនោះមាន ៤,៣ ភាគរយដែលមិនចេះអក្សរ ហើយបើគិតតាមក្រុមអាយុវិញមានអ្នកមិនចេះអក្សរអាយុពី ១៥-២៤ ឆ្នាំមានចំនួន ៧០ នាក់ ស្មើនឹង ១,៨ ភាគរយ អ្នកមិនចេះអក្សរអាយុពី ២៥-៤៥ឆ្នាំ មានចំនួន ៣៤៣ នាក់ ស្មើនឹង ៦,១ ភាគរយ ។

ប្រជាជនភាគច្រើន មិនបានចូលរៀនដោយសារតែសាលារៀននៅឆ្ងាយពីភូមិ សង្កាត់ ប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅសាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារៈសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរឹលឬមិនជឿនលឿន ហើយម៉្យាងវិញទៀតនៅក្នុងសង្កាត់មានថ្នាក់អក្ខរកម្មជាប្រចាំតែពួកគាត់ពុំទាន់មានពេលសិក្សាព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ ក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក។

**- អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយត្រូវបានពង្រឹងតាមរយៈការពិនិត្យឡើងវិញនូវគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធ និងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញកម្មវិធីចូលរៀនឡើងវិញ និងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ និងកម្មវិធីសមមូល។ ដើម្បីជំរុញឱ្យផែនការយុទ្ធសាស្ត្រអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១. បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់
២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា
៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង
៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ១៥០ | ៧០ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ៣,៩ | ១,៨ |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៥៨២ | ៣៤៣ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ១០,១ | ៦,១ |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៩៥៨៨ | ៩៥៦៦ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ៧,៦ | ៤,៣ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

### គ.ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យមន្ទីរផែនខេត្តឆ្នាំ២០១៧បានបង្ហាញឱ្យឃើញថាលទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងសង្កាត់ស្រយ៉ូវទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៤១២ នាក់ ស្រីមានចំនួន ២៤៦ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៤៤៦ នាក់ ស្រីមានចំនួន ២២៩ នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ២៩៧ នាក់ ស្រីមានចំនួន ១៥៥ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៥៣៧ នាក់ ស្រីមានចំនួន ២៦០ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ៧៦ នាក់ ស្រីមានចំនួន ២៨ នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ៥៣ នាក់ ស្រីចំនួន ៣០ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១៥ នាក់ មានស្រី ៦ នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ២០ នាក់ ស្រី ៧ នាក់

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ៤១២ | ២៤៦ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ៤៤៦ | ២២៩ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ២៩៧ | ១៥៥ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ៥៣៧ | ២៦០ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ៧៦ | ២៨ |
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ៥៣ | ៣០ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៥ | ៦ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ២០ | ៧ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

### ១.១.៩.ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព ថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ។ សង្កាត់ស្រយ៉ូវមានមណ្ឌលសុខភាពចំនួន ០១កន្លែង ស្ថិតនៅខាងលិចជាប់សាលាសង្កាត់

ក្នុងភូមិត្រពាំងវែងជាប់ផ្លូវជាតិលេខ៦។ មណ្ឌលសុខភាពនេះមានគ្រូពេទ្យចំនួន ០៨ នាក់ ពេទ្យឆ្មប ០៤ នាក់ ១១ បន្ទប់ និង ០៩ គ្រែ តែនៅក្នុងសង្កាត់មិនទាន់មានគ្លីនិកឯកជននោះទេ ។ ប្រភេទជម្ងឺ ដែលកាចសាហាវ ឬជម្ងឺឆ្លង ដែលកើតញឹកញាប់ គឺជាជម្ងឺរលាកផ្លូវដង្ហើម។ ស្ថានភាពមាតា និងទារកនៅក្នុងសង្កាត់ស្រយ៉ូវមានស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណនៅក្នុង១ឆ្នាំកន្លងទៅចំនួន៦នាក់ ស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមានចំនួន ២០៦នាក់ ទារកដែលបានកើតរស់ដោយឆ្មបបុរាណចំនួន ៦នាក់ ស្ត្រីដែលសម្រាលកូនដោយពេទ្យឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅមានចំនួន ២០៨នាក់ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបបុរាណមិនមាននោះទេ មរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែ ដោយពេទ្យឆ្មបមិនមាននោះទេ មរណភាពមទារកបន្ទាប់ពីសម្រាលនៅក្នុងចន្លោះ ០-១ខែដោយឆ្មបបុរាណមិនមាននោះទេ មរណភាពទារកបន្ទាប់ពីសម្រាលក្នុងចន្លោះ០-១ខែ ដោយពេទ្យឆ្មបមិនមានទេ ទារកដែលបានចុះសំបុត្រកំណើតមានចំនួន ១៨០នាក់ កុមារដែលមានអាយុនៅក្នុងចន្លោះពី៩-១២ខែមានចំនួន ១៧០ នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន ១៧០នាក់។ សម្រាប់ការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗធ្វើនៅមណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋមានជម្ងឺមួយចំនួន ដូចជា ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងគ្រុនឈាម។ ករណីជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់មកកាន់មណ្ឌលសុខភាពព្រោះមណ្ឌលសុខភាពស្ថិតនៅជិតពួកគាត់ ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែកដោយមធ្យោបាយផ្ទាល់ខ្លួន និងរថយន្តសង្គ្រោះរបស់ពេទ្យបង្អែកតែការចំណាយផ្សេងៗជាបន្ទុករបស់អ្នកជម្ងឺក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ។

តារាង 13៖ សុខភាពមាតានិងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | ៨ នាក់ |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | ៤ នាក់ |
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | ០ |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | ១១ បន្ទប់ |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | ៩ គ្រែ |
| ៦ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | ៧ នាក់ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | ៦ នាក់ |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | ២០៦ នាក់ |
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | ៦ នាក់ |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ២០៨ នាក់ |
| ១១ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១២ | ចំនួនមរណភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយពេទ្យឆ្មប | ០ |
| ១៣ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១៤ | ចំនួនមរណភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយពេទ្យឆ្មប | ០ |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ១៨០ នាក់ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ១៧០ នាក់ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ១៧០ នាក់ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

រូបភាព 2៖ មណ្ឌលសុខភាពក្នុងសង្កាត់ស្រយ៉ូវ




បើយោងទៅតាមពីទិន្នន័យមន្ទីរផែនការខេត្តនៅឆ្នាំ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹមពី ០៤ ទៅ ០៧គីឡូម៉ែត្រប៉ុណ្ណោះ ដូចដែលមាននៅក្នុងតារាងសង្ខេបខាងក្រោម។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព(គ.ម)

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | រលួស | ៧ គីឡូម៉ែត | |
| ២ | ប្រម៉ាត់ដី | ៥ គីឡូម៉ែត | |
| ៣ | កំពង់សំរោង | ៥ គីឡូម៉ែត | |
| ៤ | ពោធិ៍សែនស្នាយ | ៣ គីឡូម៉ែត | |
| ៥ | ពោធិ៍តាអ៊ុន | ២ គីឡូម៉ែត | |
| ៦ | ត្រពាំងវែង | ០,៥ គីឡូម៉ែត | |
| ៧ | ស្រយ៉ូវជើង | ២,៥ គីឡូម៉ែត | |
| ៨ | ស្រយ៉ូវត្បូង | ២ គីឡូម៉ែត | |
| ៩ | ពុកយុក | ១ គីឡូម៉ែត | |
| ១០ | ម្នាវ | ៤ គីឡូម៉ែត | |
| ១១ | ចំបក់ | ២,៧ គីឡូម៉ែត | |
| ១២ | កំរ៉ែង | ២,៨៨ គីឡូម៉ែត | |
| ១៣ | រកា | ៧ គីឡូម៉ែត | |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយមធ្យមពីភូមិទៅមណ្ឌលសុខភាព(ម.គ)




*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

### ១.១.៦.ស្ថានភាពយេនឌ័រ

បើយោងតាមផែនការអភិវឌ្ឍសង្កាត់ស្រយ៉ូវរយៈពេល៥ឆ្នាំ(២០១៨-២០២២) បានឱ្យដឹងថា សមភាពការងាររបស់ស្ត្រី និងបុរសក្នុងសង្កាត់ស្រយ៉ូវ នាពេលបច្ចុប្បន្នគ្មានការរើសអើងឬគាបសង្កត់ទៅលើស្ត្រីនោះទេ។ ផ្ទុយទៅវិញការងារយេនឌ័រ កំពុងតែមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងក្នុងការងាមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងនៅថ្នាក់សង្កាត់កំពុងត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងការកសាងផែនការអភិវឌ្ឍសង្កាត់ ក៏ដូចជាផែនការវិនិយោគផងដែរ។ ទោះជាយ៉ាងនេះក្តីបញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រី ដោយមានមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រ ខ្លះបោះបង់ការសិក្សាដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពក្នុងគ្រួសារ អ្នកខ្លះបានចំណាកស្រុកទៅភ្នំពេញដើម្បីធ្វើជាកម្មកររោងចក្រ។ ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ បានសហការជាមួយនឹងមន្ទីរការិយាល័យជំនាញជំនាញ និងដៃគូអភិវឌ្ឍនានាជុំវិញ និងលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូល និងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើតាមរយៈរបាយការណ៍នៃការវិភាគប្រព័ន្ធគ្សេត្រ-បរិស្ថានសង្កាត់ស្រយ៉ូវឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រនៅក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅរបស់កសិករក្នុងសង្កាត់ស្រយ៉ូវ មានលម្អិតនៅក្នុងតារាងខាងក្រោម។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រសង្កាត់ស្រយ៉ូវ

| សកម្មភាព | បុរស | ស្ត្រី | យោបល់បន្ថែម |
|---|---|---|---|
| *ស្រូវវស្សា* | | | |
| ការរៀបចំដីលើកទី១ និងទី២ | ៩០ | ១០% | ស្ត្រីជួយរៀបចំអាហារ និងរើសស្មៅ |
| ព្រួសស្រូវ | ៥០% | ៥០% | ស្ត្រីច្រកពូជ ជញ្ជូនពូជ |
| ការប្រើប្រាស់ជី(លើកទី១&២&៣) | ៨០% | ២០% | ស្ត្រីជួយទៅទិញជី លាយជី |
| ការបាញ់ថ្នាំ | ៩៥% | ៥% | ស្ត្រីជួយរៀបចំអាហារនិងការងារផ្សេង |
| ការគ្រប់គ្រងទឹក | ៩០% | ១០% | ស្ត្រីជួយបញ្ចេញ បញ្ចូលមួយចំនួន |
| ការគ្រប់គ្រងក្លីស្រែ | ៥០% | ៥០% | ស្ត្រី និងបុរសជួយគ្នា |
| ការច្រូតកាត់ | ៥០% | ៥០% | ស្ត្រី និងបុរសជួយគ្នា |
| ការដឹកជញ្ជូន | ៩០% | ១០% | ស្ត្រីរៀបចំការងាផ្ទះ |
| បោកបែន | ៥០% | ៥០% | ស្ត្រី និងបុរសជួយគ្នា |
| ហាលសម្ងួត | ២០% | ៨០% | ការងានៅផ្ទះ |

| | | | |
|---|---|---|---|
| ការទុកដាក់ | ២៥% | ៧៥% | ស្ត្រីរៀបចំកន្លែងទុកដាក់ |
| លក់ដូរ | ២៥% | ៧៥% | ស្ត្រីមានទំនាក់ទំនងល្អជាងបុរស |
| **សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត** | | | |
| ដំណាំឈើហូបផ្លែលក្ខណៈគ្រួសារ | ៥០ | ៥០ | បុរសដាំ ស្ត្រីជាអ្នកមើលថែទាំ |
| សួនបន្លែ | ៥០ | ៥០ | ស្ត្រីជាអ្នកមើលថែទាំ |
| ដំណាំរួមផ្សំ | ៤០ | ៦០ | ស្ត្រីជាអ្នកមើលថែទាំ |
| ចិញ្ចឹមគោ ក្របី | ៥៥% | ៤៥% | ស្ត្រីជួយខ្លះ និងយកទៅលក់ដូរ |
| ចិញ្ចឹមជ្រូក | ៤៥% | ៥៥% | នារីនៅផ្ទះច្រើនជាងបុរស |
| ចិញ្ចឹមមាន់ ទា | ៤០% | ៦០% | ការផ្តល់ចំណីស្ត្រីនៅផ្ទះច្រើនជាង |
| ការរកអនុផលចម្រុះ | ៥៥% | ៤៥% | ស្ត្រីជួយខ្លះ និងយកទៅលក់ដូរ |
| សិប្បកម្មដែក ផ្ទះឈើ | ៨០% | ២០% | បុរសជាមេជាងស្ត្រីបានជួយការងាងាយមួយចំនួន |
| ការថែទាំប្រឡាយ | ៥០% | ៥០% | បុរស និងស្ត្រីជួយគ្នា |
| ការបូមទឹកដាក់ពាង | ៥០% | ៥០% | បុរស និងស្ត្រីជួយគ្នា |
| នេសាទត្រី | ៦០% | ៤០% | ស្ត្រីបានជួយ និងយកទៅលក់ |
| ការរកឧស | ៩០% | ១០% | ការងារដែលប្រើកម្លាំងច្រើន |
| ឈ្លើង | ៥០ | ៥០ | បុរស និងស្ត្រីជួយគ្នា |
| កណ្តុរ | ១០០ | - | បុរសជាអ្នករក និងលក់តែម្តង |
| ខ្យង ក្តាម | ៤៥ | ៥៥ | បុរស និងស្ត្រីជួយគ្នា |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានសង្កាត់ស្រយ៉ូវឆ្នាំ២០១៧*

យោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានសង្កាត់ស្រយ៉ូវ ឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងសង្កាត់ស្រយ៉ូវដូចខាងក្រោម៖

១.ស្ត្រីភាគច្រើនជាអ្នកផលិតកសិកម្ម

២.បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣.ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤.សកម្មភាពការងាមានការចូលរួមធ្វើទាំងអស់គ្នា

៥.ការងាធ្ងន់ៗជាបន្ទុករបស់បុរស

បើយោងតាមប្រភពព័ត៌មាន ដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រនិងសិទ្ធិអំណាចស្ត្រីក្នុងសង្កាត់ស្រយ៉ូវ យើងសង្កេតឃើញថាបុរស និងស្ត្រីមិនមានការរើសអើងគ្នាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតែតិចតួចប៉ុណ្ណោះ ដូចជា ការងាធ្វើស្រែឃើញថាបុរសមានការចូលរួមច្រើនជាងស្ត្រីជាពិសេសការងារៀបចំដីស្រែឃើញការងានេះបុរសទទួលរ៉ាប់រងស្ទើរតែទាំងស្រុងដែលស្ត្រីមានកម្លាំងទន់ខ្សោយជាងជាអ្នកចម្អិនអាហារនៅផ្ទះ ហើយក៏ឃើញថាការងាដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំសម្លាប់សត្វល្អិត ការដាក់ជីច្រូតកាត់ និងការងាទុកដាក់ស្រូវជាដើមគឺ បុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងាក្នុងផ្ទះនិងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើនជាងបុរសវិញ តែនៅក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារ បុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហិង្សាក្នុនៅងគ្រួសារនៅឡើយ។ ប៉ុន្តែទោះបីមានបញ្ហា

ប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយ ក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២.ស្ថានភាពភូមិសាស្ត្រ

### ១.២.១.ទីតាំងភូមិសាស្ត្រ

សង្កាត់ស្រយ៉ូវជាសង្កាត់មួយ ដែលស្ថិតក្នុងការគ្រប់គ្រងរបស់ដែនរដ្ឋបាលក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានទីតាំងផ្អែកទៅលើនិយាមកាផែនទី (អាប់ស៊ីស) ៤៩១០៣៤,២៨ និង(អ័រដោនេ) ១ ៣៩៤ ៧០១,៦១ ។ សណ្ឋានដីនៅក្នុងសង្កាត់ស្រយ៉ូវ បើផ្អែកទៅតាមរបាយការណ៍ស្ដីពីការវិភាគប្រព័ន្ធកស្សិក្រ-បរិស្ថានបានឱ្យដឹងថា ជាតំបន់ដីមិនរាបស្មើមានទាបមានខ្ពស់ ដោយបានចែកចេញជា៣តំបន់គឺ

**តំបន់ទី I ៖** នៅភាគខាងជើងនៃសង្កាត់ ជាតំបន់ទំនាបមធ្យម មានប្រភេទដីកណ្ដោងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ស លាយខ្មៅ ត្រូវបានប្រើប្រាស់សម្រាប់មានដីលំនៅឋាន ដំណាំស្រូវ និងដំណាំចម្រុះ។

**តំបន់ទី II ៖** នៅប៉ែកកណ្ដាលនៃសង្កាត់ ជាតំបន់ទំនាបទាប មានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ ប្រផេះ ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវវស្សា និងស្រូវប្រាំង។

**តំបន់ទី III ៖** នៅភាគខាងលិចឈាងខាងត្បូងជាតំបន់ទំនាបទាបលិចទឹកតាមរដូវ មានប្រភេទដីកណ្ដោងពណ៌ក្រម៉ៅល្បាប់ ដីពពាយកណ្ដុរពណ៌ខ្មៅ ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវប្រាំងលិចទឹក។

ផែនទី 3៖ ផែនទីរយៈសង្កាត់ស្រយ៉ូវ



ផែនទី 4៖ ផែនទីពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ




តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន

| | | | |
|---|---|---|---|
| **រូបថត** |  |  |  |
| **ឈ្មោះតំបន់** | **តំបន់ទី I**<br>**តំបន់ទំនាបមធ្យមដាំដំណាំ ស្រូវ ដំណាំចម្រុះ និងលំនៅឋាន** | **តំបន់ទី II**<br>**តំបន់ទំនាបទាប ដំណាំស្រូវវស្សា និងស្រូវប្រាំង** | **តំបន់ទី III**<br>**តំបន់ទំនាបទាបលិចទឹកតាមរដូវដំណាំស្រូវប្រាំងលិចទឹករយៈពេលវែង** |
| **រៀបរាប់ដោយសង្ខេប** | -មានជម្រាលមធ្យមជម្រាលស្មើមានដីលំនៅឋានប្រជាជនភាគច្រើនជាកសិកដំណាំស្រូវនិង<br>ដំណាំចម្រុះ<br>-ដីកណ្តេងពណ៌ខ្មៅដីល្បាយខ្សាច់ពណ៌ស លាយខ្មៅ<br>-ស្រោចស្រពដោយទឹកភ្លៀងនិងទឹកស្ទឹងសែន,ទឹកអណ្តូង-ទឹកបឹងម្បៀ បឹងទទឹងថ្ងៃ បឹងតំណាក់រទេះបឹងទួលវត្ត<br>បឹងធំ ប្រឡាយ<br>កំពង់ពុទ្រាប្រឡាយកំពង់សំរោង អូរដូន | -តំបន់ទំនាបទាបដំណាំស្រូវធ្ងន់ស្រូវប្រាំង លិចទឹករយៈពេលខ្លី<br>-ដីល្បាយខ្សាច់លាយឥដ្ឋពណ៌សខ្មៅ ប្រផេះ<br>-ស្រោចស្រពដោយទឹកភ្លៀងទឹកស្ទឹងទឹកប្រឡាយ ទឹកអាងទឹក<br>បឹង ទឹកអូរទឹកជំនន់ទន្លេសាប | -ជម្រាលទាបលិចទឹកតាមរដូវស្រូវប្រាំងលិចទឹករយៈពេលវែង<br>-ដីកណ្តេងពណ៌ក្រម៉ៅល្បាប់ដីពពាយកណ្តុរពណ៌ខ្មៅ<br>-ស្រោចស្រពដោយទឹកភ្លៀង,ទឹកស្ទឹង,ទឹកប្រឡាយ,ទឹកអាងទឹកបឹង,ទឹកអូរ,ទឹកជំនន់ទន្លេសាប |

| | | | |
|---|---|---|---|
| | ពៅ អូរក្អែកពល (អូរត្រពាំងវែង)<br>-ការប្រើប្រាស់ពូជស្រូវចម្រុះ | | |
| **ឋានលេខា** | មានជម្រាលមធ្យមជម្រាលស្មើមានដីលំនៅឋានប្រជាជនភាគច្រើនជាកសិកដំណាំស្រូវនិងដំណាំចម្រុះ | តំបន់ទំនាបទាបដំណាំស្រូវធ្ងន់ ស្រូវប្រាំង លិចទឹករយៈពេលខ្លី | ជម្រាលទាបលិចទឹកតាមរដូវ ស្រូវប្រាំងលិចទឹករយៈពេលវែង |
| **ប្រភេទដី** | -ដីកណ្ដេងពណ៌ខ្មៅ<br>-ដីល្បាយខ្សាច់ពណ៌ស លាយខ្មៅ | - ដីល្បាយខ្សាច់លាយឥដ្ឋ ពណ៌ស ខ្មៅ ប្រផេះ | -ដីកណ្ដេងពណ៌ក្រម៉ៅល្បាប់<br>-ដីពពាយកណ្ដុរពណ៌ខ្មៅ |
| **ជលសាស្រ្ត** | -ទឹកភ្លៀង ទឹកស្ទឹង<br>ទឹកប្រឡាយ ទឹកអណ្តូង<br>ទឹកអូរ ទឹកបឹងម្សៀ | -ទឹកភ្លៀង ទឹកស្ទឹង ទឹកប្រឡាយ<br>ទឹកអាង ទឹកបឹង ទឹកអូរ<br>ទឹកទន្លេសាប | -ទឹកភ្លៀង ទឹកស្ទឹង<br>ទឹកប្រឡាយ ទឹកអាង<br>ទឹកបឹង ទឹកទន្លេសាប |
| **ធនធានទឹក** | -ប្រឡាយកំពង់ពុទ្រា<br>-ប្រឡាយកំពង់សំរោង<br>-ប្រឡាយអូរដូនពៅ<br>-អូរក្អែកពល(អូរត្រពាំងវែង)<br>-បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ<br>-បឹងទួលវត្ត បឹងធំ | -ប្រឡាយកំពង់ពុទ្រា<br>-ប្រឡាយកំពង់សំរោង<br>-ប្រឡាយអូរដូនពៅ<br>-អូរក្អែកពល(អូរត្រពាំងវែង)<br>-អាងឯកជន(បាត់ពន្លាក)<br>-បឹងគ្រោះក្រោម បឹងឈូកច្បារ<br>-បឹងគ្រោះកណ្ដាល គ្រួសក្រជា<br>-បឹងត្រពាំងជង្រុក បឹងកូនក្អែក<br>-បឹងទឹកស្រាំ លាក់ពាង ជួន<br>-បឹងឈូកប្រដីតបឹងឈូកបឹងគោក សំរោង<br>-បឹងសេកស្លាប់ បឹងមូសខាំ បឹង ខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោតបឹងតាឡុង<br>-បឹងត្រពាំងវែង ដំរីរត់ បឹងថ្លុកពោ បឹងថ្វា សាលា ត្រស់វែង ត្រស់ធំ<br>-បឹងកណ្ដាប់ចង្អេរ តាលហាល ស្នួងបែន រំពេរ កូនខ្លា តាសៀង<br>-បឹងគោកត្នោត ទំនប់សាប ស្រះ លោក គ្រាប់បាយ ត្រស់អាច់ សៀម ហាន់ស្លា ផ្ទរលាន់ យោល ទោង ក្បាលខ្មោច ត្រសែង ជី មឿងសុខ បាក់សម សាក់ជ័យ ប្រាំបែកចាន ស្នោ តាឡុក | -ប្រឡាយកំពង់ពុទ្រា<br>-ប្រឡាយកំពង់សំរោង<br>-ប្រឡាយអូរដូនពៅ<br>-អូរក្អែកពល<br>-អាងឯកជនចំនួន១១<br>-បឹងកុកទើត បឹងរាំងទេរ<br>-បឹងតាមប្រដើស (ក្នុងអាងទឹកក្រុមហ៊ុន)<br>-បឹងម៉ាយាង(ក្នុងអាងពីរពាន់)<br>-បឹងសារាយក្នុង (ក្នុងអាងពីរពាន់)<br>-បឹងសារាយក្រៅ (ក្នុងអាងពីរពាន់)<br>-បឹងថ្លុកអញ្ចាញ (ក្នុងអាងពីរពាន់)<br>-បឹងអាខ្មាច (ក្នុងអាងពីរពាន់)<br>-បឹងកាឆឹងរលំពៅ (ក្នុងអាងពីរពាន់)<br>-បឹងថ្លុករ៉ែន (ក្នុងអាងពីរពាន់)<br>-អូរស្ដីទឹម (ក្នុងអាងពីរពាន់)<br>-បឹងស្នែងក្របីបឹងផ្ទោល បឹងឈូកសបឹងលេងមាសបឹង ចំរេះបឹងអន្ទង់បឹងបាក់សមបឹង ក្បាលបីបឹងយាយឡាក់បឹង ក្រោមចំលាក់<br>បឹងក្រពើសារ<br>-បឹងឈ្មោះបឹងក្រពើគោះ បឹងជំរុំបាតី<br>-បឹងថ្មល់ខ្សាច់បឹងអាថ្ម |

| | | | |
|---|---|---|---|
| | | | បឹងតាព្រួច<br>-បឹងក្រាយ បឹងបាក់ដឹប<br>បឹងវ៉ាន់ |
| **គម្របដី និងការប្រើប្រាស់ដី** | -សង់លំនៅឋាន<br>-សាលារៀន(បឋមសិក្សា១០ អនុវិទ្យាល័យ១ វិទ្យាល័យ១)<br>-មណ្ឌលសាសនា<br>(វត្ត៥ គ្រិស្តសាសនា)<br>-ដីមណ្ឌលសុខភាព<br>-ដីសាលាសង្កាត់ ដីប៉ុស្តប៉ូលី<br>-ដីផ្សារ ២កន្លែង ដីអាគារសហគមន៍ (ជំនួយកូរ៉េ) ៣កន្លែង ដីសាលាបុណ្យ ប្រាសាទបុរាណ១<br>ទួលបុរាណ(បឹងថ្នាំង,ទួលឆ្កាំង,ទួលធំ,ទួលតាទា,ទួលចេក,ទួលគោកត្នោត,ទួលល្ហុង,ទួលទឹកស្រាំ,ទួលសំរោងពែន,ទួលគោកទិល,ទួលតាសេក, ទួលបឹងផុក,ទួលត្នោត,ទួលតាឆាន, ទួលថ្វាន់,ទួលសំរោងតាប៉ឹម,ទួលស្វាយ,ទួលលាប,ទួលកំភ្លុក,ទួលបឹងត្របែក,ទួលអង្រ្គង,ទួលកំពង់ព្រួច ទួលគោកត្នោត,ទួលស្មរ,ទួលរង់វ៉ា, ទួលគោកពោធិ,ទួលកន្សែងសូត្រ, ទួលពោដូនសោ,<br>ទួលស្លែ,ទួលស្តៅ,ទួលក្រពេញ, ទួលច្រេស,ទួលទ្រាជូ,ទួលហ៊ុន, ទួលពោធិសែនខ្មុក,ទួលភូមិចាស់, ទួលចារ,ទួលល្វា,ទួលក្រោល,ទួលភ្មៀតទួលស្រឹង,ទួលស្លែង,ទួលពោធិប្រាសាទ,ទួលអ្នកតា,ទួលចារ<br>ទួលថ្វាន់<br>-ដំណាំស្រូវវស្សា ស្រូវប្រាំង<br>ឪឡឹក ពោត សណ្តែក<br>(សណ្តែកបាយ សណ្តែកដី)<br>-ដំណាំបន្លែ(ស្ពៃ,សាលាដ,ម្រះ, ននោង,ល្ពៅ,ត្រកួន,ត្រសក់, សណ្តែកកួរ)<br>-ដំណាំឈើហូបផ្លែ(ដូង,ស្វាយ,ចេក ទឹកដោះ,ខ្នុរ,ទាប,ក្រូច,<br>-ដីដាំដំឡូងមី,អំពៅ,ឫស្សី | -ទួលបុរាណ(ទួលតាឡី,ប្រាសាទ ឡោក,ទួលវែង,ទួលផ្សោត,ទួលព្រំខ, ទួលខុន,ទួលដំណាក់រទេះ,ទួលខ្មោច, ទួលធំ,ទួលស្នាយដួច,ទួលព្រៃស្រប, ទួលពោធិបឹង,ទួលនួន,ទួលជ្រឹង,ទួលពង្រោះ,ទួលតាគង់,ទួលតាយី,ទួលចារ,តាអុក<br>ទួលតាវើន)<br>-ស្រូវប្រាំង<br>-ស្រូវវស្សា<br>-ដំណាំស្វាយ(ដាំលើខ្នងអាង)<br>-ស្វាយចន្ទី(ដាំលើខ្នងអាង) | -ស្រែប្រាំង<br>-ព្រៃលិចទឹក(ក្នុងអាង)<br>-អាងទឹកឯកជន១១<br>- បឹង,ត្រពាំង<br>- អូរក្បាលបី |
| **ដំណាំសំខាន់ៗ** | -ដំណាំស្រូវស្សា<br>-ដំណាំស្រូវប្រាំង<br>-ដំណាំឪឡឹក<br>-ដំណាំពោត | -ដំណាំស្រូវវស្សា<br>-ដំណាំស្រូវប្រាំង<br>-ដំណាំឪឡឹក<br>-ដំណាំម្ទេស (ក្រុមហ៊ុនចិន) | -ដំណាំស្រូវប្រាំង<br>-ដំណាំស្រូវវស្សា |

| | | | |
|---|---|---|---|
| | -ដំណាំសណ្ដែក(សណ្ដែកបាយ សណ្ដែកដី)<br>-ដំណាំបន្លែ(ស្ពៃ,សាលាដ,ម្រះ, ននោង,ល្ពៅ,ត្រកួន,ត្រសក់ | -ដំណាំត្រសក់ចំណា<br>-ដំណាំរត្រសក់ស្រូវ<br>-ស្វាយចន្ទី(ដាំលើខ្នងអាង)<br>-ស្វាយកែវរមៀត(ដាំលើខ្នងអាង) | |
| **ពូជស្រូវ** | -ស្រូវរាំងជ័យ(ស្រូវធ្ងន់)<br>-ស្រូវផ្កាខ្ញី(ស្រូវធ្ងន់)<br>-ស្រូវដំណើបនាងនក់<br>-ស្រូវនាងអមួ(ស្រូវធ្ងន់)<br>-ស្រូវផ្ការំដួល(ស្រូវកណ្ដាល)<br>-ស្រូវផ្កាម្លិះ(ស្រូវកណ្ដាល)<br>-ស្រូវចង្វាយផ្តៅ(កណ្ដាល)<br>-ស្រូវក្រឹម (ស្រូវកណ្ដាល)<br>-ស្រូវ៥០១(ស្រូវប្រាំង)<br>-ស្រូវសែនក្រអូប(ស្រូវប្រាំង) | -ស្រូវពពាយ(ស្រូវធ្ងន់)<br>-ស្រូវបឹងកក(ស្រូវធ្ងន់)<br>-ស្រូវក្រឹមឡើងទឹក(ស្រូវធ្ងន់)<br>-ស្រូវក្រញូល(ស្រូវធ្ងន់)<br>-ស្រូវ៥៤៥១(ស្រូវប្រាំង)<br>-ស្រូវ៥០៤(ស្រូវប្រាំង)<br>-ស្រូវ៤៩(ស្រូវប្រាំង)<br>-ស្រូវសែនក្រអូប(ស្រូវប្រាំង) | -ស្រូវ៥៤៥១(ស្រូវប្រាំង)<br>-ស្រូវ៥០៤(ស្រូវប្រាំង)<br>-ស្រូវ៤៩(ស្រូវប្រាំង) |
| **ការប្រើប្រាស់ជី** | -ជី DAP ជី UREA ជី KLi<br>ជីចម្រុះ ជី ធម្មជាតិ | -ជី DAP ជី UREA ជី KLi<br>-ជីចម្រុះ | -ជី DAP ជី UREA<br>-ជី KLi ជីចម្រុះ |
| **ការចិញ្ចឹមសត្វ** | -ចិញ្ចឹមគោ ចិញ្ចឹមក្របី<br>-ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់<br>-ចិញ្ចឹមទា ចិញ្ចឹមត្រី | -ចិញ្ចឹមគោ (រដូវប្រាំង)<br>-ចិញ្ចឹមក្របី (រដូវប្រាំង)<br>-ចិញ្ចឹមទា | -ចិញ្ចឹមគោ(រដូវប្រាំង)<br>-ចិញ្ចឹមក្របី(រដូវប្រាំង)<br>-ចិញ្ចឹមទា |
| **ដីរបស់រដ្ឋនិងសហគមន៍** | -ដីសាលាសង្កាត់,ដីសាលារៀន<br>-ដីមណ្ឌលសុខភាព,ដីវត្ត,ដីសាលាបុណ្យ ដីទួលបុរាណ,ដីប្រាសាទបុរាណដីផ្លូវ ប្រឡាយ ដីបឹង ,ដីអូរ ដីស្ទឹង សហគមន៍ | -ដីបឹង<br>-ដីអូរ<br>-ដីផ្លូវ<br>-ដីទួលបុរាណ | -ដីបឹង<br>-ដីស្ទឹង |
| **បញ្ហាផ្សេងៗ** | -ខ្វះទឹកស្រោចស្រព<br>-ដីខ្វះជីវជាតិ<br>-ដីស្រែមិនទាន់រាបស្មើ<br>-ខ្យងមាសស៊ីស្រូវ<br>-ដីស្រែសម្បូរស្មៅចង្រៃ<br>-សត្វល្អិតបំផ្លាញដំណាំស្រូវ (មមាចត្នោត,សង្កើច,កណ្ដុរ,ស្រឹង, កណ្ដុរ,ក្ដាម)<br>-បញ្ហាជួបគ្រោះរាំងស្ងួត<br>-បញ្ហាជួបទឹកជំនន់ទឹកភ្លៀង<br>-ធ្វើស្រែតាមទម្លាប់តៗគ្នា<br>-បញ្ហាខ្វះបច្ចេកទេសកសិកម្ម<br>-បញ្ហាតម្លៃស្រូវមានការប្រែប្រួល<br>-សត្វចិញ្ចឹមកើតជម្ងឺច្រើន(គោ,ក្របី ,ជ្រូក,មាន់,ទា)<br>-នេសាទត្រីខុសច្បាប់<br>-ការចាក់ដីរំលោភយកដីអូរនិង ប្រឡាយធ្វើកម្មសិទ្ធិ | -ខ្វះទឹកស្រោចស្រព<br>-ជួបគ្រោះរាំងស្ងួត<br>-ជួបទឹកជំនន់ទឹកទន្លេ<br>-ដីខ្វះជីវជាតិ<br>-ដីស្រែមិនទាន់រាបស្មើ<br>-ដីស្រែសម្បូរស្មៅចង្រៃ<br>-សត្វល្អិតបំផ្លាញដំណាំស្រូវ(មមាចត្នោត,សង្កើច,កណ្ដុរ, ស្រឹង,កណ្ដុរ,ក្ដាម)<br>-បញ្ហាជំងឺលើដំណាំស្រូវ<br>-ធ្វើស្រែតាមទម្លាប់តៗគ្នា<br>-បញ្ហាតម្លៃស្រូវនៅទីផ្សារមានការប្រែប្រួល<br>-បញ្ហាខ្វះបច្ចេកទេសកសិកម្ម<br>-ការព័ទ្ធយកបឹងធម្មជាតិរបស់រដ្ឋកាន់កាប់ជាលក្ខណៈឯកជន<br>-នេសាទត្រីខុសច្បាប់<br>-ការចាក់ដីរំលោភយកដីអូរនិង | -ខ្វះទឹកស្រោចស្រព<br>-បញ្ហាជួបគ្រោះរាំងស្ងួត<br>-បញ្ហាទឹកជំនន់ទឹកទន្លេ<br>-បញ្ហាតម្លៃស្រូវនៅទីផ្សារមានការប្រែប្រួល<br>-សត្វល្អិតបំផ្លាញស្រូវ(មមាចត្នោត,សង្កើច,កណ្ដុរ,ស្រឹង, កណ្ដុរ)<br>-តម្លៃស្រូវនៅទីផ្សារមានការប្រែប្រួល<br>-បញ្ហាជំងឺលើដំណាំស្រូវ<br>-ខ្វះបច្ចេកទេសកសិកម្ម<br>-បញ្ហាដីមិនរាបស្មើ<br>-នេសាទត្រីខុសច្បាប់<br>-ការព័ទ្ធយកបឹងធម្មជាតិរបស់រដ្ឋកាន់កាប់ជាលក្ខណៈឯកជន |

| | | | |
|---|---|---|---|
| | -ការរំលោភយកដីទួលសាធារណៈរបស់រដ្ឋកាន់កាប់ | ប្រឡាយធ្វើកម្មសិទ្ធិ | |
| **កាលានុវត្តភាព/ឱកាស** | -កែប្រែតំបន់ធ្វើស្រូវវស្សាទៅជាតំបន់ស្រែប្រាំង<br>-ស្តាប្រឡាយដែលមានស្រាប់<br>-សាងសង់ប្រឡាយជើងក្អែប<br>-រៀបចំកៀរពង្រាបដីស្រែ<br>-បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ<br>-បើវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំ បន្លែ<br>-បើវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ បង្កើនការចិញ្ចឹមត្រី<br>-បើកវគ្គបណ្តុះបណ្តាលការប្រើប្រាស់ថ្នាំ ពុលកសិកម្មសមស្រប<br>-រៀបចំស្ថានីយ៍បូមទឹកស្ទឹងសែន<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-អប់រំការយល់ដឹងពីបរិស្ថាន | -កែប្រែតំបន់ធ្វើស្រូវវស្សាទៅជាតំបន់ស្រែប្រាំង<br>-រៀបចំប្រព័ន្ធស្រោចស្រព<br>-រៀបចំកៀរពង្រាបដីស្រែ<br>-រៀបចំប្រឡាយជើងក្អែប<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-ពង្រឹងការអនុវត្តច្បាប់ជលផល<br>-អប់រំការយល់ដឹងពីបរិស្ថាន | -រៀបចំកៀរពង្រាបដីស្រែ<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-ពង្រឹងការអនុវត្តច្បាប់ជលផល<br>-អប់រំការយល់ដឹងពីបរិស្ថាន |

ប្រភព៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ- បរិស្ថានសង្កាត់ស្រយ៉ូវ*

បើយោងទៅតាមរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានបានបង្ហាញឱ្យឃើញថា នៅក្នុងសង្កាត់ស្រយ៉ូវមានប្រភពទឹកពី ១)ទឹកភ្លៀង ២)ស្ទឹងសែន ៣)អូរក្អែកពល(អូរត្រពាំងវែង) អូរស្តីទឹម ៤)បឹងចំនួន៧៣ ដូចជាបឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត បឹងធំ បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងគ្រួសក្រចាបឹងត្រពាំងជង្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន បឹងឈូកប្រដឹត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ បឹងតាលហាល បឹងស្នួង បឹងបែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះ លោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្តា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងដីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យ បឹងប្រា បឹងបែកចាន បឹងស្មោ បឹងតាឡក បឹងស្វែងក្របីបឹងផ្គោល បឹងឈូកស បឹងលេងមាស បឹងចំរេះ បឹងអន្ទង់ បឹងបាក់សម បឹងក្បាលបី បឹងយាយឡាក់ បឹងក្រោមចំលាក់ បឹងក្រពើសារ បឹងឈ្មោះ បឹងក្រពើគោះ បឹងជំរុំបាតី បឹងថ្មល់ខ្សាច់ បឹងអាថ្ម បឹងតាព្រួច បឹងក្រាយ បឹងបាក់ដឹប បឹងវ៉ាន់ ៥)អាងស្តុកទឹកចំនួន ១១ ដែលក្នុងនោះមានអាងធំចំនួនពីរគួរឱ្យកត់សម្គាល់គឺ អាងបាត់ពន្លាក និងអាង២០០០(ក្នុងអាង២០០០ មានបឹងចំនួន១១ ដូចជាបឹងថ្លុកអញ្ចាញ បឹងកុកទើត បឹងរាំងទេរ បឹងតាមប្រដេស បឹងម៉ាឃាង បឹងសារាយ បឹងសារាយក្រៅ បឹងថ្លុកអញ្ចាញ បឹងអាខ្មាច បឹងកាឡឹងរលំពៅ បឹងថ្លុករ៉ែន)។ ទន្ទឹមនោះសង្កាត់ស្រយ៉ូវមានប្រឡាយនាំទឹកពីប្រភពទឹកខាងលើចំនួន ២៣ខ្សែ មានប្រវែង ៦៣ ០០០,០៧ ម៉ែត្រថែមទៀត ដែលក្នុងនោះមានប្រឡាយមេ២ខ្សែ ប្រវែង ១៩ ២២០,៩៧ ម៉ែត្រ ដែលខ្សែទី១ ប្រវែង ១១ ៦១៦,៨៧ ម៉ែត្រ ចេញពីស្ទឹងសែនឆ្ពោះមកភូមិត្រពាំងវែងជាប់និងសាលាបុណ្យពោធិតាអុន ធ្លាក់ដល់ភូមិរលួស។ ខ្សែទី២ ប្រវែង ៧ ៦០៤,១១ ម៉ែត្រ ពីភូមិពោធិ៍សែនស្នាយកាត់ផ្លូវជាតិលេខ ៦ ឆ្ពោះទៅភូមិរលួស។ ចំណែកប្រឡាយរងមាន ៣ ខ្សែ ប្រវែង ៤ ២២៣ ម៉ែត្រ ដែលខ្សែទី ១ ៧៨៩,៩៦ ម៉ែត្រ ចេញពីប្រឡាយទី១ ទៅទិសខាងត្បូង តំបន់ដីស្រែប្រាំង មកទល់ទួលព្រៃស្របៗ ខ្សែទី២

ប្រវែង ១ ៥៣០,៥៩ ម៉ែត្រ ចេញពីអូរដូនពៅទៅខាងកើតភូមិម្នាវនៅក្បែរព្រំប្រទល់ឃុំកកោះ និងខ្សែទី៣ ប្រវែង ១ ៩០២,៤៥ម៉ែត្រ ចេញពីទួលព្រៃស្របឆ្ពោះទៅខាងត្បូងតំបន់ដីស្រែក្រោមព្រមទាំងប្រឡាយជើងក្អែប ១៨ ខ្សែ ប្រវែង ៣៩ ៥៥៦,០៥ ម៉ែត្រ។ ចំណែកទឹកនៅក្រោមដីក្នុងសង្កាត់ស្រយ៉ូវមានការប្រើប្រាស់តាមរយៈអណ្តូងស្នប់សម្រាប់ស្រោចស្រព និងសម្រាប់ការប្រើប្រាស់ទូទៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ។ ប្រភពទឹកដែលនាំទឹកមកប្រើប្រាស់នៅក្នុងសង្កាត់ពីប្រភពទឹកខាងលើ គឺតាមរយៈប្រឡាយមេនិងប្រឡាយរង ដែលសង្កាត់បានជីក និងស្តាសម្រាប់នាំយកទឹកមកស្រោចស្រព នៅក្នុងភូមិសាស្ត្រស្រែវស្សា និងស្រែប្រាំង ក្រៅពីប្រភពទឹកខាងលើសង្កាត់មានតែទឹកអណ្តូ ស្រះទឹកដែលជាប្រភពទឹកបន្ទាប់បន្សំតែប៉ុណ្ណោះ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

| ល.រ | ប្រភេទប្រឡាយ | ចំនួនប្រឡាយ | ប្រវែង(ម៉ែត្រ) |
|---|---|---|---|
| ១ | ប្រឡាយមេ | ២ | ១៩២២០,៩៧ |
| ២ | ប្រឡាយរង | ៣ | ៤២២៣ |
| ៣ | ប្រឡាយតូច | ១៨ | ៣៩៥៥៦,០៩ |
| **ប្រវែងប្រឡាយសរុប** | | **២៣** | **៦៣០០០,០៧** |

រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ



ប្រឡាយរង



ប្រឡាយតូច

ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រ សង្កាត់ស្រយ៉ូវ




### ១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងសង្កាត់ស្រយ៉ូវ ក៏ដូចជានៅទូទាំងខេត្ត គឺទទួលរបបខ្យល់ពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅហើយសើម។ របបខ្យល់មូសុង បាននាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗ។

បើយោងតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំប្រចាំក្រុងស្ទឹងសែន នៅក្នុងឆ្នាំ ២០១៧បានបង្ហាញថាក្រុងស្ទឹងសែន មានភ្លៀងធ្លាក់ចំនួន ១០៩ដង ដែលមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន ១ ២៦៦,២ ម.ម។

**អំពីសីតុណ្ហភាព៖**

- រដូវរងា៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨ អង្សា)
- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥ អង្សា)
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០ អង្សា ជាមួយនិងការឡើងសំណើមទៅដល់ ៩០ ភាគរយ)នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។

នៅក្នុងសង្កាត់ស្រយ៉ូវមានសំណើមជាមធ្យម៥៥ភាគរយ និងមានល្បឿនខ្យល់៣គីឡូម៉ែត្រ/១ម៉ោង។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | ៣ | ២ | ៧៣,៨ | ៦៣,៦ | ១៧៣,២ | ១៣៦,៧ | ២៦៦,៣ | ១៧៤ | ២២៨,៩ | ២៤៧,៦ | ៧៤,៥ | ៧០,៥ |
| ចំនួនថ្ងៃធ្លាក់ភ្លៀង | ២ | ១ | ៦ | ៥ | ១៣ | ៨ | ១៧ | ១៦ | ១០ | ១២ | ១៤ | ៥ |

ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភព៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

### ១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នសង្កាត់ស្រយ៉ូវ មានតែប្រព័ន្ធគមនាគមន៍ផ្លូវគោកនិងផ្លូវទឹកប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់នៅក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងសង្កាត់ នៅក្នុងនោះមានផ្លូវសំខាន់ៗដែលជាច្រកចេញ-ចូលរបស់សង្កាត់ចំនួន ០២ ខ្សែ ប្រវែង ១១ ៥០១,៦៣ ម៉ែត្រ ដែលខ្សែទី១ គឺជាផ្លូវជាតិ៦មានប្រវែង ៨ ៣៤៦,៩៦ ម៉ែត្រ ឆ្លងកាត់សង្កាត់ចាប់ពីព្រំប្រទល់ឃុំត្បូងក្រពើឆ្ពោះទៅកាន់ទីរួមខេត្តកំពង់ធំ និងខ្សែទី២ គឺផ្លូវជាតិ៥0C មានប្រវែង ៣១៣៦,៦៧ម៉ែត្រ ដែលបែកចេញពីផ្លូវជាតិលេខ៦ឆ្ពោះទៅខាងត្បូងឆ្លងកាត់សង្កាត់ រហូតដល់ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ព្រមទាំងផ្លូវលំក្រាលគ្រួសក្រហម ៥៧ខ្សែ ប្រវែង ៧១ ៣៨៣,៧១ម៉ែត្រ ផ្លូវលំដីសលើករួចឬផ្លូវរទេះ៨0ខ្សែ ប្រវែង ១0៤ ២០១,៧២ម៉ែត្រ ។ ផ្លូវគ្រួសក្រហមមួយចំនួនដែលធ្វើ និងជួសជុលរួចហើយត្រូវបានខូចខាតទៅវិញ ធ្វើឱ្យប្រជាពលរដ្ឋពិបាកក្នុងការធ្វើដំណើរ ជាដំណោះស្រាយចំពោះមុខ គណៈកម្មការកសាងផែនការ និងថវិកាក្រុមប្រឹក្សាសង្កាត់ បានលើកគម្រោងជួយជួសជុលផ្លូវក្រាលគ្រួសក្រហមចំនួន ៧ខ្សែ នៅក្នុងភូមិពុកយុក ម្នាវ ចំបក់ កំរ៉ែង និងភូមិរកា ដែលមានប្រវែងសរុប ៦ ៤០០ ម៉ែត្រ និងបន្តលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ដោយប្រើប្រាស់មូលនិធិសង្កាត់ និងគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍកសិកម្មខ្នាតតូចតំបន់ទន្លេសាប ដើម្បីលើកទិសដៅឱ្យប្រជាពលរដ្ឋងាយស្រួលការចរាចរ ចំណេញពេលវេលា និងកាត់បន្ថយចំណាយ និងបង្កើនការធ្វើកសិកម្មបានច្រើន មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ដើម្បីបង្កើនទិន្នផលស្រូវ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ល.រ | ប្រភេទផ្លូវ | ចំនួនខ្សែផ្លូវ | ប្រវែង (ម៉ែត្រ) |
|---|---|---|---|
| ១ | ផ្លូវចាក់កៅស៊ូ | ២ | ១១៥០១,៦៣ |
| ២ | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ៥៧ | ៧១៣៨៣,៧១ |
| ៣ | ផ្លូវដីស ឬផ្លូវរទេះ | ៨០ | ១០៤២០១,៧២ |
| ប្រវែងផ្លូវសរុប | | ១៤២ | ១៨៧០៨៧,០៦ |

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍


ប្រភេទផ្លូវកៅស៊ូក្នុងសង្កាត់ស្រយ៉ូវ


ប្រភេទផ្លូវគ្រួសក្រហមក្នុងសង្កាត់ស្រយ៉ូវ


ប្រភេទផ្លូវលំដីសក្នុងសង្កាត់ស្រយ៉ូវ

ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធ សង្កាត់ស្រយ៉ូវ



### ១.២.៤.បរិក្ខាសាធារណៈ

#### ក.ស្ថានភាពប្រើប្រាស់អគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី នៅក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ។

នៅសង្កាត់ស្រយ៉ូវ ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួនច្រើនជាងគេ ២០០៦ខ្នងផ្ទះ ស្មើនឹង ៤៩,៩ ភាគរយ អាគុយមានចំនួន ១ ០៥៧ ខ្នងផ្ទះ ស្មើនឹង ២៦,៣ ភាគរយ បន្ទះសូឡាមានចំនួន ៤១៦ខ្នងផ្ទះ ស្មើនឹង ១០,៣ ភាគរយ និងឡជីវឧស្ម័នមានចំនួនតិចជាងគេ ដែលមានចំនួន ០១ ខ្នងផ្ទះ។

ប្រជាជនដែលមិនមានអគ្គិសនីប្រើប្រាស់ ដោយសារភូមិខ្លះក្នុងសង្កាត់មានចម្ងាយឆ្ងាយពីបង្គោលបណ្តាញអគ្គិសនី ចំណែកប្រជាពលរដ្ឋមានចំនួនតិចតួច និងភូមិខ្លះទៀតមិនទាន់មានបណ្តាញអគ្គិសនីទៅដល់ ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| បរិយាយ | ២០១៦ភាគរយ | ២០១៧ | |
|---|---|---|---|
| | | ភាគរយ | ចំនួនផ្ទះ |
| ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី | ៤១,៣ | ៤៩,៩ | ២០០៦ |
| ផ្ទះបំភ្លឺដោយអាគុយ | ៣៧,៩ | ២៦,៣ | ១០៥៧ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ៨,៥ | ១០,៣ | ៤១៦ |
| ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | ០,២ | ០,០ | ១ |
| ផ្ទះមានទូរទស្សន៍ប្រើប្រាស់ | ៧៩,៥ | ៧៨,៨ | ៣១៦៩ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

#### ខ.ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឱ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹកស្ទឹង បឹង ត្រពាំង ឬអណ្តូងដៃងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាពនិងលើកស្ទួយអនាម័យនៅជនបទ។ នៅក្នុងសង្កាត់ប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាតមានចំនួន ៤ ២២៧គ្រួសារ ស្មើនឹង ៩៣,៧ភាគរយ ដែលនៅក្នុងនោះទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះមានចំនួន ៣ ១២៦ គ្រួសារ អណ្តូងជីកមានការការពារចំនួន ១ ០៧៩ គ្រួសារ និងទឹកភ្លៀងមានការការពារចំនួន ២១គ្រួសារ ចំណែកអណ្តូងជីកមិនមានការការពារចំនួន ៧២គ្រួសារ ស្មើនឹង ១,៦ ភាគរយ ស្រះចំនួន ៧១ គ្រួសារ ស្មើនឹង ១,៦ ភាគរយ និងទឹកពីប្រភពផ្សេងៗដូចជាស្ទឹង អូរ ត្រពាំង ចំនួន ១៤០ គ្រួសារ ស្មើនឹង ៣,១ ភាគរយ។

តារាង 21៖ ស្ថិតិអ្នកប្រើប្រាស់ការប្រើប្រាស់ទឹក

| បរិយាយ | | ២០១៦ | ២០១៧ |
|---|---|---|---|
| សរុបគ្រួសារមានទឹកស្អាតប្រើប្រាស់ | | ៤១៤០ | ៤២២៧ |
| ក្នុងនោះ | ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត | ០ | ១ |
| | ទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ | ៣០៦៤ | ៣១២៦ |
| | ទឹកអណ្តូងជីកមានការការពារ | ១០៧៦ | ១០៧៩ |

| | | | |
|---|---|---|---|
| | ទឹកភ្លៀងដែលមានការការពារ | ០ | ២១ |
| %គ្រួសារមានទឹកស្អាតប្រើប្រាស់ | | ៩២,៣ | ៩៣,៧ |
| ទឹកអណ្តូងជីកមិនមានការការពារ | | ៩៤ | ៧២ |
| %គ្រួសារប្រើប្រាស់ទឹកអណ្តូងជីកមិនមានការការពារ | | ២,១ | ១,៦ |
| ទឹកស្រះ | | ៣៦ | ៧១ |
| %គ្រួសាប្រើប្រាស់ទឹកស្រះ | | ០,៨ | ១,៦ |
| ទឹកពីប្រភពផ្សេងៗ(ទន្លេ ស្ទឹង អូរ ជ្រោះ) | | ២១៥ | ១៤០ |
| %គ្រួសារប្រើប្រាស់ទឹកពីប្រភពផ្សេងៗ(ទន្លេ ស្ទឹង អូរ ជ្រោះ) | | ៤,៨ | ៣,១ |

*ប្រភព៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែមេសា ឆ្នាំ២០១៨*

# ១.៣.ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១.ស្ថានភាពការកាន់កាប់ និងគ្រប់គ្រ

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញ សង្កាត់ស្រយ៉ូវ



ផែនទី ៥៖ ផែនទីប្រើប្រាស់ដីលម្អិត សង្កាត់ស្រយ៉ូវ



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន

| ប្រភេទដីប្រើប្រាស់ (ឈ្មោះហៅតាមបច្ចេកទេស) | បរិយាយ (ឈ្មោះហៅតាមអ្នកស្រុក) | ទំហំ (ហិកតា) | ភាគរយ |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **៥៤៦,៤៩** | **១,៩៣** |
| -ដីលំនៅឋាន ភូមិក្រៅតំបន់ការពារ ជុំវិញបឹងទន្លេសាប | ដីភូមិ | ១១២,៤៨ | ០,៤០ |
| -ដីលំនៅឋានភូមិក្នុងតំបន់១ ជុំវិញបឹងទន្លេសាប | ដីភូមិ | ៤១៤,៨២ | ១,៤៧ |
| -ដីលំនៅឋាន ភូមិក្នុងតំបន់២ ជុំវិញបឹងទន្លេសាប | ដីភូមិ | ១៧,០៦ | ០,០៦ |
| **ខ.ដីកសិកម្ម** | | **២៤ ០៤០,២៥** | **៨៥,០៨** |
| **ខ.១.ដីស្រែវស្សា** | | **៧២៩៥,២៤** | **២៥,៨១** |
| -ដីស្រែវស្សាក្រៅតំបន់ការពារ ជុំវិញបឹងទន្លេសាប | ដីស្រែ | ៤,៩២ | ០,០២ |
| -ដីស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប | ដីស្រែ | ២៩៥៧,៤៦ | ១០,៤៦ |
| -ដីស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប | ដីស្រែ | ៤៣៣២,៨៦ | ១៥,៣៣ |
| **ខ.២.ដីស្រែប្រាំង** | | **១៤២៦៦,៦១** | **៥០,៤៩** |
| -ដីស្រែប្រាំងក្នុងតំបន់១ ជុំវិញបឹងទន្លេសាប | ដីស្រែ | ៦,៨៨ | ០,០២ |
| -ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប | ដីស្រែ | ៩៧១០,៦៨ | ៣៤,៣៧ |
| -ដីស្រែប្រាំងក្នុងតំបន់៣ ជុំវិញបឹងទន្លេសាប | ដីស្រែ | ៤៥៤៩,០៦ | ១៦,១០ |
| **ខ.៣.ដីស្រែប្រាំងនិង ស្រែវស្សា** | | **២៤៦២,៩៣** | **៨,៧២** |
| -ដីស្រែប្រាំងនិង ស្រែវស្សាក្រៅតំបន់ការពារ ជុំវិញបឹងទន្លេសាប | ដីស្រែ | ៥៦៦,២៤ | ២ |
| -ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប | ដីស្រែ | ១៥១៧,២៣ | ៥,៣៧ |
| -ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប | ដីស្រែ | ៣៧៩,៤៦ | ១,៣៤ |
| **ខ.៤.ដីចម្ការស្រោចស្រព** | **ដីចម្ការ** | **១៦,៦៤** | **០,០៣** |
| **គ.ផ្ទៃទឹក និងខ្សែទឹក** | | **៣៦៦៩,២៨** | **១២,៩៩** |
| **គ.១.ស្ទឹងមានទឹកតាមរដូវ** | **ស្ទឹងសែន** | **២១៧,៥៦** | **០,៧៨** |
| **គ.២.បឹង** | **បឹង** | **៣៣៤,៥០** | **១,១៨** |
| **គ.៣.អាងស្តុកទឹក** | | **២៩៤៨,៣១** | **១០,៤៣** |
| -អាងស្តុកទឹកក្នុងតំបន់២ ជុំវិញបឹងទន្លេសាប | អាងស្តុកទឹក | ២១៨៥,៦៣ | ៧,៧៤ |
| -អាងស្តុកទឹកក្នុងតំបន់៣ ជុំវិញបឹងទន្លេសាប | អាងស្តុកទឹក | ៧៦២,៦៨ | ២,៧០ |
| **គ.៤.ស្រះ** | | **១៦៩,៨៣** | **០,៦០** |
| -ស្រះក្រៅតំបន់ការពារ ជុំវិញបឹងទន្លេសាប | ស្រះ | ១,០១ | ០,០០ |
| -ស្រះក្នុងតំបន់១ ជុំវិញបឹងទន្លេសាប | ស្រះ | ៥,៤៩ | ០,០២ |
| -ស្រះក្នុងតំបន់២ ជុំវិញបឹងទន្លេសាប | ស្រះ | ៩៨,៦៧ | ០,៣៥ |
| -ស្រះក្នុងតំបន់៣ ជុំវិញបឹងទន្លេសាប | ស្រះ | ៦៤,៦៦ | ០,២៣ |
| **ផ្ទៃដីសរុបក្នុងសង្កាត់** | | **២៨ ២៥៦,១៥** | **១០០** |

### ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

ដីលំនៅឋាន ភូមិ ជាដីដែលត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នៅពេលបច្ចុប្បន្នដីលំនៅឋាន ភូមិនៅក្នុងសង្កាត់ស្រយ៉ូវមានទំហំផ្ទៃដីសរុបចំនួន ៥៤៦,៥៩ហិកតា ភាគច្រើនស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦និងមានចំនួនតិចតួចស្ថិតនៅភាគខាងជើងផ្លូវជាតិ ដែលនៅក្នុងបច្ចុប្បន្ននេះ បាននិងកំពុងប្រើប្រាស់ជាដីលំនៅឋាន ភូមិ ហើយស្ថិតនៅតាម ០២ តំបន់ផ្សេងគ្នា គឺក្រៅតំបន់ការពារ តំបន់១ និងតំបន់២ ដូចមានរៀបរាប់ខាងក្រោម៖

**-ដីលំនៅឋាន ភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ដីលំនៅឋាន ភូមិ ក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានពីរកន្លែងផ្សេងគ្នា មានទំហំផ្ទៃដីសរុបចំនួន ១១២,៤៨ ហិកតា ក្នុងនោះមួយផ្នែកនៅខាងជើងផ្លូវជាតិលេខ៦ ចូលទៅក្នុងប្រមាណ ១,៥ គីឡូម៉ែត្រ មានភូមិ ០២ គឺភូមិប្រម៉ាត់ដី និងភូមិកំពង់សំរោង និងមួយផ្នែកទៀត ស្ថិតនៅតាមបណ្តោយខាងជើងជាប់ផ្លូវជាតិលេខ៦ ដែលមានចំនួន ០៣ ភូមិ គឺភូមិពុកយុក ភូមិត្រពាំងវែង និងភូមិពោសែនស្នាយ ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបមធ្យមមានប្រភេទដីកណ្តេងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌សលាយខ្មៅ និងដីពាយកណ្តុរពណ៌ខ្មៅ ដែលជាដីកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធបាន ៤០ ភាគរយ ហើយ ។

**-ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានពីរផ្នែក ទំហំផ្ទៃដីចំនួន ៤១៤,៨២ ហិកតា ក្នុងនោះមួយផ្នែកស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ ចូលទៅក្នុង ដែលមានចំនួន ០៨ ភូមិ គឺភូមិរកា ភូមិកំរែង ភូមិចំបក់ ភូមិម្នាវ ភូមិស្រយ៉ូវជើង ភូមិស្រយ៉ូវត្បូង ភូមិពោធិ៍តាអ៊ុន និងភូមិរលួស ព្រមទាំងមួយផ្នែកទៀត ស្ថិតនៅតាមបណ្តោយខាងត្បូងជាប់ផ្លូវជាតិលេខ៦ មានចំនួន ០៣ ភូមិ គឺភូមិពុកយុក ត្រពាំងវែង និងភូមិពោសែនស្នាយ ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបមធ្យមមានប្រភេទដីកណ្តេងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌សលាយខ្មៅ និងពាយកណ្តុរពណ៌ខ្មៅ គឺជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) ត្រូវបានចុះបញ្ជីជាលក្ខណៈប្រព័ន្ធបាន ៤០ ភាគរយ ហើយ ។

**-ដីលំនៅឋាន ភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ១៧,០៦ ហិកតា ស្ថិតនៅភាគខាងត្បូនៃសង្កាត់ នៅក្នុងភូមិរលួស ក្នុងនោះមួយផ្នែកខាងជើងនៃភូមិ ស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប និងមួយផ្នែកខាងត្បូងនៃភូមិ ស្ថិតនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប គឺជាដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ និងប្រផេះ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។ដីលំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាបនាពេលបច្ចុប្បន្នត្រូវបានប្រជាពលរដ្ឋ ប្រើប្រាស់សម្រាប់តាំងលំនៅឋានរស់នៅ ។

រូបភាព 5៖ លំនៅឋានភូមិ

| | | |
|---|---|---|
|  |  |  |
| លំនៅឋានភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | លំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | លំនៅឋានភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប |

## ខ.ដីកសិកម្ម

### ខ.១.ដីស្រែវស្សា

នាពេលបច្ចុប្បន្ននេះ ដីស្រែវស្សា នៅក្នុងសង្កាត់ស្រយ៉ូវមានទំហំផ្ទៃដីសរុបចំនួន ៧២៩៥,២៤ ហិកតា ភាគច្រើនស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦និងមានចំនួនតិចតួចស្ថិតនៅភាគខាងជើងផ្លូវជាតិ ដែលនៅក្នុងបច្ចុប្បន្ននេះ បាននិងកំពុងប្រើប្រាស់ជាដីស្រែវស្សា ហើយស្ថិតនៅតាម ០៣ តំបន់ផ្សេងគ្នា គឺក្រៅតំបន់ការពារ តំបន់១ និងតំបន់២ ដូចមានរៀបរាប់ខាងក្រោម៖

**-ដីស្រែវស្សាក្រៅតំបន់ការពារ ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ៤,៩២ ហិកតា ស្ថិតនៅភាគខាងជើងជាប់ផ្លូវជាតិលេខ៦។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានសង្កាត់នេះ ដីស្រែវស្សាទាំងនេះ ជាតំបន់ទំនាប មានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ និងប្រផេះ ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយកំពុងតែដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបាន ៤០ភាគរយ ។ ដីស្រែវស្សាទាំងនេះមានមួយផ្នែកស្ថិតនៅក្បែរៗជាប់នឹងដីលំនៅឋានភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋនៅក្នុងសង្កាត់តែងតែនាំគ្នាដាំដំណាំរួមផ្សំថែមទៀត រួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម ។ល។ ហើយដីនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត និងបឹងធំ។

**-ដីស្រែវស្សាក្នុងតំបន់១ ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ២ ៩៥៧,៤៦ហិកតា ដែលស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានសង្កាត់នេះ ដីស្រែវស្សាទាំងនេះ ជាតំបន់ទំនាប មានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ និងប្រផេះ ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយកំពុងតែដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ៤០ភាគរយ។ ដីស្រែវស្សាទាំងនេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋានភូមិ ក្រោយពីច្រូតកាត់ស្រូវរួចប្រជាពលរដ្ឋនៅក្នុងសង្កាត់ តែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀត ដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ល។ ហើយដីទាំងនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពុល បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត និងបឹងធំ។

**-ដីស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ៤ ៣៣២,៨៦ ហិកតា ស្ថិតនៅភាគខាងត្បូងសង្កាត់ចាប់ពីផ្លូវជាតិលេខ៦។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ នៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបមានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋ ពណ៌ស ខ្មៅ និងប្រផេះ គឺជាដីសាធារណៈរបស់រដ្ឋ ហើយមិនទាន់បានចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានប្រភពទឹកស្រោចស្រពមកពីទឹកភ្លៀង អូរក្អែកពល(អូរត្រពាំងវែង) អាងឯកជន(បាត់ពន្លាក) បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងត្រពាំងជម្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹលាក់ពាង បឹងជួន បឹងឈូកប្រដឺត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ បឹងតាលហាល បឹងស្នួងម៉ែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោតទំនប់សាប បឹងស្រះលោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្អា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យប្រា បឹងបែកចាន បឹងស្នោ និងបឹងតាឡក ។

រូបភាព 6៖ ដីស្រែវស្សា

|  |  |  |
|---|---|---|
| ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប |

## ខ.២.ដីស្រែប្រាំង

នាពេលបច្ចុប្បន្ននេះ ដីស្រែប្រាំងនៅក្នុងសង្កាត់ស្រយ៉ូវមានទំហំផ្ទៃដីសរុបចំនួន ១៤២៦៦,៦១ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦បន្តពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ដែលក្នុងបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំង ហើយស្ថិតនៅតាម ០៣តំបន់ការពារផ្សេងគ្នា គឺតំបន់១ តំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-ដីស្រែប្រាំងក្នុងតំបន់១ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាបស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦នៅក្នុងភូមិពុកយុក ដែលមានផ្ទៃដីចំនួន ៦,៨៨ ហិកតា។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ នៃរបាយការណ៍វិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាតំបន់ទំនាប មានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋ ពណ៌ស ខ្មៅ និងប្រផេះ គឺជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ ហើយបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបានចំនួន ៤០ ភាគរយហើយ ។ ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) អាងឯកជន (បាត់ពន្លាក) បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងត្រពាំងជម្រុក បឹងកូនក្អែក បឹងទឹកស្រាំ លាក់ពាង ជួន បឹងឈូកប្រដឺត បឹង

ឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ បឹងតាលហាល បឹងស្នួងម៉ែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត ទំនប់សាប បឹងស្រះលោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្នា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សមសាក់ជ័យប្រា បឹងបែកចាន បឹងស្នោ និងបឹងតាឡុក។

**- ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ដែលមានទំហំផ្ទៃដីសរុប ៩ ៧១០,៦៨ ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនៅក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបលិចទឹកនៅរដូវវស្សា មានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋ ពណ៌ស ខ្មៅ ប្រផេះក្លាម ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងអ្វីនោះឡើយ ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាបនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) អាងឯកជន (បាត់ពន្លាក) បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងត្រពាំងជង្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន ឈូកប្រជីត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ តាលហាល បឹងស្នួងម៉ែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះ លោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្នា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យប្រា បឹងបែកចាន បឹងស្នោ និងបឹងតាឡុក។

**-ដីស្រែប្រាំងក្នុងតំបន់៣ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់កាពារព្រៃលិចទឹក នៅភាគខាងត្បូងសង្កាត់មានផ្ទៃដីសរុបចំនួន ៤ ៥៤៩,០៦ ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ គឺជាតំបន់ទំនាបព្រៃលិចទឹកដែលមានប្រភេទដីកណ្តេងពណ៌ក្រម៉ៅ ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹកដែលហាមការកាប់រានដីការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀត។ នៅក្នុងករណីដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ពិតជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់ស្រយ៉ូវពិតមែនត្រូវស្នើសុំធ្វើការដោះស្រាយក្នុងការផ្តល់ដីស្រែក្នុងតំបន់នេះពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិតបទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឆ្វៀលដីនេះជូនមែន ក៏ដីនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរប្រជាជនគ្រាន់តែអាចមានសិទ្ធិអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល អាងឯកជនចំនួន១១ បឹងកុកទើតបឹងតាមប្រដើស (ក្នុងអាងក្រុមហ៊ុន) បឹងម៉ាឃាង (ក្នុងអាងពីរពាន់) បឹងសារាយក្នុង (ក្នុងអាងពីរពាន់) បឹងសារាយក្រៅ (ក្នុងអាងពីរពាន់) បឹងថ្លុកអញ្ចាញ (ក្នុងអាងពីរពាន់) បឹងអាខ្មាច (ក្នុងអាងពីរពាន់) បឹងកាឆឹងរលំពៅ (ក្នុងអាងពីរពាន់) បឹងថ្លុករ៉ែន (ក្នុងអាងពីរពាន់) អូរស្តីទឹម (ក្នុងអាងពីរពាន់) បឹងស្នែងក្របី បឹងផ្ទោល បឹងឈូកស បឹងលេងមាស បឹងចំរេះ បឹងអន្ទង់ បឹងបាក់សម បឹងក្បាលបី បឹងយាយឡាក់ បឹងក្រោម បឹងចំលាក់ បឹងក្រពើសារ បឹងឈ្មោះ បឹងក្រពើគោះ បឹងជំរុំបាតី បឹងថ្មល់ខ្សាច់ បឹងអាថ្ម បឹងតាព្រួច បឹងក្រាយ បឹងបាក់ដឹប និងបឹងភ៉ាន់។

រូបភាព 7៖ ដីស្រែប្រាំង

|  |  |  |
| --- | --- | --- |
| ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ដីស្រែវស្សាក្នុងតំបន់៣ជុំវិញបឹងទន្លេសាប |

### ខ.៣.ដីស្រែប្រាំងនិង ស្រែវស្សា

បច្ចុប្បន្ននេះ ដីស្រែប្រាំងនិងស្រែវស្សាក្នុងសង្កាត់ស្រយ៉ូវមានពីរកន្លែង ដែលមានទំហំផ្ទៃដីសរុបចំនួន ២ ៤៦២,៩៣ហិកតា នៅក្នុងនោះមួយកន្លែងស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ និងមួយកន្លែងទៀតស្ថិតនៅភាគខាងជើងផ្លូវជាតិ ដែលបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាដីស្រែប្រាំងនិងស្រែវស្សា ហើយស្ថិតនៅតាម ០៣ តំបន់ផ្សេងគ្នា គឺក្រៅតំបន់ការពារ តំបន់១ និងតំបន់២ ដូចមានរៀបរាប់ខាងក្រោម៖

**-ដីស្រែប្រាំង និងស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ៥៦៦,២៤ ហិកតា ស្ថិតនៅភាគខាងជើងចាប់ពីផ្លូវជាតិលេខ៦ ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវ នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំង និងស្រែវស្សាទាំងនេះ ជាតំបន់ទំនាប ដែលមានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ និងប្រផេះ ជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ និងត្រូវបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបាន៤០ភាគរយ។ ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត និងបឹងធំ។

**-ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ១ ៥១៧,២៣ ហិកតា ស្ថិតនៅខាងត្បូងចាប់ពីផ្លូវជាតិលេខ៦។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ គឺជាតំបន់ទំនាប ដែលមានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋ ពណ៌ស ខ្មៅ និងប្រផេះ ជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ និងបានកំពុងដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធបាន ៤០ភាគរយហើយ។ ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត និងបឹងធំ។

**-ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សានៅក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីសរុបចំនួន ៣៧៩,៤៦ ហិកតា ស្ថិតនៅភាគខាងត្បូងនៃសង្កាត់ក្នុងភូមិរលួស។ ផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងសង្កាត់ស្រយ៉ូវនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាតំបន់ទំនាបលិចទឹកតាមរដូវមានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌សខ្មៅនិងប្រផេះ ហើយជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) អាងទឹកឯកជន (បាត់ពន្លាក) បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងកំពង់ជង្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹង

លាក់ពាង បឹងជួន បឹងឈូកប្រដឹត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ បឹងតាលហាល បឹងស្នួងបែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះលោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្តា បឹងផ្គរលាន់ បឹងឃោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យប្រា បឹងបែកចាន បឹងស្នោ និងបឹងតាឡក។

រូបភាព ៨៖ ស្រែប្រាំង និងស្រែវស្សា

|  |  |  |
|---|---|---|
| ដីស្រែប្រាំង និងស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ដីស្រែប្រាំង និងស្រែវស្សាតំបន់២ជុំវិញបឹងទន្លេសាប |

## ខ.៨.ដីចម្ការស្រោចស្រព

នៅក្នុងសង្កាត់ស្រយ៉ូវមានដីចម្ការស្រោចស្រពស្ថិតនៅតាមដងស្ទឹងសែន ស្ថិតនៅចុងភាគខាងជើងនៃសង្កាត់ ដែលមានដំណាំ ដូចជា ពោត សណ្តែក ឪឡឹក និងបន្លែផ្សេងៗ ដោយពួកគាត់ធ្វើការដាំដុះបានតែនៅរដូវប្រាំងប៉ុណ្ណោះ ព្រោះនៅក្នុងរដូវវស្សាតំបន់ទាំងនេះរងការលិចទឹក ហើយទទួលបានការស្រោចស្រពពីប្រភពទឹកស្ទឹងសែន។ ដីចម្ការស្រោចស្រពក្នុងសង្កាត់ស្រយ៉ូវមានទំហំសរុប ១៦,៦៤ ហិកតា ត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋអាស្រ័យផលនៅលើដីចំណីស្ទឹង ដែលជាដីសាធារណៈរបស់រដ្ឋ ។

រូបភាព ៩៖ ដីចម្ការស្រោចស្រព



## គ.ផ្ទៃទឹក និងខ្សែទឹក

### គ.១.ស្ទឹងមានទឹកតាមរដូវ

នៅក្នុងសង្កាត់ស្រយ៉ូវមានស្ទឹងចំនួន ១ខ្សែ គឺស្ទឹងសែន ដែលមានទំហំផ្ទៃដីសរុបចំនួន ២១៧,៥៦ហិកតា ដែលជាដីសាធារណៈរបស់រដ្ឋ ជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀតរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ ព្រមទាំងជាប្រភពធនធានជលផលផងដែរ។ ស្ទឹងនេះហូរកាត់ភូមិចំនួន ៣ គឺភូមិប្រម៉ាត់ដី ភូមិកំពង់សំរោង និងភូមិពុកយុក ដែលផ្តល់ទឹកបានតែនៅក្នុងរដូវវស្សាប៉ុណ្ណោះ។

រូបភាព 10៖ ស្ទឹងសែន



### គ.២.បឹង

នៅសង្កាត់ស្រយ៉ូវមានបឹងចំនួន ៥៤ កន្លែង ដូចជា បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត បឹងធំ បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងគ្រួសក្រហម បឹងត្រពាំងជង្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន បឹងឈូកប្រជីត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ បឹងតាលហាល បឹងស្នួង បែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះ លោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្លា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យ បឹងប្រា បឹងបែកចាន បឹងស្នោ បឹងតាឡុក និងបឹងកណ្តឹង ដែលមានទំហំផ្ទៃដីសរុប ៣៣៤,៥០ ហិកតា ។ បឹងធម្មជាតិទាំងអស់នេះ ជាដីសាធារណៈរបស់រដ្ឋ បច្ចុប្បន្នត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសស្រែប្រាំង និងប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផងដែរ ។

រូបភាព 11៖ បឹង



គ.៣.អាងស្តុកទឹក

បច្ចុប្បន្នអាងស្តុកទឹកក្នុងសង្កាត់ស្រយ៉ូវមាន ២១កន្លែង ទំហំផ្ទៃដីសរុបចំនួន ២ ៩៤៨,៣១ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦នៅលាយឡំជាមួយនឹងដីស្រែដែលបច្ចុប្បន្ននេះបាននិងកំពុងប្រើប្រាស់ជាអាងស្តុកទឹក ហើយស្ថិតនៅតាម ០២តំបន់ផ្សេងគ្នា គឺតំបន់២ និងតំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានចំនួន ១៩កន្លែង មានផ្ទៃដីសរុប ២ ១៨៥,៦៣ហិកតា។ អាងស្តុកទឹកទាំងនេះ ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ហើយក្នុងបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ។

**-អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបមាន ០២ កន្លែង ទំហំផ្ទៃដីសរុបចំនួន ៧៦២,៦៨ ហិកតា។ អាងស្តុកទឹកនេះ ជាដីសាធារណៈរបស់រដ្ឋស្ថិតក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី និងការរំលោភកាន់កាប់អាងស្តុកទឹកទាំងនេះ ។

រូបភាព 12៖ អាងស្តុកទឹក



គ.៤.ស្រះ

បច្ចុប្បន្ននេះស្រះនៅក្នុងសង្កាត់ស្រយ៉ូវមាន៤៧កន្លែង និងមានទំហំផ្ទៃដីសរុបចំនួន ១៦៩,៨៣ហិកតា ភាគច្រើន ស្ថិតនៅលាយឡំជាមួយដីលំនៅឋាន និងមានតិចតួចនៅលាយឡំជាមួយនឹងដីស្រែ ដែលបច្ចុប្បន្នបាន និងកំពុងប្រើប្រាស់ជាស្រះទឹក ហើយស្ថិតនៅតាម ០៤តំបន់ផ្សេងគ្នា គឺក្រៅតំបន់ការពារ តំបន់១ តំបន់២ និង តំបន់៣ ដូចមានរៀបរាប់ខាងក្រោម៖

**-ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមាន ០៣ កន្លែង ទំហំផ្ទៃដីសរុបចំនួន ១,០១ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ និងភាគខាងកើតនៃសង្កាត់។ ស្រះទាំងអស់នេះ ជាដីឯកជន ដែលត្រូវបានកាន់កាប់ និងប្រើប្រាស់ដោយប្រជាពលរដ្ឋ ។ បច្ចុប្បន្នស្រះទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

**-ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានចំនួន ២៥ កន្លែង ទំហំផ្ទៃដីចំនួន ៥,៤៩ ហិកតា ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ ដែលស្រះទាំងអស់នេះ ជាដីឯកជនត្រូវបានកាន់កាប់និងប្រើប្រាស់ដោយប្រជាពលរដ្ឋ។ បច្ចុប្បន្នស្រះទាំងនេះ ប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតទៅតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

**-ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

នៅក្នុងសង្កាត់ស្រយ៉ូវមានស្រះ ១៣ កន្លែង ទំហំផ្ទៃដីសរុប ៩៨,៦៧ ហិកតា ស្ថិតនៅភាគខាងត្បូងនៃសង្កាត់ក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ នាពេលបច្ចុប្បន្នស្រះទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

**-ស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

សង្កាត់ស្រយ៉ូវមានស្រះ ០៧កន្លែង ទំហំផ្ទៃដីចំនួន ៦៤,៦៦ហិកតា ស្ថិតនៅចុងភាគខាងត្បូងនៃសង្កាត់ ជាដីសាធារណៈរបស់រដ្ឋស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលបច្ចុប្បន្នស្រះទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងជាប្រភពធនធានមច្ឆាជាតិ។

រូបភាព 13៖ ស្រះ


ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប


ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប


ស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាប

ពាក់ព័ន្ធបញ្ហាផ្សេងៗក្នុងការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ តាមរយៈការសម្ភាសន៍ក្រុមប្រឹក្សាសង្កាត់បានឱ្យដឹងថា មានប្រជាពលរដ្ឋក្នុងសង្កាត់ចំនួន ០៥ គ្រួសារ មិនមានដីសម្រាប់សាងសង់លំនៅឋាន និង ១០៣២ គ្រួសារមិនមានដីធ្វើកសិកម្មឡើយ។ នៅក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ រស់នៅលើដីកម្មសិទ្ធិរបស់គេផ្សេង ព្រមទាំងអ្នកមួយចំនួនទៀតរស់នៅជាមួយឪពុកម្តាយ។ ចំណែកបញ្ហាទំនាស់នៅក្នុងការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ទោះបីមិនទាន់ត្រូវបានចុះបញ្ជីកាន់កាប់ដីរួចរាល់ក៏ដោយ តែបញ្ហាដែលកើតឡើងមានទំនាស់តិចតួច ក្រុមប្រឹក្សាសង្កាត់អាចសម្របសម្រួល និងដោះស្រាយបាន។

### ១.៣.២.ផលិតកម្មកសិកម្ម

#### ក.ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងក្នុងសង្កាត់ស្រយ៉ូវបានផ្តោតសំខាន់ទៅលើផលិតកម្មដំណាំស្រូវហើយដំណាំនេះបានដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសង្កាត់ ដោយសារផលិតផលស្រូវ ក្រៅពីប្រជាពលរដ្ឋបានទុកផ្គត់ផ្គង់សម្រាប់ការហូបចុក និងមាននៅសល់បានទុកលក់ សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ។ ដំណាំស្រូវបានផលិតនៅលើផ្ទៃដីស្រែសរុបទំហំ ២៤ ០២៣,៦១ ហិកតា ដែលជាប្រភេទដីកណ្តៀងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ស លាយខ្មៅ នៅប៉ែកខាងជើងដែលបច្ចុប្បន្នធ្វើស្រែបានស្រែវស្សា និងស្រែប្រាំង ហើយនិយមប្រើពូជស្រូវ រាំងជ័យ(ស្រូវធ្ងន់) ស្រូវផ្កាខ្ញី(ស្រូវធ្ងន់) ស្រូវដំណើបនាងនក់ ស្រូវនាងអម(ស្រូវធ្ងន់) ស្រូវផ្ការំដួល(ស្រូវកណ្តាល) ស្រូវផ្កាម្លិះ (ស្រូវកណ្តាល) ស្រូវចង្វាយផ្តៅ(កណ្តាល) ស្រូវក្រឹម(ស្រូវកណ្តាល) ស្រូវ៥៤៥១(ស្រូវប្រាំង) ស្រូវសែនក្រអូប (ស្រូវប្រាំង) ព្រមទាំងមានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋ ពណ៌សខ្មៅប្រផេះនៅភាគកណ្តាលនៃសង្កាត់ ដែលអាចធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ គឺស្រែប្រាំងនិងស្រែវស្សា ហើយនិយមប្រើប្រាស់ពូជស្រូវពពាយ (ស្រូវធ្ងន់) ស្រូវបឹងកក (ស្រូវធ្ងន់) ស្រូវក្រឹមឡើងទឹក (ស្រូវធ្ងន់) ស្រូវក្រញូល (ស្រូវធ្ងន់) ស្រូវ៥៤៥១ (ស្រូវប្រាំង) ស្រូវ៥០៤ (ស្រូវប្រាំង) ស្រូវ៤៩(ស្រូវប្រាំង) និងស្រូវសែនក្រអូប(ស្រូវប្រាំង) ព្រមទាំងប្រភេទដីកណ្តៀងពណ៌ក្រម៉ៅល្បាប់ ដីពពាយកណ្តុរពណ៌ខ្មៅ ធ្វើស្រែបានពីរដងនៅក្នុងមួយឆ្នាំ គឺស្រែប្រាំងនិងស្រែវស្សា ហើយប្រើពូជស្រូវ៥៤៥១(ស្រូវប្រាំង) ស្រូវ៥០៤(ស្រូវប្រាំង) ស្រូវ៤៩(ស្រូវប្រាំង) ក្នុងការស្រោចស្រព សម្រាប់ដំណាំស្រូវនៅក្នុងសង្កាត់ស្រយ៉ូវត្រូវបានប្រើប្រាស់ទឹកពីប្រភពទឹកអូរក្អែកពល(អូរត្រពាំងវែង) បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត បឹងធំ អាងឯកជនចំនួន១(បាត់ពន្លាក) បឹងគ្រោះក្រោម បឹងឈូកច្បារបឹងគ្រោះកណ្តាល បឹងគ្រួសក្រជា បឹងត្រពាំងជង្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន បឹងឈូកប្រជីត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុងបឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្កេរ បឹងតាលហាល បឹងស្នួង បែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះលោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្តា បឹងផ្តូរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យ បឹងប្រា បឹងបែកចាន បឹងស្មោ បឹងតាឡុក ប្រឡាយកំពង់ពុទ្រា ប្រឡាយកំពង់សំរោង ប្រឡាយអូរដូនពៅ អូរក្អែកពល (អូរត្រពាំងវែង) អាងឯកជនចំនួន១១ បឹងកុកទើត បឹងរាំងទេរ បឹងតាមប្រដើស (ក្នុងអាងក្រុមហ៊ុន) បឹងម៉ាយាង (ក្នុងអាងពីរពាន់) បឹងសាវាយក្នុង (ក្នុងអាងពីរពាន់) បឹងសាវាយក្រៅ (ក្នុងអាងពីរពាន់) បឹងថ្លុកអញ្ចាញ (ក្នុងអាងពីរពាន់) បឹងអាខ្មាច (ក្នុងអាងពីរពាន់) បឹងកាធឹងរលំពៅ(ក្នុងអាងពីរពាន់) បឹងថ្លុករ៉ែន(ក្នុងអាងពីរពាន់) អូរស្ដីទឹម(ក្នុងអាងពីរពាន់) បឹងស្នែងក្របីបឹងថ្លោល បឹងឈូកស បឹងលេងមាស បឹងចំរេះ បឹងអន្ទង់ បឹងបាក់សម បឹងក្បាលបី បឹងយាយឡាក់ បឹងក្រោមចំលាក់ បឹងក្រពើសារ បឹងឈ្មោះ បឹងក្រពើគោះ បឹងជំរុំបាតី បឹងថ្មល់ខ្សាច់ បឹងអាថ្ម បឹងតាព្រួច បឹងក្រាយ បឹងបាក់ដឹប បឹងវ៉ាន់។ ជាទូទៅក្នុងសង្កាត់ស្រយ៉ូវ ប្រជាពលរដ្ឋបានទទួលផលស្រូវវស្សាជាមធ្យម ០,៥តោន/ហ.ត ស្រូវប្រាំងជាមធ្យម

៣,៥តោន/ហ.ត ហើយបានពិនិត្យឃើញថានៅក្នុងឆ្នាំ២០១៧នេះ នៅក្នុងសង្កាត់ទទួលបានផលស្រូវសរុបចំនួន ១៣ ២១៥ តោន ដែលក្នុងនោះផលស្រូវវស្សាមានចំនួន ២ ១៩០ តោន និងស្រូវប្រាំងចំនួន ១១ ០២៥ តោន ដោយនៅក្នុងនោះបានទុកសម្រាប់ហូបចុក ៣០ ភាគរយ ទុកពូជ ១០ ភាគរយ និងសល់ពីនេះបានលក់ចេញ ចំនួន ៧ ៩២៩តោន នៅក្នុងតម្លៃជាមធ្យម ៨៤១ រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ៦ ៥៨៤ លានរៀល។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ភាពរាំងស្ងួត<br>- សត្វល្អិតបំផ្លាញ និងជម្ងឺលើដំណាំស្រូវ<br>- ប្រើប្រាស់ពូជស្រូវតាមទម្លាប់<br>- ខ្វះបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម<br>- ខ្វះបច្ចេកទេសដាំ និងថែទាំដំណាំស្រូវ<br>- ប្រព័ន្ធប្រឡាយមានស្រាប់រងការខូចខាត (រាក់)<br>- ខ្វះខាតប្រព័ន្ធប្រឡាយនាំទឹកស្រោចស្រព<br>- ខ្វះកម្លាំងពលកម្ម(ចំណាកស្រុកច្រើន) | - ដីស្រែធំទូលាយរហូត៨៥ភាគរយ នៃផ្ទៃដីសរុប<br>- ស្ថានភាពដីស្រែជាវាលទំនាប អាចមានលទ្ធភាព នាំទឹកពីប្រភពទឹក បឹង អាង មកផ្គត់ផ្គង់ការ ស្រោចស្រព ដើម្បីធ្វើស្រែបង្កើនរដូវ២-៣ដងក្នុង មួយឆ្នាំបាន<br>- មានប្រព័ន្ធប្រឡាយស្រាប់<br>- មានកម្លាំងពលកម្មច្រើន<br>- មានគោលការណ៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិ បាលក្នុង ការពង្រឹងតួនាទីលើវិស័យកសិកម្ម<br>- មានគោលនយោបាយស្តីពីការជំរុញផលិតកម្ម ស្រូវ និងការនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។ |

### ខ.ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំនៅក្នុងសង្កាត់ស្រយ៉ូវបច្ចុប្បន្ន ប្រជាពលរដ្ឋបានដាំនៅលើផ្ទៃដី ១៦,៦៤ ហិកតា ដែលភាគច្រើននៅតាមបណ្តោយមាត់ស្ទឹង ជាប្រភេទដីល្បាប់ដែលមានជីជាតិ ហើយមានដំណាំដូចជា៖ ពោត សណ្តែក ស្ពៃ ត្រកួន ត្រសក់ ននោង និងល្ពៅ ។ល។ មិនតែប៉ុណ្ណោះដំណាំរួមផ្សំត្រូវបានដាំនៅជុំវិញលំនៅឋាន ជាលក្ខណៈគ្រួសារផងដែរ។ ដំណាំទាំងនេះទទួលបានការស្រោចស្រពពីស្ទឹងសែន អូរក្អែកពល(អូរត្រពាំងវែង) បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត បឹងធំនិងស្រះផងដែរ ហើយទិន្នផលដែលទទួលបានគ្រាន់សម្រាប់ ផ្គត់ផ្គង់ការហូបចុក និងលក់ដូរបានបន្តិចបន្តួច ដើម្បីបានកម្រៃខ្លះក្នុងការជួយបំពេញញការខ្វះខាតនៅក្នុងជីវភាព គ្រួសារតែប៉ុណ្ណោះ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - មានការកាប់ឈើសម្រាប់ធ្វើជាឧសដុត និងប្រើ ប្រាស់ផ្សេងៗ<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផល ប្រយោជន៍ នៃដើមឈើនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើមិនទាន់ពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយ | - មានច្បាប់ស្តីពីព្រៃឈើដែលបានកំណត់ ករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូល រួមដាំដើមឈើ<br>- មានការលើកទឹកចិត្តពីរាជរដ្ឋាភិបាលដល់ការចូល រួមដាំដើមឈើរបស់ប្រជាពលរដ្ឋ<br>- មានការផ្តល់នូវជំនួយបច្ចេកទេសដាំដើមឈើពី |

| | |
|---|---|
| | រដ្ឋបាលព្រៃឈើ។<br>- មានដីតាមដងផ្លូវសាធារណៈប្រព័ន្ធប្រឡាយ សាលារៀន មណ្ឌលសុខភាព វត្តអារាម តាមភូមិ ដែលអាចដាំដើមឈើបាន ។ |

គ.ផលិតកម្មឧស្សាហកម្ម

នៅក្នុងសង្កាត់ស្រយ៉ូវ ប្រជាពលរដ្ឋមិនបានធ្វើការដាំដុះដំណាំឧស្សាហកម្មនោះទេ ដោយសារតំបន់នេះជាតំបន់ទំនាបលិចទឹក ស្ថានភាពដីមិនសមស្របទៅនឹងដំណាំនេះទេ ។

១.៣.៣.ធនធានធម្មជាតិ

ក.ធនធានព្រៃឈើ

បច្ចុប្បន្ននេះនៅក្នុងសង្កាត់ស្រយ៉ូវមិនមានដីព្រៃឈើនោះទេ ប៉ុន្តែយើងសង្កេតឃើញថាមានដើមឈើដុះតិចតួចនៅតាមដីសាធារណៈ មានដូចជា នៅតាមដងផ្លូវជាតិលេខ៦ ផ្លូវផ្សេងៗ ទីធ្លាសាលារៀន ទីធ្លាវត្តអារាម តាមមាត់ស្ទឹង (ស្ទឹងសែន) និងតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបស័គ្គ | ឱកាស |
|---|---|
| - មានការកាប់បំផ្លាញឈើសម្រាប់ធ្វើឧសដុត និងប្រើប្រាស់ផ្សេងៗ<br>- មានការកាប់បំផ្លាញឈើដើម្បីយកដីកាន់កាប់<br>- ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃដើមឈើនៅមានកម្រិត<br>- ការអនុវត្តច្បាប់ព្រៃឈើនូវទាន់បានពេញលេញ<br>- ការផ្សព្វផ្សាយច្បាប់ពុំទាន់បានទូលំទូលាយនៅឡើយ | - មានច្បាប់និងអនុក្រឹត្យស្តីពីព្រៃឈើ<br>- មានដីព្រៃឈើធម្មជាតិ<br>- មានរដ្ឋបាលព្រៃឈើជាសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ |

ខ.ធនធានជលផល

បច្ចុប្បន្ននេះនៅក្នុងសង្កាត់ស្រយ៉ូវមានស្ទឹងចំនួន០១ គឺស្ទឹងសែន ទំហំផ្ទៃដីសរុប ២១៧,៥៦ ហិកតា បឹងចំនួន ១៧ មានដូចជា បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត បឹងធំ បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងគ្រួសក្រចា បឹងត្រពាំងជម្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន បឹងឈូកប្រដឹត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ បឹងតាលហាល បឹងស្នួង បែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះលោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្គា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យ បឹងប្រា បឹងបែកចាន បឹងស្នោ បឹងតាឡូក បឹងកុកទើត បឹងរាំងទេរ បឹងតាមប្រដើស (ក្នុងអាងក្រុមហ៊ុន) បឹងម៉ាឃាង(ក្នុងអាងពីរពាន់) បឹងសារាយក្នុង(ក្នុងអាងពីរពាន់) បឹងសារាយក្រៅ (ក្នុងអាងពីរពាន់) បឹងថ្លុកអញ្ចាញ(ក្នុងអាងពីរពាន់) បឹងអាខ្មាច(ក្នុងអាងពីរពាន់) បឹងកាផឹងរលំ៧(ក្នុងអាង

ពីរពាន់) បឹងថ្លុកវ៉ែន(ក្នុងអាងពីរពាន់) បឹងស្នែងក្របី បឹងផ្ទោល បឹងឈូកស បឹងលេងមាស បឹងចំរេះ បឹងអន្ទង់ បឹងបាក់សម បឹងក្បាលបី បឹងយាយឡាក់ បឹងក្រោមចំលាក់ បឹងក្រពើសារ បឹងឈ្មោះ បឹងក្រពើគោះ បឹងជំរុំបាតី បឹងថ្មល់ខ្សាច់ បឹងអាថ្ម បឹងតាព្រួច បឹងក្រាយ បឹងបាក់ដឹប និងបឹងវ៉ាន់ហើយភាគច្រើននៅប៉ែកខាងលិច និងខាងត្បូងនៃសង្កាត់ ក្នុងតំបន់ស្រែប្រាំង និងព្រៃលិចទឹកដែលមានផ្ទៃដីសរុបទំហំ ៣៣៤,៥០ ហិកតា ព្រមទាំងមានអាងស្តុកទឹកចំនួន ២១ កន្លែង ដូចជា អាងឯកជនបាត់ពន្លាក អាងពីរពាន់ និងអាងផ្សេងៗទៀត ដែលមានទំហំ ២ ៩៤៨,៣១ ហិកតា ព្រមទាំងស្រះទឹកចំនួន ២៧ កន្លែងស្ថិតនៅលាយឡំជាមួយដីលំនៅឋាន និងដីស្រែវស្សាភាគច្រើនស្ថិតនៅភាគខាងកើតនៃសង្កាត់ ដែលមានផ្ទៃដីទំហំសរុប ១៦៩,៨៣ ហិកតា។ ស្ទឹង បឹង អាងស្តុកទឹក និងស្រះទាំងអស់នេះមានធនធានជលផលជាច្រើនប្រភេទមាន ដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីអណ្តែង ត្រីក្រាញ់ ត្រីទីឡាបស្យា អន្ទង់ក្តាម ខ្យង កង្កែប អណ្តើក និងពស់ជាដើម។ល។ ហើយត្រូវបានធ្វើការនេសាទដោយប្រជាជនក្នុងសង្កាត់ជាលក្ខណៈគ្រួសារតាមរយៈការប្រើប្រាស់ឧបករណ៍ ដូចជា សំណាញ់ មុង ទ្រ អួន សន្ទូច ជាលក្ខណៈប្រពៃណី ដែលផលនេសាទទាំងនេះសម្រាប់តែការហូបចុក និងលក់ដូរតិចតួចប៉ុណ្ណោះ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបស័គ្គ | ឱកាស |
|---|---|
| - មានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនសមស្របលើដំណាំកសិកម្ម នាំឱ្យមានការថយចុះបរិមាណធនធានជលផល<br>- ការប្រើឧបករណ៍នេសាទខុសច្បាប់។ | - មានស្ទឹង បឹង អាងស្តុកទឹក ស្រះ និងស្រែ ដែលអំណោយផលដល់ធនធានជលផល<br>- មានច្បាប់ជលផល<br>- ប្រើប្រាស់ឧបករណ៍បែបប្រពៃណី ។ |

គ.ធនធានរ៉ែ

សង្កាត់ស្រយ៉ូវ មិនមានទិន្នន័យ ពីជំនាញពាក់ព័ន្ធអំណះអំណាងពីវត្តមានធនធានរ៉ែ នៅក្នុងសង្កាត់គួរឱ្យកត់សម្គាល់បាននោះទេ។

## ១.៤.ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១.ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

បច្ចុប្បន្ននៅក្នុងសង្កាត់ស្រយ៉ូវមានតែផលិតផលស្រូវ ដែលអាចនាំចេញទៅរកទីផ្សារ ហើយផលិតផលស្រូវដែលសល់ពីការហូបចុកអាចនាំទៅរកទីផ្សារមានប្រភេទស្រូវផ្ការំដួល និងពូជស្រូវ ៥៤ ៥១ ។ បើយោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្បេត្រ-បរិស្ថាននៅសង្កាត់ស្រយ៉ូវឆ្នាំ២០១៧ បានឱ្យដឹងថាប្រភេទស្រូវផ្ការំដួលមានទីផ្សារក្នុងប្រទេស និងទីផ្សារប្រទេសវៀតណាមដែលប្រជាពលរដ្ឋតែងលក់ស្រូវសើម ៥0ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ក្នុងសង្កាត់មានតម្លៃត្រឹម ១ ៣០០ រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវ ៥៤៥១ មានទីផ្សារក្នុងប្រទេស និងទីផ្សារប្រទេសប្រទេសវៀតណាមដូចគ្នាដែរ ប្រជាពលរដ្ឋតែងលក់ស្រូវសើម ៩០ ភាគរយតាមរយៈឈ្មួញមកទទួលទិញដល់ក្នុងសង្កាត់ដែរ មានតម្លៃ ៨០០ រៀលក្នុងមួយគីឡូក្រាម។

តារាង 27៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃជារៀល | ទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | ស្រូវផ្ការំដួល | ១ គ.ក្រ | ១៣០០ | | វៀតណាម |
| ២ | ស្រូវ( ៥៤៥១ ) | ១ គ.ក្រ | ៨០០ | | វៀតណាម |

## ១.៤.២.ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកសិកម្ម-បរិស្ថានសង្កាត់ស្រយ៉ូវឆ្នាំ ២០១៧ បានឱ្យដឹងថាបច្ចុប្បន្ននៅក្នុងសង្កាត់ស្រយ៉ូវ ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញគឺ ត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមនូវពូជស្រូវ ដែលភាគច្រើនរក្សាទុកដោយខ្លួនឯង ៥០ ភាគរយ និងមានការទិញចូល ១០ ភាគរយ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តរហូតដល់ ៩៥ ភាគរយ និងច្រូតកាត់ដោយដៃតែ ៥ ភាគរយ ប៉ុណ្ណោះ។ ផលស្រូវដែលទទួលបានត្រូវហាលសម្ងួតទុកពូជចំនួន ១០ ភាគរយ និងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ ២០ ភាគរយ ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ ៧០ ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងសង្កាត់បានតម្លៃ ១៥០០រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ទៅឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារនៅក្នុងប្រទេស និងទីផ្សារក្រៅប្រទេស។ តែចំពោះស្រូវ( ៥៤៥១ )វិញពូជត្រូវបានទិញពីគ្នាឯងនៅក្នុងសង្កាត់ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តទាំងអស់ ១០០ ភាគរយ ចំណែកផលស្រូវដែលទទួលបានត្រូវបានហាលសម្ងួតទុកពូជ ១០ ភាគរយ ចំណែកផលស្រូវនៅសើមដែលសល់ប្រមាណ ៩០ ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងសង្កាត់តម្លៃត្រឹមតែ ៧៦០ រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តយកទៅលក់ឱ្យទីផ្សារប្រទេសវៀតណាម ។

**គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងឃុំ និង ការប្រើប្រាស់**






### ១.៨.៣.ឧបសគ្គ និងឱកាស

តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ឈ្មួញជាអ្នកកំណត់តម្លៃស្រូវ<br>- ឈ្មួញកណ្តាលយកជី ថ្នាំ និងប្រេងមកបណ្តាក់ដោយគិតការប្រាក់ខ្ពស់រហូតដល់ ២ ភាគរយ ក្នុងមួយខែ ហើយទូទាត់នៅពេលប្រមូលផល<br>- កសិករប្រើពូជទុកខ្លួនឯងច្រើនជំនាន់<br>- ធាតុចូលកសិកម្មថ្លៃខ្ពស់<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជស្រូវវៀតណាម។ | - មានឈ្មួញមកទិញដល់កន្លែង<br>- មានភាពងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលស្រូវ<br>- អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់<br>- កែច្នៃចេញជាផលិតផលសម្រេច។ |

# ជំពូក២៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត

## ២.១.តម្រូវការសម្រាប់អនាគត

### ២.១.១.ផែនការអភិវឌ្ឍ សង្កាត់

ក.ផែនការអភិវឌ្ឍសង្កាត់៥ឆ្នាំ(២០១៨-២០២២)

ផែនការអភិវឌ្ឍសង្កាត់៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា តម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងសង្កាត់យ៉ាងមានប្រសិទ្ធិភាពតាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍសង្កាត់មួយ ដែលមានរយៈពេលប្រាំឆ្នាំសម្រាប់អណត្តិក្រុមប្រឹក្សាសង្កាត់។ តារាងក្របខ័ណ្ឌអភិវឌ្ឍសង្កាត់នេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍ ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បាន ការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឱ្យបាន ស្របតាមចក្ខុ វិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះក៏បានរំលេចឱ្យឃើញពីគោលបំណងអភិវឌ្ឍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាសង្កាត់ចង់បាន ព្រមទាំងគោលដៅអភិវឌ្ឍ ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បានតាមវិស័យនីមួយៗ។ទន្ទឹមនេះក៏បានរំលេចឱ្យឃើញនូវយុទ្ធសាស្ត្រអភិវឌ្ឍ ដែលជាការកំណត់នូវវិធីសាស្ត្រ ឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍនីមួយៗខាងលើ។

ចំណែកនៅសង្កាត់ស្រយ៉ូវ ក្រុមប្រឹក្សាសង្កាត់ក្នុងអាណត្តិ ២០១៨-២០២២ ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍសង្កាត់រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំទៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍសង្កាត់ដូចមានខ្លឹមសារ ដែលក្រុមការងាបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម

តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជំរើសនៃការប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍ | ប្រភពឯកសារ | គោលដៅនៃការអភិវឌ្ឍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍ | សកម្មភាពជា អាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -ប្រជាពលរដ្ឋក្នុងសង្កាត់មានផ្លូវធ្វើដំណើរស្រួលចាប់ពីឆ្នាំ២០១៨ | -កែលម្អរជួសជុលផ្លូវ និងដាក់លូបង្ហូរទឹក<br>-សាងសង់ផ្លូវថ្មីបន្ថែម | -សាងសង់ផ្លូវចាក់កៅស៊ូ<br>-ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>-ជួសជុលសាងសង់ស្ពាន<br>-ជួសជុលសាងសង់ផ្លូវលំដីស | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | -ស្តានិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗឡើងវិញ<br>-សាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីបន្ថែមទៀត | -ស្តារប្រឡាយស្រោចស្រព<br>-ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក<br>-ផ្តល់ម៉ាស៊ីនបូមទឹក<br>-ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ | |
| ៣.កម្រិតអប់រំមានគ្រប់កម្រិត និងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងសង្កាត់ | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -បង្កើនការចូលរៀនកុមារអាយុ ៣-៤ ឆ្នាំឱ្យបាន ៩០% នៅឆ្នាំ ២០១៨<br>-កុមារអាយុ ៦-១៤ ឆ្នាំបានរៀនបញ្ចប់នូវ | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឱ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជំរុញការយល់ដឹងដល់ឪពុកម្តាយកុមារពីតម្លៃសិក្សា | -បង្កើតថ្នាក់មត្តេយ្យ<br>-ផ្តល់គ្រូមត្តេយ្យ<br>-ផ្សព្វផ្សាយឱ្យឪពុកម្តាយនាំកូនចូលរៀន<br>-ផ្តល់សម្ភារៈសិក្សាដល់សិស្សក្រីក្រ | |

| | | | | | |
|---|---|---|---|---|---|
| | | កម្រិតមូលដ្ឋាន៩ឆ្នាំ<br>-ចំនួនអនក្ខរជននឹងថយនៅត្រឹម២% | -ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -ផ្តល់អាហាររូបករណ៍សិស្សក្រីក្រ<br>-អប់រំកុមារឱ្យយល់ដឹងពីតម្លៃនៃការសិក្សា<br>-បើកថ្នាក់អក្ខរកម្មឱ្យបានគ្រប់ភូមិ | |
| ៤.សុខភាពរបស់ប្រជាជនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -ធ្វើឱ្យប្រសើឡើងសុខភាព និងអនាម័យរបស់ប្រជាជនបានល្អ | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -ចាក់វ៉ាក់សាំងការពារជម្ងឺ០៧មុខ<br>-ផ្តល់ថ្នាំជាតិដែក<br>-សំណើរសុំគ្រូពេទ្យ និងថ្នាំ<br>-ជួសជុលជីកអណ្តូងទឹកស្អាត<br>-ធ្វើទស្សនកិច្ចសិក្សាយកបទពិសោធន៍ ពីកន្លែងផ្សេងៗ<br>-បណ្តុះបណ្តាលស្ត្រីមេម៉ាយក្រីក្រ<br>-បង្កើតជាសមាគមន៍ក្រុមចេះជួយខ្លួនឯង<br>-សាងសង់បង្គន់អនាម័យ<br>-អប់រំ និងផ្សព្វផ្សាយអំពីជម្ងឺឆ្លង ដូចជា របេង ថ្លើម គ្រុនចាញ់ និងគ្រុណឈាមជាដើម<br>-កម្មវិធីពន្យាកំណើត | |
| ៥.សង្កាត់មានបរិស្ថាន និងធនធានធម្មជាតិស្រស់បំព្រង | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិ | -បង្កើនសេវាលើការគ្រប់គ្រធនធានធម្មជាតិ និងបរិស្ថាន | -បណ្តុះបណ្តាលច្បាប់ការពារព្រៃសហគមន៍<br>-បណ្តុះបណ្តាលច្បាប់វុក្ខាប្រមាញ់ និងនេសាទត្រីខុសច្បាប់<br>-ដាំកូនឈើតាមទីសាធារណៈ<br>-ចិញ្ចឹមត្រីតាមគ្រួសារតាមគោលការណ៍ធម្មជាតិ | |
| ៦.សង្កាត់អាចផ្គត់ផ្គង់បាននូវតម្រូវការ ថាមពល | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -ប្រជាពលរដ្ឋនៅក្នុងចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | -លើកកម្ពស់ការយល់ដឹង ផ្នែកធនធាន ធម្មជាតិ និងបរិស្ថាន | -បច្ចេកទេសប្រើចង្រ្កាន ជីវឧស្ម័ន<br>-បច្ចេកទេសប្រើចង្រ្កានសន្សំខុស<br>-ផ្សព្វផ្សាយច្បាប់ការពារព្រៃឈើ | |
| ៧.ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត និងសុវត្ថិភាព | សាលាសង្កាត់ | -ភូមិសង្កាត់មានសន្តិសុខ និងសណ្តាប់ធ្នាប់ និងមានសុវត្ថិភាពល្អ | -ជំរុញពង្រីកការអនុវត្តគោលនយោបាយភូមិសង្កាត់មានសុវត្ថិភាព<br>-ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុមការពារភូមិ ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ភូមិ-សង្កាត់ | -បង្កើតប៉ុស្តិ៍ស្ម័យការពារតាមភូមិ<br>-បង្កើតក្រុមប្រជាជនការពារតាមភូមិ-សង្កាត់<br>-ផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗទៀត<br>-ចុះបញ្ជីអគ្រានុកូលដ្ឋានបានគ្រប់ៗគ្នា<br>-ផ្សព្វផ្សាយអប់រំក្រុមក្មេងទំនើង<br>-អប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន<br>-កាត់បន្ថយល្បែងស៊ីសង<br>-បំផុសឱ្យចូលរួមសហការណ៍ជាមួយសម្មកិច្ច | |
| ៨.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | សាលាសង្កាត់ | -មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីនិងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង | -ជំរុញឱ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់ | -ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ផ្សេងៗ | |

| | | | | | |
|---|---|---|---|---|---|
| | | | -បង្កើនការគ្រប់គ្រងដីឱ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -ជំរុញឱ្យប្រជាពលរដ្ឋធ្វើរបង និងព្រំដីឱ្យបានច្បាស់លាស់ | |
| ៩.ទិន្នផលកសិកម្មកើនឡើង | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -ធានាស្បៀងហូបគ្រប់គ្រាន់ | -បង្កើន ផលិតកសិកម្ម | -បង្កើនចំណេះដឹងបច្ចេកទេស ដាំដុះដល់កសិករ<br>-ផ្សព្វផ្សាយការប្រើប្រាស់ពូជផ្តល់ទិន្នផលខ្ពស់និងស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ<br>-បង្កើនប្រសិទ្ធភាពការប្រើប្រាស់គ្រឿងយន្តកសិកម្ម<br>-បង្កើនបច្ចេកទេសការគ្រប់គ្រងផលិតផលស្រូវមុននិងក្រោយពេលប្រមូលផល<br>-ជំរុញអនុវត្តប្រពលវប្បកម្មស្រូវ<br>-បណ្តុះបណ្តាលពីសាលារៀនទីផ្សាកសិក<br>-ផ្តល់ចំណេះដឹងពីការកែឆ្នៃវេចខ្ចប់ទុកដាក់ផលិតផល<br>-បង្កើនទំនាក់ទំនងព័ត៌មានទីផ្សាផលិតផល | |
| ១០.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់ | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០០៨-២០១២ | -ការរស់នៅមានអនាម័យតាមរយៈប្រើប្រាស់ទឹកស្អាត | -ពង្រីក និងកែលំអប្រភពផ្គត់ផ្គង់ទឹក | -ជីកអណ្តូងលូ ស្នប់<br>-ជួសជុលអណ្តូង<br>-បច្ចេកទេសចម្រោះទឹក | |
| ១១សមភាព និងសមធម៌ក្នុងការរស់នៅ | សៀវភៅផែនការអភិវឌ្ឍ សង្កាត់ ២០១៨-២០២២ | -ធ្វើឱ្យប្រសើរឡើងដល់ប្រជាជនគ្រប់រូបរស់នៅប្រកបដោយសមភាព សមធម៌ គោរពគ្នាទៅវិញទៅមក | -បង្កើនការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់មុខរបរ | -ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>-ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រីនិងកុមារ<br>-ពង្រឹងជនបង្គោលជាស្ត្រីតាមភូមិ<br>-ផ្សព្វផ្សាយច្បាប់កេងប្រវ័ញ្ចដល់កម្លាំងពលកម្មស្ត្រីនិងកុមារ<br>-បណ្តុះបណ្តាលពីតួនាទី យេនឌ័រ | |
| ១២.សត្វព្រៃមានការកើនឡើង | សាលាសង្កាត់ | -បង្កើនវិធានការការពារសត្វព្រៃ | -ជំរុញការផ្សព្វផ្សាយច្បាប់ និងពង្រឹងវិធានការទប់ស្កាត់<br>-សហការជាមួយស្ថាប័នពាក់ព័ន្ធ ពង្រឹងការការពារសត្វព្រៃ | -ដាក់ទោសឬផាកពិន័យអ្នកសម្លាប់សត្វព្រៃ<br>-ផ្សព្វផ្សាយច្បាប់ការពារសត្វព្រៃ | |
| ១៣.ទិន្នផលត្រីកើនឡើង | សាលាសង្កាត់ | -បង្កើនធនធានជលផល | -ជំរុញការបង្កើតវារីវប្បកម្ម | -បណ្តោះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ផ្តល់ឥណទាន<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>-បំរាមនេសាទនៅរដូវត្រីពង | |
| ១៤.គ្រួសារចិញ្ចឹមសត្វកើនឡើង | សាលាសង្កាត់ | -បង្កើនការចិញ្ចឹមសត្វបន្ថែមទៀត | -ជំរុញការផ្តល់បច្ចេកទេសកសិកម្ម<br>-ជំរុញការផ្តល់បច្ចេកទេសចិញ្ចឹម | -ចាក់វ៉ាក់សាំងការពារជម្ងឺគោក្របីឱ្យបានទៀងទាត់<br>-ផ្តល់ឥណទានគោក្របី<br>-ផ្តល់ឥណទានមានការប្រាក់ទាប | |

| | | | | | |
|---|---|---|---|---|---|
| | | | ថែទាំសុខភាពសត្វ និងជ្រើសរើសពូជ | | |
| ១៥.កាត់បន្ថយមរណៈមាតា និងទារកក្រោយសម្រាល | សាលាសង្កាត់ | -បង្កើនការលុបបំបាត់អត្រាស្លាប់មាតា និងទារកក្រោយសម្រាល | -ពង្រឹងនិងពង្រីកការផ្តល់សេវាគាំពារសុខភាពមាតា និងទារក | -ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឱ្យទៅសម្រាលកូនដោយពេទ្យឆ្មប<br>-អប់រំឱ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍<br>-មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍<br>-ជំរុញឱ្យស្ត្រីមានផ្ទៃពោះទៅពិនិត្យពោះនៅមណ្ឌលសុខភាព<br>-ជំរុញឪពុកម្ដាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ០៧មុខ | |
| ១៦.ឱ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ | សាលាសង្កាត់ | -ទូទាំងសង្កាត់មានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ | -ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញជំរុញការផ្គត់ផ្គង់ថាមពលអគ្គិសនី | -រៀបចំបណ្ដាញអគ្គិសនីតាមភូមិ | |

ប្រភព៖ *ផែនការអភិវឌ្ឍសង្កាត់៥ឆ្នាំ(២០១៨-២០៣២) និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែកញ្ញា ឆ្នាំ២០១៨*

## ខ.គម្រោងអភិវឌ្ឍផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងសង្កាត់ស្រយ៉ូវបច្ចុប្បន្ននេះមិនមានគម្រោងអភិវឌ្ឍណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍសង្កាត់ឡើយ

ផែនទី ១៖ ផែនទីគម្រោងអាទិភាពសង្កាត់ស្រយ៉ូវ



### ២.១.២.ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន គឺជាចំនុចសំខាន់ណាស់ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជននៅក្នុងសង្កាត់នេះក្នុងរយៈពេល ១៥ឆ្នាំ ខាងមុខដ៏វែង អត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ បានបង្ហាញក្នុងជំពូក១ បានឱ្យដឹងគឺ ១,១០ភាគរយ ដូច្នេះប្រជាពលរដ្ឋនៅក្នុងសង្កាត់នឹងមានការកើនឡើងរហូតទៅដល់ឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ២១០០៦នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំៈ ១,១០%

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំៈ ២១០០៦នាក់ x ១,១០% = ២៣១ នាក់/ឆ្នាំ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងបានៈ ២៣១នាក់/ឆ្នាំ x ១៥ ឆ្នាំ = ៣៤៦៥នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខមានៈ ២១ ០០៦នាក់ + ៣៤៦៥នាក់ = ២៤៤៦៩នាក់**

ចំណែកចំនួនគ្រួសារនៅក្នុងសង្កាត់ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ២១ ០០៦ នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ ២០១៧ គឺ ៤ ៥១០ គ្រួសារ

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ ២០១៧ គឺៈ

**២១០០៦នាក់ /៤៥១០គ្រួសារ = ៤,៦៥ នាក់/គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៣៤៦៥នាក់/ ៤,៦៥នាក់/គ្រួសារ = ៧៤៥ គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមានៈ

**៤៥១០គ្រួសារ + ៧៤៥ គ្រួសារ = ៥២៥៥ គ្រួសារ**

តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ៤៥១០ | ២១០០៦ | ១០៩៣៧ |
| ២០២២ | ៤៧៦៤ | ២២១៦០ | ១១៥៣៨ |
| ២០២៧ | ៥០១៧ | ២៣៣១៥ | ១២១៣៩ |
| ២០៣២ | ៥២៥៥ | ២៤៤៧១ | ១២៧៤០ |

☞ចំណាំ៖

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំxចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំx១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ+ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០-២ឆ្នាំ | ៦៣៤ | ៣២៩ | ៦៦៩ | ៣៤៧ | ៧០៤ | ៣៦៥ | ៧៣៩ | ៣៨៣ |
| អាយុពី៣-៤ | ៨៧៦ | ៥៣៧ | ៩២៤ | ៥៦៧ | ៩៧២ | ៥៩៦ | ១,០២១ | ៦២៦ |
| អាយុ៥ឆ្នាំ | ៥៦១ | ២៨២ | ៥៩២ | ២៩៧ | ៦២៣ | ៣១៣ | ៦៥៣ | ៣២៨ |
| អាយុ៦-១១ឆ្នាំ | ១,៧៩៧ | ៩៤៤ | ១,៨៩៦ | ៩៩៦ | ១,៩៩៥ | ១,០៤៨ | ២,០៩៣ | ១,១០០ |
| អាយុ១២-១៤ឆ្នាំ | ១២៣៧ | ៦៨៣ | ១,៣០៥ | ៧២១ | ១,៣៧៣ | ៧៥៨ | ១,៤៤១ | ៧៩៦ |
| អាយុ១៥-១៧ឆ្នាំ | ១,៥២៣ | ៨៧៩ | ១,៦០៧ | ៩២៧ | ១,៦៩០ | ៩៧៦ | ១,៧៧៤ | ១,០២៤ |
| អាយុ១៨-២៤ឆ្នាំ | ២,៤០១ | ១,២២៨ | ២,៥៣៣ | ១,២៩៥ | ២,៦៦៥ | ១,៣៦៣ | ២,៧៩៧ | ១,៤៣០ |
| អាយុ២៥-៦០ឆ្នាំ | ៨,១៥៧ | ៤,០៧៩ | ៨,៦០៥ | ៤,៣០៣ | ៩,០៥៤ | ៤,៥២៧ | ៩,៥០២ | ៤,៧៥២ |
| អាយុ៦១ឆ្នាំ | ៣,៨២០ | ១,៩៧៦ | ៤,០៣០ | ២,០៨៥ | ៤,២៤០ | ២,១៩៣ | ៤,៤៥០ | ២,៣០២ |
| ប្រជាជនសរុប | ២១,០០៦ | ១០,៩៣៧ | ២២,១៦០ | ១១,៥៣៨ | ២៣,៣១៥ | ១២,១៣៩ | ២៤,៤៦៩ | ១២,៧៤០ |
| ចំនួនគ្រួសារ | ៤ ៥១០ | | ៤ ៧៦៤ | | ៥ ០១៧ | | ៥ ២៥៥ | |

## ២.១.៣.តម្រូវការដីធ្លីជាមូលដ្ឋាន

### ក.ដីលំនៅឋាន

ចំពោះដីភូមិសំដៅទៅលើដីសម្រាប់សាងសង់ផ្ទះនិងសម្រាប់សួនដំណាំជុំវិញផ្ទះតាមគ្រួសារ។ នៅក្នុងឆ្នាំ ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ៥៤៤,៣១ ហិកតា និងមានគ្រួសារសរុបចំនួន ៤ ៥១០ គ្រួសារ គឺជាស្ថានភាពរស់នៅរបស់ប្រជាជន ដែលមានភាពសមស្របមិនមានបញ្ហាពីការខ្វះដី សម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូច គឺស្មើចំនួន ០៥ គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្ននេះ គ្រួសារទាំងនោះកំពុងរស់នៅលើដីចំណីប្រឡាយ ជាដីសាធារណៈ និងគ្រួសារមួយចំនួនទៀតកំពុងតែរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច ១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវធ្វើការយកចិត្តទុកដាក់ដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ច មាននៅទីតាំងក្រៅសង្កាត់តាមការសម្រេចរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ច ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

**៥៤៤,៣១ ហិកតា/ ៤៥១០គ្រួសារ = ០,១២ហិកតា/ គ្រួសារ**

តែបើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីលំនៅឋាន យ៉ាងច្រើន ០,២៥ ហិកតា ក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ៥ គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់លំនៅឋានដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមាននៅទីតាំងផ្សេងពីសង្កាត់នេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងចំនួនៈ ៧៤៥ នាក់

-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារមានៈ ៤,៦៥ នាក់/គ្រួសារ

-តម្រូវការដីលំនៅឋានក្នុង១គ្រួសារមានចំនួន០,១២ ហិកតា/ គ្រួសារ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបានៈ

**៣៤៦៥នាក់/ ៤,៦៥នាក់/គ្រួសារ = ៧៤៥ គ្រួសារ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីលំនៅឋានត្រូវកើនឡើងៈ**

**៧៤៥គ្រួសារ x 0,១២ហិកតា/គ្រួសារ = ៨៩,៤ហិកតា**

**-ដូច្នេះរហូតដល់ឆ្នាំ ២០៣២ ដីលំនៅឋាននៅក្នុងសង្កាត់ស្រយ៉ូវ ត្រូវកើនឡើងដល់ៈ**

**៥៤៤,៣១ ហិកតា + ៨៩,៤ ហិកតា = ៦៣៣,៧១ហិកតា**

-ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន ៥ គ្រួសារតាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ **៥ គ្រួសារ x 0,២៥ ហិកតា/គ្រួសារ = ១,២៥ ហិកតា**

ខ.ដីកសិកម្ម

ចំពោះដីកសិកម្មសំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចម្ការដំណាំ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ ២៤ 0២៥,១៩ ហិកតា និងមានគ្រួសារសរុបចំនួន ៤៥១០ គ្រួសារអាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះសម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាព គឺជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបានលើកលែងតែគ្រួសារចំនួន ១ 0៣២ គ្រួសារ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួនៈ

**២៤ 0២៥,១៩ ហិកតា / ៤ ៥១០ គ្រួសារ = ៥,៣២ ហិកតា/ គ្រួសារ**

តែបើយោងតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ ហិកតា ក្នុង១គ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ១ 0៣២ គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារដើម្បីអាចទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមាននៅទីតាំងផ្សេងពីសង្កាត់ស្រយ៉ូវនេះ។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ ៧៤៥ គ្រួសារ

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ**

**៧៤៥ គ្រួសារ x ៥,៣២ ហិកតា/គ្រួសារ = ៣ ៩៦៣,៤ ហិកតា**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ**

**២៤ 0២៥,១៩ ហិកតា + ៣ ៩៦៣,៤ ហិកតា = ២៧ ៩៨៨,៥៩ ហិកតា**

-ចំណែកការដោះស្រាយដីកសិកម្មជូនគ្រួសារ ដែលគ្មានដីពិតប្រាកដចំនួនសរុប ១៦៩គ្រួសារ តាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ **១ 0៣២ គ្រួសារ x ២ ហិកតា/គ្រួសារ = ២ 0៦៤ ហិកតា**

គ.ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដែលមានដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោលឧស និងអនុផលនានាមានជ័រ វល្លិ ឱសថ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទតាមរយៈការប្រើប្រាស់ដោយផ្ទាល់ឬតាមរយៈការលក់ដូរ។ ទន្ទឹមនឹងនេះព្រៃឈើក៏បានដើរតួយ៉ាងសំខាន់ក្នុងចំណោមតួនាទីដទៃទៀត ដូចជា ការទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ (ផ្តល់ខ្យល់អាកាសបរិសុទ្ធ) បញ្ចេញឧស្ម័នអុកស៊ីសែន (ជួយស្រូបឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះធម្មជាតិ

(ជួយទប់ទល់នឹងខ្យល់ព្យុះ ទឹកជំនន់ ជួយការពារការហូរច្រោះដី និងបាក់ដី)ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ។ ចំណែកព្រៃលិចទឹកសាបជា ជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ...។

នាពេលអនាគត នៅក្នុងសង្កាត់ស្រយ៉ូវមិនមានតម្រូវការដីបន្ថែម សម្រាប់ព្រៃឈើនោះទេ តែក្នុងសង្កាត់មានលទ្ធភាពក្នុងការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗតាមដូចជាតាមដងផ្លូវ ប្រឡាយទឹក អាងស្តុកទឹក សាលាសង្កាត់ សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាមជាដើម សម្រាប់ផ្តល់ផលជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន ស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ។ល។

### ឃ.ធនធានទឹក

សង្កាត់ស្រយ៉ូវ ជាសង្កាត់មានសក្តានុពលទៅលើផ្នែកសិកម្ម ដំណាំស្រូវ និងចម្ការដំណាំរួមផ្សំ ដែលនាំឱ្យសង្កាត់ស្រយ៉ូវ មានគោលដៅអភិវឌ្ឍរយៈពេលវែងរបស់ខ្លួនផ្តោតសំខាន់លើកសិកម្មដំណាំស្រូវ និងចម្ការដំណាំរួមផ្សំទាំងនេះមិនអាចគេចចេញបានឡើយ។ ដូច្នេះ ដើម្បីជំរុញវិស័យកសិកម្មដំណាំស្រូវ កត្តាចាំបាច់មួយក្នុងចំណោមកត្តាជាច្រើនគឺមានកត្តាទឹកជាកត្តាសំខាន់ដែរដែលត្រូវយកចិត្តទុកដាក់ដោយ ត្រូវធ្វើយ៉ាងណាឱ្យមានទឹកគ្រប់គ្រាន់ សម្រាប់ការស្រោចស្រពបានគ្រប់រដូវកាលទៅលើដីស្រែ និងចម្ការដែលសង្កាត់មាន ដើម្បីដោះស្រាយទឹកពេលមានគ្រោះរាំងស្ងួតនិងធ្វើស្រែបង្កើនរដូវឱ្យទទួលបានផលិតភាពខ្ពស់ជួយផ្គត់ផ្គង់ទៅដល់ការហូបចុក និងជំរុញក្នុងការនាំចេញបង្កើនសេដ្ឋកិច្ចគ្រួសារក៏ដូចសេដ្ឋកិច្ចជាតិ ដើម្បីឆ្លើយតបបានទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។ ដូច្នេះនាពេលអនាគតនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខ សង្កាត់ស្រយ៉ូវនឹងមិនមានតម្រូវការដីសម្រាប់ការរៀបចំអាងស្តុកទឹកបន្ថែមនោះទេ គឺមានត្រឹមតែធ្វើការស្តាប្រព័ន្ធប្រឡាយបង្ហូរទឹកដែលមានស្រាប់ចំនួន ១០ខ្សែ ប្រវែង ១៤ ៩០៧,៣៣ ម៉ែត្រប៉ុណ្ណោះ ដែលក្នុងនោះមានប្រឡាយមេ ២ខ្សែ ប្រវែង ១៩ ២២១ ម៉ែត្រ។ ប្រឡាយរង ២ខ្សែ ប្រវែង ៤ ១៥១ ម៉ែត្រ និងប្រឡាយតូចៗ ៦ខ្សែ ប្រវែង ១៤ ៩០៧ម៉ែត្រ និងស្ពានស្ទឹង ០១កន្លែង ទំហំផ្ទៃដី ៦៥,៧០ហិកតា បន្ថែមលើប្រព័ន្ធស្រោចស្រពដែលមានស្រាប់ សម្រាប់ស្រោចស្រពដំណាំស្រូវនៅរដូវប្រាំង និងពេលមានគ្រោះរាំងស្ងួត ហើយក៏អាចជាជម្រកត្រីនាំឱ្យកើនឡើងបរិមាណត្រីបូកផ្សំជាមួយការយកចិត្តទុកដាក់នៅក្នុងការចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារលាយឡំជាមួយបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែដែលជាទម្រង់មួយនៃវារីវប្បកម្ម គឺជាបច្ចេកទេសមួយជួយ ដើម្បីបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលស្រូវផង ដែលអាចផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋក្នុងសង្កាត់គួរទទួលបាននូវអាហារ សម្រាប់ទ្រទ្រង់សុខភាព និងជីវិតរស់នៅអោយមានភាពល្អប្រសើរ។

### ង.ហេដ្ឋារចនាសម្ព័ន្ធសង្គម និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

### ង.១.វិស័យអប់រំ

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ យ៉ាងណាមិញនៅក្នុងសង្កាត់ស្រយ៉ូវទៅថ្ងៃអនាគតក្នុងរយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចដែលមានការគណនាក្នុងចំណុច

២.១.២ ស្ដីពីចំណោលប្រជាសាស្ត្រខាងលើដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែមគ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន។

❖ **មត្តេយ្យសិក្សា:**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ១ ៦៧៤ នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ ៥០នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ**

**១ ៦៧៤ នាក់ /៥០ នាក់/បន្ទប់= ៣៣ បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៣៣ បន្ទប់ / ៥ បន្ទប់/អគារ= ៧ អគារ**

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ២០៩៣នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ**

**២០៩៣នាក់ ៖ ៤៥នាក់/បន្ទប់ = ៤៧បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ**

**៤៧បន្ទប់ ៖ ៦ បន្ទប់/អគារ = ៨ អគារ**

-តែក្នុងករណីត្រូវរៀន**២**វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាវេតែចំនួនៈ

**៨អគារ/វេន ៖ ២ វេន = ៤អគារ**

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ១ ៤៤១នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១ ៤៤១នាក់ ៖ ៤៥នាក់/បន្ទប់ = ៣២ បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៣២ បន្ទប់ ៖ ១២បន្ទប់/អគារ = ៣អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាវេតែចំនួនៈ

**៣អគារ / វេន ៖ ២ វេន = ១,៥ អគារ**

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៧៧៤ នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

១ ៧៧៤ នាក់ ៖ ៤៥នាក់/**បន្ទប់ = ៣៩ បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៣៩ បន្ទប់ ៖ ១២បន្ទប់/អគារ = ៣ អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

**៣ អគារ / វេន ៖ ២ វេន = ១,៥អគារ**

តារាង 32៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលារៀននៅឆ្នាំ ២០១៨ ដល់ឆ្នាំ ២០៣២

| បរិយាយ | បច្ចុប្បន្ន២០១៧ | អនាគត ២០៣២ | បម្រែបម្រួល |
|---|---|---|---|
| សាលាមត្តេយ្យ | | | |
| សិស្ស | ២៧៥នាក់ | ១ ៦៧៤ នាក់ | ១ ៣៩៩នាក់ |
| បន្ទប់ | ៨ បន្ទប់ | ៣៣បន្ទប់ | ២៥ បន្ទប់ |
| អគារ | ៨ អគារ | ៧ អគារ | -១អគារ |
| សាលាបឋមសិក្សា | | | |
| សិស្ស | ២៩៩៥នាក់ | ២០៩៣នាក់ | -៩០២នាក់ |
| បន្ទប់ | ៤៧ បន្ទប់ | ៤៧បន្ទប់ | 0 |
| អគារ | ១១អគារ | ៨ អគារ | -៣អគារ |
| អនុវិទ្យាល័យ | | | |
| សិស្ស | 0 | ១ ៤៤១ នាក់ | ១ ៤៤១ នាក់ |
| បន្ទប់ | 0 | ៣២បន្ទប់ | ៣២បន្ទប់ |
| អគារ | 0 | ៣ អគារ | ៣ អគារ |
| វិទ្យាល័យ | | | |
| សិស្ស | ១១២៧នាក់ | ១ ៧៧៤ នាក់ | ៦៤៧ នាក់ |
| បន្ទប់ | ២១បន្ទប់ | ៣៩ បន្ទប់ | ១៨ បន្ទប់ |
| អគារ | ១អគារ | ៣ អគារ | ២ អគារ |

## ង.២.វិស័យសុខាភិបាល

បើយោងទៅតាមការស្រាវជ្រាវរកឃើញដែលបានរៀបរាប់ក្នុងជំពូកទី ១ នៃរបាយការណ៍នេះបានឱ្យដឹងថា នៅក្នុងសង្កាត់ស្រយ៉ូវមានមណ្ឌលសុខភាពមួយកន្លែង ដែលមានលទ្ធភាពផ្តល់សេវាកម្មនៅក្នុងការព្យាបាលជូនប្រជាពលរដ្ឋនៅក្នុងសង្កាត់សមស្របរួចហើយ ដែលទៅថ្ងៃអនាគត១៥ឆ្នាំទៅមុខនឹងមិនមានតម្រូវការដីសម្រាប់រៀបចំទីតាំងផ្តល់សេវាកម្មសុខាភិបាលបន្ថែមនោះទេ ដោយគ្រាន់តែធ្វើការជំរុញការផ្តល់សេវាពីមណ្ឌលសុខភាពដែលមានស្រាប់មួយនេះ ដើម្បីបម្រើជូនដល់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ឱ្យបានប្រសើរឡើងតែប៉ុណ្ណោះ ហើយក៏នឹងអាចផ្តល់លទ្ធភាពឱ្យមានគ្លីនិចឯកជនបំពេញបន្ថែមទៀតផងដែរ។

## ង.៣.អគ្គិសនី

អគ្គិសនីមានសារៈសំខាន់ណាស់ សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីបានផ្តល់ឱ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសម្បូររុងរឿង ដូចជា ជួយដោះស្រាយបញ្ហា និងធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកម្សាន្តផងដែរ។ ចំពោះស្ថានភាពការប្រើប្រាស់អគ្គិសនីនៅក្នុងសង្កាត់ស្រយ៉ូវក្នុងបច្ចុប្បន្ននេះមាន

ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន ២០០៦ ខ្នងផ្ទះ ស្មើនឹង ៤៩,៩ ភាគរយ អាគុយមានចំនួន ១ ០៥៧ ខ្នងផ្ទះ ស្មើនឹង ២៦,៣ ភាគរយ បន្ទះសូឡាមានចំនួន ៤១៦ខ្នងផ្ទះ ស្មើនឹង ១០,៣ ភាគរយ និងឡជីវឧស្ម័នមានចំនួនតិចជាងគេ ដែលមានចំនួន០១ ខ្នងផ្ទះ។ ដូច្នេះនៅពេលអនាគត១៥ឆ្នាំទៅមុខនឹងមានការកើនឡើងចំនួនគ្រួសារថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនីតភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់។

### ង.៤.ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលត្រូវគេបានបោះបង់ចោល វាមានពីរបែប គឺកាកសំណល់រឹង និងរាវ។ ដូច្នេះសំរាមគឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងជាការបង្កើតកន្លែងគរមួយផ្សេងទៀតប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ គំនរសំរាមកើតចេញមកពីកាកសំណល់ផ្ទះបាយដែលដាក់លាយឡំចូលគ្នាជាមួយនឹងអំបែងកែវ អំបែងចាន និងអំបែងដបជាដើម។ នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាងឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាច១ ដែលនៅពេលនោះ មានលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត។

ចំពោះសំរាមនៅក្នុងសង្កាត់ស្រយ៉ូវបច្ចុប្បន្ននេះ ប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិសង្កាត់។ ដើម្បីអាចគ្រប់គ្រងសំរាមបាន សង្កាត់ត្រូវរកដីដែលមានទីតាំងសមស្របនៅក្នុងសង្កាត់ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើទីលានចាក់សំរាមមួយកន្លែង ដើម្បីប្រមូលសំរាមដែលមាននៅក្នុងសង្កាត់ទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទីកយកទៅកែច្នៃផលិតវាឡើងវិញ ចំណែកសំរាមពីផ្ទះបាយនិងស្លឹកឈើផ្សេងពីប្លាស្ទីកអាចកែច្នៃធ្វើជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់ក្នុងការបង្កើនគុណភាពដីដាំដុះ។ ជារួមសំខាន់ជាងគេបំផុត គឺត្រូវលុបបំបាត់សំរាមប្លាស្ទិកឱ្យអស់ពីភូមិ សង្កាត់។

### ង.៥.ដីកប់ខ្មោច

ជាទូទៅពិធីបុណ្យសព មានពីរបែបគឺពិធីដុតសព និងកប់សពរក្សាក្នុងដី ដែលពិធីទាំងពីរនេះពិធីកប់សពត្រូវការប្រើប្រាស់ដី ដែលធ្វើឱ្យមានការបាត់បង់ដីសម្រាប់ប្រើប្រាស់បម្រើឱ្យការអភិវឌ្ឍក្នុងសហគមន៍ ដែលមនុស្សរស់នៅ។ នៅក្នុងសង្កាត់ស្រយ៉ូវ បច្ចុប្បន្នក៏មានប្រើពិធីទាំងពីរនេះដែរ ហើយក៏មានទីលានកប់សពចំនួន ០៤កន្លែងហើយដែរ តែទៅអនាគតទីលានទាំងអស់នេះ មិនមានលទ្ធភាពក្នុងការបញ្ចុះសពបានគ្រប់គ្រាន់ស្របតាមតម្រូវការឡើយ ដែលចាំបាច់អាជ្ញាធរដែនដីពាក់ព័ន្ធជាពិសេសក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ត្រូវខិតខំយកចិត្តទុកដាក់គិតគូរអំពីពិធីបូជាសពនេះ ដែលនឹងកើតឡើងជាបន្តបន្ទាប់ ដោយគួរខិតខំលប់បំបាត់ការបញ្ចុះសព ដែលកប់នៅក្នុងដីហើយជំនួសមកវិញ ដោយការរៀបចំឱ្យមានកន្លែងបូជាសពនៅតាមវត្តអារាម ឬកន្លែងណាផ្សេងដាច់ឆ្ងាយពីភូមិ ដែលជាជម្រើសល្អបំផុត។

### ង.៦.ស្រះ និងអណ្តូងទឹក

ទឹក គឺជាផ្នែកមួយនៃធាតុ ដ៏សំខាន់បំផុតសម្រាប់រាងកាយមនុស្សយើង ដែលជាពិសេសនោះ គឺសម្រាប់សុខភាព ដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស ។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែង ប៉ុន្តែវាមិនអាច

យកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត។ នៅក្នុងសង្កាត់ស្រយ៉ូវបច្ចុប្បន្ននេះ មានការប្រើប្រាស់ទឹកស្អាត សម្រាប់ទទួលទានតាមរយៈការប្រើទឹកស្រះ និងអណ្តូង ដូចដែលបានរៀបរាប់ក្នុងជំពូកទី១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹក និងអណ្តូងទាំងអស់នេះ មិនទាន់មានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋនៅក្នុងសង្កាត់ត្រងទឹកភ្លៀងនៅរដូវវស្សា ដើម្បីរក្សាទុកនៅក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួនសម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំង ដែលខ្សត់ទឹកហើយថែមពីលើនេះទៀត ក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះ ប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត។

## ២.២.តំបន់រសើប

តំបន់រសើប ជាតំបន់ដែលទាមទារនូវការការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តំលៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ប្រពៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងទៀត។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ ដើម្បីជានាថាឃុំ/ឃុំត្រូវការដឹងឮនូវតម្រូវការ និងប្រធានបទពិសេសទាំងនេះ។

នៅក្នុងសង្កាត់ស្រយ៉ូវ មានតំបន់ការពារព្រៃលិចទឹកនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ដែលមានទំហំផ្ទៃដីចំនួន ៥ ៣៧៦,៤០ហិកតា ដែលទាមទារនូវកិច្ចការពារបន្ថែមពិសេសនោះ ដោយសារតំបន់នេះ មានសារៈសំខាន់ដល់ការធានាលំនឹងធម្មជាតិ ជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ ជីវចម្រុះនៃបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។ ទួលបុរាណចំនួន ៣៤កន្លែង វត្តមានស្ថានីបុរាណ០១កន្លែង និងស្ថានីបុរាណចំនួន ០១កន្លែង ដែលទាមទារនូវកិច្ចការពារបន្ថែម ពិសេសដែរនោះ ដោយសារតំបន់នេះមានសារៈសំខាន់ផ្នែកវប្បធម៌ប្រវត្តិសាស្ត្រ តាមរយៈការធ្វើកំណាយសិក្សាស្រាវជ្រាវស្វែងរកសំណល់ជាភ័ស្តុតាង ដែលនាំឱ្យដឹងពីប្រវត្តិសាស្ត្រពីយូរលង់មក ហើយ ចំណែកសហគមន៍នេសាទ ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសនោះដោយសារតំបន់នេះត្រូវថែរក្សាទុកស្របតាមច្បាប់ស្តីពីជលផល ជាតំបន់សហគមន៍នេសាទ ព្រមទាំងតំបន់ដីសង្ស័យថាមានមីន ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែមពិសេស ដើម្បីធ្វើការហាមឃាត់ប្រជាពលរដ្ឋចូលទៅតំបន់នេះ ដែលនាំឱ្យពួកគាត់មានគ្រោះថ្នាក់ពីគ្រាប់មីន ដែលមិនទាន់ផ្ទុះ។ តំបន់រសើបដែលមាននៅក្នុងសង្កាត់ស្រយ៉ូវ ដូចបានរៀបរាប់ខាងលើមានបង្ហាញនៅក្នុងផែនទីតំបន់រសើបខាងក្រោម។

ផែនទី 10៖ តំបន់រសើបសង្កាត់ស្រយ៉ូវ




## ២.៣.ការប្រឈម

### ២.៣.១.ការប្រឈមដោយធម្មជាតិ

#### ក.កំណើនប្រជាជន

បច្ចុប្បន្ននៅក្នុងសង្កាត់ស្រយ៉ូវ បានរកឃើញថា ប្រជាពលរដ្ឋបានកើនឡើងតាមធម្មជាតិជារៀងរាល់ឆ្នាំ ដែលគិតជាមធ្យមប្រមាណ ១,១០ភាគរយ ហើយទៅថ្ងៃអនាគតត្រឹមឆ្នាំ២០៣២ បញ្ហាកំណើនប្រជាជន ត្រូវបានធ្វើការគិតគូរដោះស្រាយ ដោយពុំមានបញ្ហាប្រឈមធ្ងន់ធ្ងរឡើយ តែបន្តពីនេះទៅមុខវែងឆ្ងាយនឹងអាចកើតមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយមួយចំនួនដូចខាងក្រោម៖

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ។

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកក្នុងការដោះស្រាយ ដោយសារតែនៅក្នុងសង្កាត់ ពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ។

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយដូចជាការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម។

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយដូចជា គ្រូពេទ្យ ឧបករណ៍ និងសម្ភារៈបរិក្ខាពេទ្យ និងថ្នាំសង្កូវបន្ថែម។

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយ សម្រាប់ការផ្គត់ផ្គង់បន្ថែម។

### ខ.គ្រោះធម្មជាតិ ការរេចរឹលនៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងសង្កាត់ស្រយ៉ូវ គេបានកត់សម្គាល់ឃើញថា មានជួបប្រទះនូវគ្រោះធម្មជាតិ កើតឡើងស្ទើរតែរៀងរាល់ឆ្នាំ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ ជាដើម ។ ទន្ទឹមនេះ ដីធ្លីដែលជាធនធានធម្មជាតិកម្រនៅក្នុងសង្កាត់ស្រយ៉ូវ ក៏មានភាពរេចរឹលទៅៗផងដែរ ដូចជា ធ្វើឱ្យដីស្រែរឹងនិងខ្សោះជីជាតិ ដោយសារតែការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតនៅលើដំណាំស្រូវ និងដំណាំដទៃទៀត មិនស្របតាមបទដ្ឋានបច្ចេកទេស ព្រមទាំងមានការថយចុះ និងបាត់បង់ធនធានជលផល ជាពិសេសនោះមច្ឆាជាតិ ដោយសារការនេសាទខុសច្បាប់ មានដូចជា ការប្រើប្រាស់ឧបករណ៍ឆក់ នេសាទនៅរដូវបិទនេសាទជាដើម ។ ទៅថ្ងៃអនាគត ប្រជាពលរដ្ឋនៅក្នុងសង្កាត់នៅតែបន្តជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែល បើសិនជាមិនមានយន្តការឬដំណោះស្រាយ ដើម្បីទប់ទល់ទៅនឹងគ្រោះរាំងស្ងួតព្រមទាំងមិនមានការកែប្រែឥរិយាបថ នៅក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ។

### ២.៣.២.ការប្រឈមដោយ ការអភិវឌ្ឍដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍនានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងតែនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញ បើគម្រោងអភិវឌ្ឍទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធាន ដែលមានវានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចីរភាពនៃគម្រោងទាំងនោះទៅដល់កូនចៅជំនាន់ក្រោយក្នុងតំបន់នេះបានឡើយ ដូចជា ស្ថានភាពនៅក្នុងសង្កាត់ស្រយ៉ូវ ដែលជាសង្កាត់គោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដី ដូចអ្វីដែលបានរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះបានឱ្យដឹងថា សង្កាត់ស្រយ៉ូវមានស្ថានភាពភូមិសាស្ត្រ ជាតំបន់វាលទំនាបដែលមានធនធានដីអំណោយផលដល់ដំណាំស្រូវ និងដំណាំចម្ការ ដែលជាសក្តានុពលក្នុងការអភិវឌ្ឍសង្កាត់នេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយទេ។ ដូចនេះសម្រាប់សង្កាត់ស្រយ៉ូវគួរចៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍទាំងឡាយណា ដែលនាំឱ្យមានផលប៉ះពាល់ទៅដល់ការបាត់បង់ដីស្រែចម្ការ ដែលខ្លួនមានធ្វើឱ្យសង្កាត់មានការថយចុះឱកាសអភិវឌ្ឍ ដូចជា គម្រោងចាក់លុបដីស្រែ ដីចម្ការបង្កកទុកលក់ឬពុះដីឡូត៍លក់ ដើម្បីកេងផលចំណេញពីឈ្មួញ និងគម្រោងជីកយកអាចម៍ដីយកលក់ជាដើម ។ លើកលែងតែគម្រោងណាពាក់ព័ន្ធ ដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្ម ដូចជាកសិដ្ឋានផលិតពូជស្រូវ ពូជដំណាំ ស្រែគម្រូផលិតជីធម្មជាតិ ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនឹងនេះក៏នៅមានគម្រោងអភិវឌ្ឍប៉ះពាល់ដល់ការរស់នៅនិងបរិស្ថាន ដែលគួរចៀសវាងផងដែរ ដូចជាគម្រោងបង្កើតសិប្បកម្មឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមនេះក្រៅពីការប្រឈមដោយការអភិវឌ្ឍខាងលើដែលត្រូវចៀសវាង ក៏នៅមានការប្រឈមទៅនិងអំពើអនាធិបតេយ្យដែលកើតចេញពីការខ្វះខាតរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ផងដែរ ដូចជាការសាងសង់ផ្ទះស្នាក់នៅលើដីនៅតាមមាត់ប្រឡាយ តាមចិញ្ចើមផ្លូវសាធារណៈ ស្ទឹង ធ្វើស្រែបំពានទៅលើប្រឡាយ និងបឹងជាដើម។

## ២.៤.ឱកាស

### ២.៤.១.ដោយអំណោយផលពីធម្មជាតិ

នៅលើលោកយើងនេះ ធម្មជាតិ គឺពិតជាបានផ្តល់នូវធនធានដ៏មានសារៈសំខាន់ សម្រាប់ធ្វើអ្វីៗគ្រប់យ៉ាងដែលមនុស្សចង់ធ្វើ ដូចជាមនុស្សបានប្រើប្រាស់ធនធានដី និងទឹកសម្រាប់ការដាំដុះ ឈើធ្វើឧសដុត សម្រាប់ផ្តល់

កំដៅ ឬសាងសង់ទីជម្រក ខ្យល់អាកាស ធ្យូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែងជាដើម សម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ចំណែកនៅក្នុងសង្កាត់ស្រយ៉ូវ យើងផ្តោតសំខាន់លើធនធានដី ដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍសង្កាត់ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ។ នៅក្នុងសង្កាត់ស្រយ៉ូវមានស្ថានភាពអំណោយផលពីធម្មជាតិដូចខាងក្រោម៖

- ស្ថានភាពដី ជាវាលទំនាប ដែលអំណោយផលដល់ការដាំដុះដំណាំស្រូវ ព្រមទាំងទំនាបទាបនិងទំនាបខ្ពស់អំណោយផលដល់ការដាំដំណាំចម្ការ ។
- នៅជិតប្រភពស្ទឹង បឹង អូរ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការ នៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង។
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវ និងដំណាំចម្ការបាន។
- អាកាសធាតុ ក្តៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទ។

### ២.៤.២.ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងតែទទួលបានភាពប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា។បច្ចេកវិទ្យាថ្មីៗបានធ្វើឱ្យមានការផ្លាស់ប្តូរកាន់តែប្រសើរឡើង សម្រាប់ជីវិតរស់នៅរបស់ពលរដ្ឋ ដែលធ្វើឱ្យអ្វីៗនៅក្នុងពេលបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា គុណភាព និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា។

បច្ចុប្បន្ន ស្ថានភាពនៅក្នុងសង្កាត់ស្រយ៉ូវ គឺមានសក្តានុពលខ្លាំងដោយពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ និងដំណាំចម្ការរួមផ្សំ ហើយនាពេលអនាគត ក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំទាំងនេះ ដដែលដែរនោះប្រជាពលរដ្ឋនឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យ សម្រាប់វិស័យកសិកម្មដំណាំស្រូវ និងចម្ការ ដើម្បីជួយជំរុញឱ្យមានការកើនឡើងទិន្នផលខ្ពស់ ដើម្បីអាចដោះស្រាយបាននូវសន្តិសុខស្បៀង និងមានប្រាក់ចំណូលកាន់តែខ្ពស់ ដែលនាំឱ្យជីវភាពរស់របស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ពេលដែលមានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់នាពេលខាងមុខ ។ តាមរយៈបច្ចេកវិទ្យាថ្មីៗ នឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យ សម្រាប់ការផលិតដំណាំស្រូវ ដែលរួមមានដូចជា៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូង ជ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់ និងបោកបែន ព្រមទាំងគ្រឿងយន្តដឹកជញ្ជូនជាដើម។ល។

### ២.៤.៣.ដោយគម្រោងវិនិយោគ

សម្រាប់នាពេលអនាគត នៅសង្កាត់ស្រយ៉ូវ ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវនោះ នឹងនាំឱ្យមានការផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ និងដំណាំចម្ការ ដូចជាគម្រោងបង្កើតកសិដ្ឋានកសិកម្ម ដើម្បីជំរុញផលិតកម្មដំណាំស្រូវ និងដំណាំចម្ការ ព្រមទាំងគម្រោងវិនិយោគទៅលើការកែច្នៃផលិតផលកសិកម្ម ដើម្បីនាំចេញ ដែលនឹងផ្តល់ការងារបន្ថែមទៀតទៅដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងកាត់បន្ថយបាននូវភាពក្រីក្រ ស្របទៅតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

## ២.៥.បញ្ហា មូលហេតុ និងដំណោះស្រាយ

ផ្អែកទៅតាមការរកឃើញ នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគ និងចងក្រងបាននូវបញ្ហា ដែលកើតមាននៅក្នុងសង្កាត់ស្រយ៉ូវ។ មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយលើបញ្ហាទាំងអស់នេះ គឺត្រូវបានបង្ហាញនៅក្នុងតារាង និងនៅក្នុងផែនទី ដូចមាននៅខាងក្រោមនេះ៖

តារាង 33៖ បញ្ហាប្រឈម និងសក្តានុពល(ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១.ខ្វះដីលំនៅឋាន (៥គ្រួសារ)  | ភូមិស្រយ៉ូវត្បូង<br>ភូមិរលួស<br>ភូមិរកា | ក-លក់សងបំណុល | ក-ខ- ដោះស្រាយតាមរយៈដីសម្បទានសង្គមកិច្ច |
| | | ខ-កំណើនគ្រួសារ | |
| ២.ខ្វះដីកសិកម្ម (១០៣២គ្រួសារ) | គ្រប់ភូមិ | ក-លក់សងបំណុល | ក-ខ-គ-១-ស្នើសុំសម្បទានសង្គមកិច្ច<br>ក-ខ-គ-២-ផ្តល់បច្ចេកទេសកសិកម្មទំនើបៗ |
| | | ខ-កំណើនគ្រួសារ | |
| | | គ-ដីកសិកម្មតិច | |
| ៣.គ្រប់មីននៅសេសសល់  | ភូមិរកា<br>ភូមិស្រយ៉ូវជើង<br>ភូមិស្រយ៉ូវត្បូង | ក-ជាកន្លែងសមរភូមិប្រយុទ្ធ | ក-១-ដាក់សញ្ញាសម្គាល់ដីដែលមានមីននិងគ្រាប់មីនទាន់ផ្ទុះ<br>ក-២-ដាក់សំណើរទៅអង្គភាពកំចាត់មីន ឬអង្គការដើម្បីជួយអន្តរាគមន៍ |
| ៤-ទិន្នផលស្រូវទាប  | ដីស្រែ | ក-ដីខ្វះជីជាតិ | ក-១-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត<br>ក-២-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ក-៣-ជម្រុញការចិញ្ចឹមសត្វយកលាមក |
| | | ខ-ខ្វះបច្ចេកទេសកសិកម្ម | ខ-១-បណ្តុះបណ្តាលពីបច្ចេកទេសផលិតពូជស្រូវ<br>ខ-២-បណ្តុះបណ្តាលពីការដាំដំណាំស្រូវ<br>ខ-៣-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី<br>ខ-៤-បណ្តុះបណ្តាលបច្ចេកទេសជីកំប៉ុស្ត<br>ខ-៥-ប្រើប្រាស់ពូជស្រូវសុទ្ធល្អតាមស្តង់ដា |
| ៥-ខ្វះទឹកស្រោចស្រព  | ដីស្រែ | ក-ប្រព័ន្ធធារាសាស្រ្តរងការខូចខាត | ក-១-ស្តាប្រឡាយឡើងវិញ<br>ក-២-ជួសជុល និងរៀបចំទ្វារទឹក |
| | | ខ-ធ្វើស្រែក្នុងប្រឡាយ | ខ-១-ស្រង់ស្ថិតិអ្នកធ្វើស្រែក្នុងប្រឡាយ<br>ខ-២-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធនានា។<br>ខ-៣-រកវិធីដោះស្រាយនិងធ្វើកិច្ចសន្យា |

| | | | |
|---|---|---|---|
| | | | បញ្ឈប់ |
| ៦-ផ្លូវរងការខូចខាត ពិបាកធ្វើដំណើរ   | -ផ្លូវកៅស៊ូពីផ្លូវជាតិលេខ៦ត្រង់ភូមិពោធិ៍សែនស្ពាយទៅភូមិស្រយ៉ូវត្បូង -ផ្លូវគ្រួសក្រហមពីភូមិប្រម៉ាតដីទៅភូមិរលួយ -ផ្លូវគ្រួសក្រហមពីភូមិពោធិសែនស្ពាយទៅភូមិពោធិអ៊ុន -ផ្លូវគ្រួសក្រហមពីភូមិស្រយ៉ូវត្បូងទៅឃុំប្រឡាក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង -ផ្លូវគ្រួសក្រហមក្នុងភូមិស្រយ៉ូវត្បូង -ផ្លូវគ្រួសក្រហមក្នុងភូមិម្នាវ -ផ្លូវលំដីសក្នុងភូមិស្រយ៉ូវជើង -ផ្លូវលំដីសពីភូមិរការទៅភូមិពុកយុក -ផ្លូវលំដីសពីភូមិកំរ៉ែងទៅភូមិរការ | ក-ឡានធុនធ្ងន់ដឹកលើសទំងន់ឆ្លងកាត់នាំឱ្យខូចផ្លូវ | ក-១-ពង្រឹងការអនុវត្តន៍ច្បាប់ចរាចរទប់ស្កាត់ឡានដឹកលើសទម្ងន់តាមរយៈដាក់សញ្ញាកំណត់ទម្ងន់ដឹកជញ្ជូនរបស់រថយន្ត ក-២-ដាក់បារាស់កាត់ផ្លូវដែលមានរថយន្តធំឆ្លងកាត់ |
| | | ខ-មានប្រព័ន្ធលូមិនគ្រប់គ្រាន់ | ខ-១-ដាក់លូបង្ហូរទឹកតាមមុខផ្ទះជាប់ផ្លូវ |
| | | គ-ចងគោ ក្របីលើផ្លូវ | គ-១-ដាក់បំរាមហាមចងគោ ក្របីលើផ្លូវ |
| | | ឃ-ខ្វះការថែទាំផ្លូវ | ឃ-១-ថែទាំផ្លូវ ខួបជាប្រចាំ ឃ-២-បង្កើតគណៈកម្មការថែទាំផ្លូវ |
| ៧. បាត់បង់ព្រៃលិចទឹក  | តំបន់៣ | -កាប់រានយកដីធ្វើស្រែប្រាំង | -ទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក -ត្រូវអនុវត្តច្បាប់ដោយការដាក់ទោសទណ្ឌចំពោះអ្នកកាប់បំផ្លាញព្រៃលិចទឹក -ផ្សព្វផ្សាយច្បាប់ជលផល |
| ៨-ធនធានមច្ឆាថយចុះ និងបាត់បង់  | បឹង ស្ទឹង អាងស្តុកទឹក | ក-នេសាទខុសច្បាប់ | ក-១-ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ក-២-ហាមឃាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ |
| ៩-ខ្វះទឹកស្អាតប្រើប្រាស់ | ក្នុងឃុំ | ក-គ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | ក-១-យកចិត្តទុកដាក់ជម្រុញឱ្យមានសេវាកម្មផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាតបានដល់គ្រប់ភូមិ |
| | | ខ-គ្រួសារមួយចំនួនខ្វះសម្ភារៈបរិក្ខារចម្រោះទឹកស្អាត | ខ-១-បំផុសឱ្យប្រជាពលរដ្ឋមានការប្រើប្រាស់ធុងចម្រោះទឹកស្អាត |

ប្រភព៖ *សៀវភៅផែនការអភិវឌ្ឍ៥ឆ្នាំ និងក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ខែកញ្ញា ២០១៨*

ផែនទី ១១៖ បញ្ហា មូលហេតុ និងដំណោះស្រាយ



# ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២

## ៣.១.តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១.តម្រូវការដីនៅតាមប្រភេទ

នៅពេលអនាគតរហូតដល់ឆ្នាំ ២០៣២ នៅក្នុងសង្កាត់ស្រយ៉ូវ នឹងមានការកើនឡើងចំនួនប្រជាជន ៣ ៤៦៥នាក់ ដែលត្រូវនឹងចំនួន ៧៤៥គ្រួសារ និងបច្ចុប្បន្នអ្នកគ្មានដីលំនៅឋានពិតប្រាកដមានចំនួន ០៥ គ្រួសារ និងអ្នកគ្មានដីកសិកម្មពិតប្រាកដ ដែលត្រូវដោះស្រាយទៅអនាគតចំនួន ១ ០៣២ គ្រួសារ ។ ដោយសារកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែមសម្រាប់លំនៅឋាន និងដីស្រែជូនដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ស្រយ៉ូវទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូក២ខាងលើ នៃរបាយការណ៍នេះ ។ តែដោយសារទំហំផ្ទៃដីដែលត្រូវបានប្រើប្រាស់បច្ចុប្បន្នក្នុងសង្កាត់ពុំមានប្រែប្រួលកើនឡើងស្របគ្នាទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដើម្បីដោះស្រាយបានតាមតម្រូវការដីសម្រាប់លំនៅឋាន និងដីស្រែបន្ថែមនោះគឺជាដំណោះស្រាយសមស្របដីសម្រាប់លំនៅឋានត្រូវប្រើប្រាស់ដីភូមិលំនៅឋានដែលមានស្រាប់ ពីព្រោះស្ថានភាពការតាំងលំនៅឋានបច្ចុប្បន្ន មិនទាន់មានភាពចង្អៀត ដែលអាចមានលទ្ធភាពទ្រទ្រង់ដល់ការសាងសង់លំនៅឋានបន្ថែមទៀតបានសម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ហើយម្យ៉ាងទៀតការតាំងលំនៅឋាន មានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលទៅដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតមានដូចជាសេវាអប់រំ និងសេវាសុខភាព ជាដើម។ល។

ចំពោះដីស្រែវិញមិនត្រឹមតែមិនបានពង្រីកបន្ថែមទៅតាមការគិតគូរខាងលើនោះទេ តែត្រូវទទួលរងការបាត់បង់ខ្លះថែមទៀត ប្រសិនបើដីស្រែប្រាំងនៅក្នុងតំបន់៣ ដែលជាដីការពារជុំវិញបឹងទន្លេសាបមិនត្រូវបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋកាន់កាប់អាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ។ ជាដំណោះស្រាយ គឺត្រូវតែគិតគូរពិចារណាដោយធ្វើការយកចិត្តទុកដាក់ តាមរយៈការបង្កើនផលិតភាពគុណភាព និង ពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែបង្កើនរដូវឱ្យបានពី២ទៅ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ៣.១.២.ស្ថានភាពនៃដីធ្លី និងសក្តានុពល

នៅពេលអនាគត ធនធានដីក្នុងសង្កាត់ស្រយ៉ូវនៅតែរក្សាក្រឡាផ្ទៃសរុបចំនួន ២៨ ២៦២,៤៨ ហិកតាដដែល ដោយពុំមានការប្រែប្រួលអ្វីឡើយ ដោយដីធ្លីទាំងនេះ នឹងត្រូវប្រើប្រាស់សម្រាប់ការសាងសង់លំនៅឋាន (រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន និងដំណាំជុំវិញលំនៅឋាន) ដីស្រែ (រួមទាំងប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន) ដីចម្ការដំណាំ ដីស្មៅ បឹង អាងស្តុកទឹក និងស្រះ ដូចទៅនឹងការប្រើប្រាស់ដីធ្លីបច្ចុប្បន្នដដែលដោយពុំមានការប្រែប្រួលឡើយ ព្រោះដីធ្លី ដែលបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះ គឺសមស្របនិងចំសក្តានុពលនៃដីរួចហើយ។ ចំណែកទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយៗ ដូចមាន រៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ។ ជាទូទៅធនធានដីនៅក្នុងសង្កាត់ស្រយ៉ូវមានសក្តានុពលខ្ពស់ សមស្របទៅលើកសិកម្មដំណាំស្រូវនិងចម្ការដំណាំ ដោយសារតែដីក្នុងសង្កាត់មានទីតាំងភូមិសាស្ត្រ អំណោយផលពីធម្មជាតិ ដូចដែលបានរៀបរាប់ក្នុងជំពូកទី២ខាងលើ។ ដូច្នេះការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់

ដីទៅថ្ងៃអនាគតក្នុងសង្កាត់ ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវ និងចម្ការជាចំបង ជាការប្រើប្រាស់បានត្រឹមត្រូវចំសក្តានុពល ហើយក៏ជាការគាប់ជួន ដែលភាពអំណោយផលពីធនធានដីនៅក្នុងសង្កាត់សមស្របទៅលើកសិកម្មដំណាំស្រូវ និងចម្ការនេះ ហើយក៏ស្របទៅនឹងគោលដៅ ដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងា ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ ដែលមានចែងនៅក្នុងមុំទី១ ចតុកោណទី ៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍ នៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យសង្កាត់មានការរីកចម្រើនបានតាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវនៅលើផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើពេញសង្កាត់ទាំងមូល។ ដើម្បីបង្កើនទិន្នផលស្រូវ និងដំណាំចម្ការ ដែលជាដំណាំដ៏មានសារៈសំខាន់សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុកមិនអាចខ្វះបាន និងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសកម្មភាពធ្វើពាណិជ្ជកម្មនាំអង្ករចេញ របស់រាជរដ្ឋាភិបាលកម្ពុជា។

ចំណែកដី ដែលមានទំហំតិចតួច ដែលបានកំណត់ជាដីសម្រាប់ការសាងសង់លំនៅឋាន នៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលនៅក្នុងការធ្វើដំណើរចេញចូល និងងាយស្រួលក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងសង្កាត់បានប្រកបដោយផាសុកភាព ព្រមទាំងដីដែលប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ។

## ៣.២.ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១.ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅរាល់ការកំណត់តំបន់ប្រើប្រាស់ដី ត្រូវបានផ្តោតសំខាន់លើមុខងារនៃការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកម្សាន្ត ព្រៃឈើ ។ល។ ទន្ទឹមនឹងនោះការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វា តែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីទាំងនេះត្រូវតែគិតគូរពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយត្រូវតែប្រាកដថា ដីដែលក្រោយពីបានប្តូរមុខងារប្រើប្រាស់ហើយនោះ ត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬ ផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់ពីមុន តាមរយៈការរក្សាជំហរច្បាស់លាស់ ក្នុងការបង្កើនធនធានប្រើប្រាស់ប្រកបទៅដោយប្រសិទ្ធិភាព ជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុតចំពោះមនុស្សនៅជំនាន់ក្រោយ។ ឧទាហរណ៍៖ ដូចជាការផ្លាស់ប្តូរពីដីព្រៃឈើរេចរឹលទៅជាដីសម្រាប់កសិកម្ម ដែលវានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើ ដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍មូលដ្ឋាន តែជំនួសមកវិញដោយវាលស្រែសម្រាប់ផលិតកម្មស្រូវ ដែលជាចំណីអាហារដ៏សំខាន់ សម្រាប់ជីវិតរស់នៅមិនអាចខ្វះបាន ទាំងនេះជាការបង្ហាញឱ្យឃើញអំពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀត នៅលើទីតាំងដីដដែល។

យ៉ាងណាមិញក្នុងរយៈពេល១៥ឆ្នាំខាងមុខ រហូតទៅដល់ឆ្នាំ២០៣២ សម្រាប់ការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ ត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋដូចដែលបានរៀបរាប់ខាងលើ ជាពិសេសនោះ គឺការដោះស្រាយការបែងចែកការប្រើប្រាស់ដីធ្លីដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ តាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីក្នុងការកាត់

បន្ថយផលប៉ះពាល់ជាអវិជ្ជមានសម្រាប់ការប្រើប្រាស់ដីធ្លីនៅក្នុងសង្កាត់ ដែលជាក់ស្ដែងនៅក្នុងសង្កាត់ស្រយ៉ូវ មិនមានការប្រែប្រួលការប្រើប្រាស់ដីនោះទេ។

តារាង 34៖ តារាងប្រើប្រាស់ដីនាពេលអនាគត

| ប្រភេទដីប្រើប្រាស់ដី | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ឆ្នាំក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន ភូមិ** | **៥៤៦,៤៩** | **៥៤៦,៤៩** | **0** |
| -ដីលំនៅឋានភូមិក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | ១១២,៤៨ | ១១២,៤៨ | 0 |
| -ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៤១៤,៨២ | ៤១៤,៨២ | 0 |
| -ដីលំនៅឋាន ភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ១៧,០៦ | ១៧,០៦ | 0 |
| **ខ.ដីស្រែវស្សា** | **៧២៩៥,២៤** | **៧២៩៥,២៤** | **0** |
| -ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | ៤,៩២ | ៤,៩២ | 0 |
| -ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ២៩៥៧,៤៦ | ២៩៥៧,៤៦ | 0 |
| -ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៤៣៣២,៨៦ | ៤៣៣២,៨៦ | 0 |
| **គ.ដីស្រែប្រាំង** | **១៤២៦៦,៦១** | **១៤២៦៦,៦១** | **0** |
| -ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៦,៨៨ | ៦,៨៨ | 0 |
| -ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៩៧១០,៦៨ | ៩៧១០,៦៨ | 0 |
| -ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ៤៥៤៩,០៦ | ៤៥៤៩,០៦ | 0 |
| **ឃ.ដីស្រែប្រាំងនិង ស្រែវស្សា** | **២៤៦២,៩៣** | **២៤៦២,៩៣** | **0** |
| -ដីស្រែប្រាំងនិង ស្រែវស្សា | ៥៦៦,២៤ | ៥៦៦,២៤ | 0 |
| -ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ១៥១៧,២៣ | ១៥១៧,២៣ | 0 |
| -ដីស្រែប្រាំងនិង ស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៣៧៩,៤៦ | ៣៧៩,៤៦ | 0 |
| **ង.ដីចម្ការស្រោចស្រព** | **១៦,៦៤** | **១៦,៦៤** | **0** |
| **ច.ស្ទឹងមានទឹកតាមរដូវ** | **២១៧,៥៦** | **២១៧,៥៦** | **0** |
| **ឆ.បឹង** | **៣៣៤,៥0** | **៣៣៤,៥0** | **0** |
| **ជ.អាងស្តុកទឹក** | **២៩៤៨,៣១** | **២៩៤៨,៣១** | **0** |
| -អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ២១៨៥,៦៣ | ២១៨៥,៦៣ | 0 |
| -អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ៧៦២,៦៨ | ៧៦២,៦៨ | 0 |
| **ឈ.ស្រះ** | **១៦៩,៨៣** | **១៦៩,៨៣** | **0** |
| -ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប | ១,០១ | ១,០១ | 0 |

| | | | |
|---|---|---|---|
| -ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៥,៤៩ | ៥,៤៩ | 0 |
| -ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៩៨,៦៧ | ៩៨,៦៧ | 0 |
| -ស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ៦៤,៦៦ | ៦៤,៦៦ | 0 |
| **ផ្ទៃដីសរុបក្នុងសង្កាត់** | ២៨ ២៥៦,១៥ | ២៨ ២៥៦,១៥ | **0** |

តារាង 35៖ តារាងផែនការផ្ទែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែង/ចំនួន ឆ្នាំ ២០១៧(ម) | ប្រវែង/ ចំនួន ១៥ឆ្នាំ(ម) | បំរែបំរួល(ម) |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ១១៥០១,៦៣ | ៦០៨៨៥,៦២ | ៤៩៣៨៣,៩៩ |
| ផ្លូវក្រាលគ្រួសក្រហម | ៧១៣៨៣,៧១ | ៨១៧២៥,១៥ | ១០៣៤១,៤៤ |
| ផ្លូវលំដីស/រទេះ | ១០៤២០១,៧២ | ៤៤៤៧៦,២៩ | ៥៩៧២៥,៤៣ |
| ប្រឡាយមេ | ១៩២២០,៩៧ | ១៩២២០,៩៧ | 0 |
| ប្រឡាយរង | ៤២២៣ | ៤២២៣ | 0 |
| ប្រឡាយតូច | ៣៩៥៥៦,០៩ | ៣៩៥៥៦,០៩ | 0 |

តារាង 36៖ តារាងផែនការផ្ទែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមតេយ្យ | ៨អគារ ៨បន្ទប់ | ៧ អគារ ៣៣ បន្ទប់ | ០៥អគារ ២៥បន្ទប់ |
| សាលាបឋមសិក្សា | ១១ អគារ ៤៧បន្ទប់ | ៨ អគារ ៤៧ បន្ទប់ | 0 |
| សាលាអនុវិទ្យាល័យ | 0 | ០៣ អគារ ៣២ បន្ទប់ | ០៣ អគារ ៣២ បន្ទប់ |
| សាលាវិទ្យាល័យ | ០១អគារ ២១បន្ទប់ | ០៣អគារ ៣៩ បន្ទប់ | ០២អគារ ១៨បន្ទប់ |
| មណ្ឌលសុខភាព | ០១អគារ | ០១អគារ | 0 |

### ៣.២.២.ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ប្រភេទនៃការប្រើប្រាស់ដីនាពេលអនាគតនៅក្នុងសង្កាត់ស្រយ៉ូវ គឺជាការសម្រេចចិត្តមួយ ដ៏ត្រឹមត្រូវបំផុត ដោយពឹងផ្អែកទាំងស្រុងលើការវិភាគដីដ៏សមស្របមួយ តាមរយៈការវាយតម្លៃតាមបែបសាមញ្ញលើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងសង្កាត់នាពេលបច្ចុប្បន្ននេះ ដោយយកផែនទីប្រើប្រាស់ដីបច្ចុប្បន្នធ្វើជាមូលដ្ឋានក្នុងការគិតពិចារណា ដូចមានរំលេចឱ្យឃើញនៅក្នុងតារាងទី៣៤ខាងលើនេះ ដោយភ្ជាប់ជាមួយនូវផែនទីប្រើប្រាស់ដីនាពេលអនាគតមួយ ដូចខាងក្រោម ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាព តាមរយៈការបង្ហាញយ៉ាងពិស្តាពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់សង្កាត់មួយនេះ។ ទន្ទឹមនឹងនោះ ផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោមក៏មានការអត្ថាធិប្បាយលម្អិតលើតំបន់ប្រើប្រាស់ដីនីមួយៗដែលបានកំណត់លើផែនទីនេះផងដែរ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគត



### ៣.២.៣.សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

បើផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតខាងលើ បានបង្ហាញឱ្យឃើញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវដូចខាងក្រោម៖

#### ក.ដីលំនៅឋាន ភូមិ

ដីលំនៅឋាន ភូមិ ជាដីដែលត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ។ នាពេលអនាគត ក្នុងសង្កាត់ស្រយ៉ូវ ដីលំនៅឋាន ភូមិ ភាគច្រើនស្ថិតនៅសងខាងតាមបណ្តោយនិងខាងត្បូងផ្លូវជាតិលេខ៦ ព្រមទាំងខាងជើងផ្លូវមានតិចតួចតែពីរភូមិ និងមានផ្ទៃដីសរុបចំនួន ៥៤៦,៤៩ ហិកតាដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីលំនៅឋាន ភូមិ ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ដោយសារបច្ចុប្បន្ននេះ ដីលំនៅឋានភូមិ នៅមានភាពទូលាយដែលត្រូវបានប្រើប្រាស់ទំហំដីប្រមាណ ០,១២ ហិកតា នៅក្នុងមួយគ្រួសារ ដែលអាចធ្វើការដោះស្រាយសម្រាប់ការសាងសង់លំនៅឋានរហូតដល់ឆ្នាំ២០៣២បាន ដោយនឹងត្រូវប្រើប្រាស់ទំហំដីថយចុះចំនួនតិចតួច នៅសល់ប្រមាណ ០,១០ហិកតា ក្នុងមួយគ្រួសារ ។ ដីលំនៅឋាន ភូមិ ជាតំបន់ទំនាបមធ្យមមានប្រភេទដីកណ្តេងពណ៌ខ្មៅដីល្បាយខ្សាច់ពណ៌សលាយខ្មៅ និងពពាយកណ្តុរពណ៌ខ្មៅ និងពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនិងស្រោចស្រពដំណាំរួមផ្សំនៅជុំវិញលំនៅឋាន បានមកពីអណ្តូងស្នប់ ត្រពាំង ស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដៃ។ នាពេលអនាគត ទីតាំងដីលំនៅឋាន ភូមិ ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះនឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារទីតាំងដីនេះ មានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សានិងនៅជាប់ផ្លូវជាតិលេខ៦ និងផ្លូវសំខាន់ៗនៅក្នុងសង្កាត់ងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋ ដែលសមស្របសម្រាប់ការតាំងលំនៅឋាន ជាជម្រកដ៏កក់ក្តៅសម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់។ ដីលំនៅឋានភូមិនាពេលអនាគត ស្ថិតនៅតាម ០៣តំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីលំនៅឋាន ភូមិនៅក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប**

ដីលំនៅឋាន ភូមិ ក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមាន ០២ កន្លែងផ្សេងគ្នា មានទំហំផ្ទៃដីសរុបចំនួន ១១២,៤៨ ហិកតា ក្នុងនោះមួយផ្នែកនៅខាងជើងផ្លូវជាតិលេខ៦ ចូលទៅក្នុងប្រមាណ ១,៥ គីឡូម៉ែត្រ មានភូមិ ០២ គឺភូមិប្រម៉ាត់ដី និងភូមិកំពង់សំរោង និងមួយផ្នែកទៀត ស្ថិតនៅតាមបណ្តោយខាងជើងជាប់ផ្លូវជាតិលេខ៦ ដែលមានចំនួន ០៣ ភូមិ គឺភូមិពុកយុក ភូមិត្រពាំងវែង និងភូមិពោសែនស្នាយ ។ ដីលំនៅឋាន ភូមិ ក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីលំនៅឋាន ភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

លំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានពីរផ្នែក ទំហំផ្ទៃដីចំនួន ៤១៤,៨២ហិកតា នៅក្នុងនោះមួយផ្នែកស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ ចូលទៅក្នុង ដែលមានចំនួន ០៨ ភូមិ គឺភូមិរកា ភូមិកំរែង ភូមិចំបក់ ភូមិម្នាវ ភូមិស្រយ៉ូវជើង ភូមិស្រយ៉ូវត្បូង ភូមិពោធិ៍តាអ៊ុន និងភូមិរលួស ព្រមទាំងមួយផ្នែកទៀត ស្ថិតនៅតាមបណ្តោយខាងត្បូងជាប់ផ្លូវជាតិលេខ៦ មានចំនួន ០៣ ភូមិ គឺភូមិពុកយុក ត្រពាំងវែង និងភូមិពោសែនស្នាយ ។ ដីលំនៅឋានភូមិក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជនដែលត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីលំនៅឋាន ភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីលំនៅឋាន ភូមិក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីចំនួន ១៧,០៦ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ នៅក្នុងភូមិរលួស (មួយផ្នែកខាងជើងនៃភូមិរលួសស្ថិតក្នុងតំបន់១ និងមួយផ្នែកខាងត្បូងនៃភូមិស្ថិតនៅក្នុងតំបន់២) ។ ដីលំនៅឋាន ភូមិ ក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ។

**ខ.ដីស្រែវស្សា**

ដីស្រែវស្សានៅក្នុងសង្កាត់ស្រយ៉ូវ នាពេលអនាគត ភាគច្រើនលើសលប់ស្ថិតនៅប៉ែកខាងត្បូងផ្លូវជាតិលេខ៦ និងមានតិចតួចនៅប៉ែកខាងជើងផ្លូវជាតិលេខ៦ ហើយមានផ្ទៃដីសរុបចំនួន ៧ ២៩៥,២៤ ហិកតា ដែលបច្ចុប្បន្នត្រូវនេះបានប្រើប្រាស់ជាដីស្រែវស្សា ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ។ ដីស្រែវស្សាទាំងអស់នេះ ជាតំបន់ទំនាប មានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ ប្រផេះ និងពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត និងបឹងធំ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម។ ដីស្រែវស្សានេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋាន ភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋក្នុងសង្កាត់តែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមាន ដូចជា ពោត ល្ពៅ សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ល។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះ មានស្ថានភាពជាដីទាបលិចទឹកនៅរដូវវស្សា សមស្របសម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគ សម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុក ដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។ ដីស្រែវស្សា នាពេលអនាគតមានទីតាំងស្ថិតនៅតាម ០៣តំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីស្រែវស្សាក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ៤,៩២ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦។ ដីស្រែវស្សានៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ដែលត្រូវបានកាន់កាប់ និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ២ ៩៥៧,៤៦ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦។ ដីស្រែវស្សានៅក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែង ប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ៤ ៣៣២,៨៦ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦បន្តពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ។

**គ.ដីស្រែប្រាំង**

ដីស្រែប្រាំងនៅក្នុងសង្កាត់ស្រយ៉ូវ នាពេលអនាគត ស្ថិតនៅចុងភាគខាងត្បូងនៃសង្កាត់ ដែលមានផ្ទៃដីសរុបចំនួន ១៤ ២៦៦,៦១ ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ។ ដីស្រែប្រាំងទាំងនេះ ជាតំបន់

ទំនាបមានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋ ពណ៌ស ខ្មៅ ប្រផេះ និងពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) អាងឯកជន (បាត់ពន្លាក) បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះ បឹងកណ្តាល បឹងត្រពាំងជម្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន បឹងឈូកប្រជីត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្កូកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្កេរ បឹងតាលហាល បឹងស្នួងបែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះ លោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្តា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យប្រា បឹងបែកចាន បឹងស្នោ និងបឹងតាឡក ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម។ នាពេលអនាគត ទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែប្រាំងដដែល ដោយសារតែទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកខ្លាំងនៅរដូវវស្សា មិនអាចធ្វើស្រែវស្សាបាន សមស្របសម្រាប់ដំណាំស្រូវប្រាំងនៅពេលទឹកស្រកចុះវិញសម្រាប់ផ្គត់ផ្គង់ការហូបចុក និងលក់ទៅកាន់ទីផ្សារក្នុងនិងក្រៅប្រទេស ដើម្បីបង្កើនប្រាក់ចំណូលជាតិនិងគ្រួសារ។ ដីស្រែប្រាំងពេលអនាគតមានទីតាំងស្ថិតនៅតាម ០៣តំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ៦,៨៨ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦។ ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ដែលត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីសរុបចំនួន ៩ ៧១០,៦៨ ហិកតា ស្ថិតនៅភាគខាងត្បូងនៃសង្កាត់បន្តពីដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ៤ ៥៤៩,០៦ ហិកតា ស្ថិតនៅភាគខាងត្បូងនៃសង្កាត់បន្តជាប់ពីដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប។ ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទ។ នាពេលអនាគត ក្នុងករណីដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបទាំងនេះ មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យឆ្វៀលចេញពីតំបន់ការពារព្រៃលិចទឹកតាមការស្នើសុំរបស់អាជ្ញាធរដែនដីពាក់ព័ន្ធដោយផ្អែកលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ញានានារបស់រាជរដ្ឋាភិបាលទេនោះ គឺដីស្រែប្រាំងនេះ នឹងនៅតែកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកជុំវិញបឹងទន្លេសាប ដែលត្រូវការពារដដែល ។ តែទោះបីមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឆ្វៀលដីទាំងនេះជូនសម្រាប់ប្រើប្រាស់ជាដីស្រែក៏ដោយ ក៏ដីស្រែទាំងនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរ គឺពួកគាត់គ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។

### ឃ.ដីស្រែប្រាំង និងស្រែវស្សា

ដីស្រែប្រាំងនិងស្រែវស្សាក្នុងសង្កាត់ស្រយ៉ូវ នាពេលអនាគត ស្ថិតនៅសងខាងត្បូងផ្លូវជាតិលេខ៦ និងមានផ្ទៃដីសរុបចំនួន ២ ៤៦១,៧៦ ហិកតា ដែលក្នុងបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ជាដីស្រែប្រាំងនិងស្រែវស្សា ដោយពុំមានការពង្រីកបន្ថែម សម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ។

ដីស្រែប្រាំងនិងស្រែវស្សាទាំងនេះ ជាតំបន់ទំនាបលិចទឹកតាមរដូវ មានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ និងប្រផេះ និងពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អូរក្អែកពល (អូរត្រពាំងវែង) បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត បឹងធំ អាងឯកជន(បាត់ពន្លាក) បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្ដាល បឹងត្រពាំងជង្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន បឹងឈូកប្រជីត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្ដាប់ចង្អេរ បឹងតាលហាល បឹងស្នួងបែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះ លោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្ដា បឹងផ្គរលាន់ បឹងឃោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យប្រា បឹងបែកចាន បឹងស្នោ និងបឹងតាឡុក ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម ។ នាពេលអនាគត ទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះ មានស្ថានភាពជាដីទាបលិចទឹកនៅតាមរដូវសមស្របសម្រាប់ដំណាំស្រូវផ្ដល់ផលិតផលផ្គត់ផ្គង់ការហូបចុក និងលក់ទៅកាន់ទីផ្សារក្នុង និងក្រៅស្រុក ដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។ ដីស្រែប្រាំងនិងស្រែវស្សា នាពេលអនាគត មានទីតាំងស្ថិតនៅតាម ០២ តំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីស្រែប្រាំង និងស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៥៦៥,០៧ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦។ ដីស្រែប្រាំងនិងស្រែវស្សានៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជនត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ១ ៥១៧,២៣ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែប្រាំង និងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៣៧៩,៤៦ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ បន្តជាប់ពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែប្រាំងនិងស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមអាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ។

### ង.ដីចម្ការស្រោចស្រព

ដីចម្ការស្រោចស្រពក្នុងសង្កាត់ស្រយ៉ូវ នាពេលអនាគត ស្ថិតនៅតាមដងស្ទឹងសែនចុងភាគខាងជើងនៃសង្កាត់មានផ្ទៃដីសរុបចំនួន ១៦,៦៤ ហិកតា ដែលជាដីសាធរណៈរបស់រដ្ឋ ត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋអាស្រ័យផលនៅលើដីចំណីស្ទឹង។ បច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ជាដីចម្ការស្រោចស្រព ដោយពុំមានការពង្រីកបន្ថែម សម្រាប់ដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ នោះឡើយ ។ ដីចម្ការទាំងនេះជាតំបន់ទំនាបមានប្រភេទដីល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ ប្រផេះ និងពឹងផ្អែកលើប្រភពទឹកស្រោចស្រពពីស្ទឹងសែន ហើយត្រូវបាននាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម។ នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីចម្ការស្រោចស្រពដដែល ដោយសារទីតាំងដីនេះស្ថិតនៅតាមមាត់ស្ទឹងមានដីល្បាប់ហូរចាក់ពីស្ទឹង ដែលមានជីជាតិសមស្របនឹងដំណាំបន្លែបង្កាគ្រប់មុខសម្រាប់ផ្គត់ផ្គង់ការហូបចុក និងនៅសល់លក់ទៅទីផ្សារដើម្បីបង្កើនប្រាក់ចំណូលជួយជីវភាពគ្រួសារ។

**ច.ស្ទឹងមានទឹកតាមរដូវ**

សង្កាត់ស្រយ៉ូវមានស្ទឹងចំនួន ០១ខ្សែ គឺស្ទឹងសែន(ស្ទឹងស្លាប់)ស្ថិតនៅចុងភាគខាងជើងសង្កាត់ មានទំហំផ្ទៃដីសរុប ២១៧,៥៦ ហិកតា ជាដីសាធារណៈរបស់រដ្ឋ និងជាប្រភពទឹកដ៏សំខាន់សម្រាប់ស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗទៀតរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ ព្រមទាំងជាប្រភពធនធានជលផលផងដែរ។ ស្ទឹងនេះហូរកាត់តាមព្រំប្រទល់រវាងសង្កាត់ស្រយ៉ូវ និងឃុំកកោះពីជើងទៅត្បូងចាក់ចូលទៅជុំវិញបឹងទន្លេសាប ។ នាពេលអនាគត ស្ទឹងនេះ គឺជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានជលផល ជាអាហារផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។

**ឆ.បឹង**

នៅសង្កាត់ស្រយ៉ូវ មានបឹងចំនួន ៥៤ កន្លែង ដូចជា បឹងទទឹងថ្ងៃ បឹងតំណាក់រទេះ បឹងទួលវត្ត បឹងធំ បឹងគ្រោះក្រោម បឹងឈូកច្បារ បឹងគ្រោះកណ្តាល បឹងគ្រួសក្រហា បឹងត្រពាំងជង្រុក បឹងកូនក្អែក បឹងទឹកស្រាំ បឹងលាក់ពាង បឹងជួន បឹងឈូកប្រជីត បឹងឈូក បឹងគោកសំរោង បឹងសេកស្លាប់ បឹងមូសខាំ បឹងខ្សាច់ជ័យ បឹងអញ្ចាញ បឹងផុក បឹងផ្សោត បឹងតាឡុង បឹងត្រពាំងវែង បឹងដំរីរត់ បឹងថ្លុកពោ បឹងថ្វា បឹងសាលា បឹងត្រស់វែង បឹងត្រស់ធំ បឹងកណ្តាប់ចង្អេរ បឹងតាលហាល បឹងស្នងបែន បឹងរំពេរ បឹងកូនខ្លា បឹងតាសៀង បឹងគោកត្នោត បឹងទំនប់សាប បឹងស្រះលោក បឹងគ្រាប់បាយ បឹងត្រស់ឯកសៀម បឹងហាន់ស្កា បឹងផ្គរលាន់ បឹងយោលទោង បឹងក្បាលខ្មោច បឹងត្រសែង បឹងជីមឿងសុខ បឹងបាក់សម បឹងសាក់ជ័យ បឹងប្រា បឹងបែកចាន បឹងស្មោ និងបឹងតាឡុក ដែលមានទំហំផ្ទៃដីសរុបចំនួន ៣៣៤,៥០ ហិកតា ។ បឹងធម្មជាតិទាំងអស់នេះ ជាដីសាធារណៈរបស់រដ្ឋដែលពេលអនាគតត្រូវការពារ និងថែរក្សាទុកប្រើប្រាស់ សម្រាប់ជាប្រភពទឹកនៅក្នុងការស្រោចស្រពដំណាំកសិកម្ម និងប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល និងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ ។

**ជ.អាងស្តុកទឹក**

អាងស្តុកទឹកក្នុងសង្កាត់ស្រយ៉ូវ នៅពេលអនាគត ២១ កន្លែង ស្ថិតនៅភាគខាងត្បូងនៃសង្កាត់ ដែលមានផ្ទៃដីសរុបចំនួន ២៩៤៨,៣១ ហិកតា ដែលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាអាងស្តុកទឹក ដោយពុំមានការពង្រីកបន្ថែមសម្រាប់ដោះស្រាយទឹកស្រោចស្រពរហូតដល់ឆ្នាំ២០៣២នោះឡើយ។ ពេលអនាគតអាងស្តុកទឹកទាំងនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល និងព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ដែលជាប្រយោជន៍យ៉ាងសំខាន់នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់។ អាងស្តុកទឹកនៅពេលអនាគតមានទីតាំងស្ថិតនៅ ០២ តំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ២ ១៨៥,៦៣ ហិកតា ស្ថិតនៅខាងត្បូងនៃសង្កាត់លាយឡំជាមួយដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប។ អាងស្តុកទឹកនេះជាដីសាធារណៈរបស់រដ្ឋដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរឡើយ។

**-អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីចំនួន ៧៦២,៦៨ ហិកតា ស្ថិតនៅភាគខាងត្បូងសង្កាត់បន្តជាប់ពីអាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប។ អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការរំលោភកាន់កាប់ដីនៅក្នុង

តំបន់នេះ។ នាពេលអនាគត ក្នុងករណីអាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យផ្ទៀលចេញពីតំបន់ការពារព្រៃលិចទឹកតាមការស្នើសុំរបស់អាជ្ញាធរដែនដីពាក់ព័ន្ធ ដោយផ្អែកលើឯកសារលិខិតបទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាលទេនោះ អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ នឹងនៅតែកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកជុំវិញបឹងទន្លេសាប ដែលត្រូវការពារដដែល ។ តែទោះបីជាមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យផ្ទៀលដីទាំងនេះ ជូនសម្រាប់ប្រើប្រាស់ជាដីស្រែក៏ដោយ ក៏អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ មិនមែនជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរគឺពួកគាត់គ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។

ឈ.ស្រះ

ស្រះក្នុងសង្កាត់ស្រយ៉ូវ នាពេលអនាគតមានចំនួន ៤៧ កន្លែង ស្ថិតនៅរាយប៉ាយស្ទើរទូទាំងសង្កាត់ ដែលមានទំហំផ្ទៃដីសរុបចំនួន ១៦៩,៨៣ ហិកតា ហើយពេលបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់ជាស្រះទឹក ដោយពុំមានការពង្រីកបន្ថែម សម្រាប់ដោះស្រាយទឹកស្រោចស្រពរហូតទៅដល់ឆ្នាំ ២០៣២ នោះឡើយ ។ នាពេលអនាគតស្រះនេះនឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ដែលជាប្រយោជន៍យ៉ាងសំខាន់ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់។ ស្រះ នាពេលអនាគតមានទីតាំង ស្ថិតនៅតាម ០៤តំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប**

ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ១,០១ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦។ ស្រះក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានទំហំផ្ទៃដីចំនួន ៥,៤៩ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦។ ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ដែលត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៩៨,៦៧ហិកតា ស្ថិតនៅខាងត្បូងនៃសង្កាត់លាយឡំជាមួយដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប។ ស្រះក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងបានឡើយ។

**-ស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានទំហំផ្ទៃដីចំនួន ៦៤,៦៦ ហិកតា ស្ថិតនៅភាគខាងត្បូងសង្កាត់បន្តជាប់ពីស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាប។ ស្រះទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋស្ថិតនៅក្នុងតំបន់ដែនកាពារព្រៃលិចទឹក ហាមការកាប់រានដី ការរំលោភកាន់កាប់ព្រៃនៅក្នុងតំបន់នេះ។ នាពេលអនាគត ក្នុងករណីស្រះទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យផ្ទៀលចេញពីតំបន់ការពារព្រៃលិចទឹក តាមកាស្នើសុំរបស់អាជ្ញាធរដែនដីពាក់ព័ន្ធ ដោយផ្អែកលើឯកសារលិខិតបទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាលទេនោះ គឺស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាបទាំងនេះ នឹងនៅតែកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកជុំវិញបឹងទន្លេសាប ដែលត្រូវការពារដដែល ។ តែទោះបីមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យផ្ទៀលដីទាំងនេះជូនសម្រាប់ប្រើប្រាស់ជាស្រះក៏ដោយក៏ស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ

មិនមែនជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរ គឺពួកគាត់គ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។

## ៣.៣.ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិត បច្ចុប្បន្ននេះយើងបានរកឃើញថា នៅក្នុងសង្កាត់ស្រយ៉ូវ មានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅឋានចំនួន ៥គ្រួសារ និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដចំនួន ១០៣២គ្រួសារ ដូចបានអធិប្បាយនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ដែលប្រជាពលរដ្ឋមួយចំនួនកំពុងរស់នៅលើចិញ្ចើមផ្លូវ លើដីចំណីប្រឡាយ និងដីចំណីស្ទឹង និងមួយចំនួនទៀតរស់នៅក្នុងខ្ទមលើដីរបស់អ្នកដទៃ ដែលពួកគាត់កំពុងស៊ីឈ្នួលឱ្យគេដើម្បីចិញ្ចឹមជីវិត ។ ដូច្នេះ ដើម្បីដោះស្រាយដីសម្រាប់សាងសង់លំនៅឋាន និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ដែលអាចផ្តល់ឱកាសឱ្យពួកគាត់មានជម្រករស់នៅសមរម្យ និងបង្កើតឱកាសការងារ ដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ក្រោមជាតិ ដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ ។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូកទី២ ត្រង់ចំណុច២.១.៣ ខាងលើគឺ ដីសម្រាប់លំនៅឋានមានទំហំ ១,២៥ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារមានទំហំ ២០៦៤ហិកតា។

## ៣.៤.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ហើយការធានាទាំងអស់នេះ ត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូតដោយពុំមានឈប់ឈរ។ និរន្តរភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធិភាព និងធានាឱ្យមាននិរន្តរភាព។

### ៣.៤.១.កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបទៅដោយចីរភាព ដោយធានាបានការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះ និងបន្តទៅដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀត ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់ដីទាំងអស់នៅក្នុងសង្កាត់ ដែលបានកំណត់រួចរាល់តាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

#### ក.ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលនៃធនធានដែលមាននៅក្នុងសង្កាត់ស្រយ៉ូវ ដែលក្រុមការងាបានធ្វើការសិក្សាស្រាវជ្រាវរកឃើញ ហើយបានកំណត់ច្បាស់ថាសង្កាត់នេះ មានគោលដៅអភិវឌ្ឍទៅថ្ងៃអនាគត ពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលក្នុងនោះបានផ្តោតសំខាន់ទៅលើដំណាំស្រូវ។ ដូចនេះ សង្កាត់ស្រយ៉ូវ នឹងមានតួនាទីសំខាន់មួយក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលត្រូវចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅក្នុងសង្កាត់ឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល ដែលអាចមានលទ្ធភាពនាំស្រូវចេញបានច្រើន ដែលសល់ពីការហូបចុក ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជពលរដ្ឋ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍសង្កាត់ដូចខាងលើ ត្រូវតែមានការគ្រប់គ្រងដីស្រែនៅក្នុងសង្កាត់ឱ្យបានច្បាស់លាស់ ដោយរាល់ការសម្រេចចិត្តប្ដូរមុខងារប្រើប្រាស់ដី ពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀតត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបដោយតម្លាភាពនិងអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងត្រូវមានការផ្សព្វផ្សាយជាចំហ។ ម៉្យាងទៀតដីស្រែប្រាំងនៅក្នុងសង្កាត់ស្រយ៉ូវបច្ចុប្បន្ន បានរកឃើញថាមានផ្ទៃដីទំហំ ៥៥៥៩,០៦ ហិកតា ស្ថិតនៅក្នុងតំបន់៣ ដែលជាដែនការពារព្រៃលិចទឹក ប្រសិនបើមិនមានការអនុញ្ញាតពីរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋបន្តកាន់កាប់អាស្រ័យផលនៅពេលអនាគតតាមរយៈការស្នើសុំពីអាជ្ញធរដែនដីទេនោះ នឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកវិញ នឹងនាំឱ្យទំហំផ្ទៃដីស្រែប្រាំងមានការថយចុះ ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ក៏ត្រូវគិតគូរពីទឹកស្រោចស្រពដំណាំស្រូវ ដោយធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងក្នុងមួយឆ្នាំ តាមរយៈការស្ដាប្រព័ន្ធប្រឡាយចាស់ៗ ដែលមានស្រាប់អាចនាំទឹកទៅស្រោចស្រពដីស្រែបានគ្រប់គ្រាន់ដើម្បីអាចផ្ដល់ទឹកមកតាមប្រព័ន្ធប្រឡាយទាំងនោះផងដែរ។ បន្ទាប់ពីកត្តាដី និងទឹកនៅមានកត្តាបច្ចេកទេសដាំដុះថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែបែបប្រពលវប្បកម្មទំនើបដូចមានលើកឡើងតាមការវិភាគក្នុងជំពូកទី២ ត្រង់ចំណុចការផ្ដល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងាកសិកម្មបានច្រើនផងដែរ ពីព្រោះយុវជនតែងគិតថាការធ្វើស្រែនាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូកដីភក់ មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតការធ្វើស្រែតាមបែបប្រពលវប្បកម្មទំនើប កសិករក៏អាចពាក់ក្រវាត់កប្រើប្រាស់កុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា។ នៅក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅសង្កាត់ស្រយ៉ូវ មិនមែនយកចិត្តទុកដាក់តែនៅលើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍ កសិករដើម្បីជ្រើសរើសតំណាងអាចទៅចូលរួមតស៊ូមតិក្នុងការចចាររកទីផ្សារក៏ដូចជាមួយឈ្មួញ ដោយធានាការធ្វើស្រែបានផលស្រូវមានគុណភាពតាមស្តង់ដារតម្រូវទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ។

តាមការគណនា ដែលផ្អែកទៅលើការការគិតគូរនៅក្នុងជំពូក២ ត្រង់ចំណុច ១២.៣. អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ឆ្នាំខាងមុខដូចខាងក្រោម ប្រសិនបើមិនមានការប្រែប្រួលថយចុះដីស្រែប្រាំងនៅក្នុងតំបន់៣ទេនោះ។

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ ២៤ ៤៧១ នាក់

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែវស្សាមាន ៧២៩៤,២៧ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែប្រាំង និងដីស្រែប្រាំង និងស្រែវស្សាមាន ១៦៧២៨,៣៧ ហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវវស្សាជាមធ្យមចំនួន ៤ តោន/ហ.ត និងស្រូវប្រាំង និងដីស្រែប្រាំង និងស្រែវស្សាមានចំនួន ៥ តោន/ហ.ត

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែវស្សាបាន ១ដង/ឆ្នាំ ដីស្រូវប្រាំង និងដីស្រែប្រាំង និងស្រែវស្សាបាន ២ដង/ឆ្នាំ

**-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំ(២០១៧-២០៣២)ផលិតផលស្រូវទទួលបានក្នុងមួយឆ្នាំជាមធ្យមៈ**

-ស្រូវវស្សាស្មើនឹង ៧២៩៤,២៧ ហិកតា x ៤តោន/ហិកតា x ១ដង = ២៩១៧៧,០៨តោន/ឆ្នាំ

-ដីស្រូវប្រាំង និងដីស្រែប្រាំង និងស្រែវស្សាស្មើនឹង ១៦៧២៨,៣៧ ហិកតា x ៥ តោន/ហិកតា x ២ដង = ១៦៧ ២៨៣,៧០ តោន/ឆ្នាំ

**-ទិន្នផលស្រូវសរុបស្មើនឹង ២៩១៧៧,០៨តោន + ១៦៧ ២៨៣,៧០តោន = ១៩៦៤៦០,៧៨ តោន/ឆ្នាំ**

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣ គីឡូក្រាម ដែលបើគិតជាស្រូវ ត្រូវការចំនួន ២២៤ គីឡូក្រាម (ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ)

**-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យម**

២៤ ៤៧១ នាក់ x ២២៤ គីឡូក្រាម = ៥៤៨១,៥០ គីឡូក្រាម/ឆ្នាំ ស្មើនឹង ៥៤៨១,៥០ តោន/ឆ្នាំ

**-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យម ៖**

-ស្រូវវស្សាស្មើនឹង ៧២៩៤,២៧ ហិកតា x ៣០០ គីឡូក្រាម = ២១៨៨,២៨ តោន/ឆ្នាំ

-ដីស្រូវប្រាំង និងដីស្រែប្រាំង និងស្រែវស្សាស្មើនឹង ១៦៧២៨,៣៧ ហិកតា x ៣០០ គីឡូក្រាម = ៥០១៨,៥១ តោន/ឆ្នាំ

-ពូជស្រូវសរុបស្មើរនឹង ២១៨៨,២៨ តោន + ៥០១៨,៥១ តោន = ៧២០៦,៧៩ តោន/ឆ្នាំ

**-ដូច្នេះក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យម**

១៩៦៤៦០,៧៨តោន/ឆ្នាំ - ៥៤៨១,៥០តោន/ឆ្នាំ - ៥០១៨,៥១តោន/ឆ្នាំ = ១៨៥៩៦០,៧៧ តោន/ឆ្នាំ

**-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យម:**

**១៨៥ ៩៦០,៧៧ តោន/ឆ្នាំ x ៦០ % = ១១១ ៥៧៦,៤៦ តោន/ឆ្នាំ**

### ខ.ការគ្រប់គ្រងព្រៃឈើ ជលផល និង ធនធានសំខាន់ៗផ្សេងៗទៀត

ដោយឡែកធនធានព្រៃឈើវិញ យើងបានរកឃើញថា នៅក្នុងសង្កាត់ស្រយ៉ូវមិនមានដីព្រៃឈើនោះទេ ហើយក៏មិនមានដីសម្រាប់ដាំដើមឈើដែរ ប៉ុន្តែអាចធ្វើការដាំដើមឈើនៅតាមដងផ្លូវ នៅតាមប្រឡាយទឹក ទីធ្លាសាលាសង្កាត់ ទីធ្លាសាលារៀន ទីធ្លាមណ្ឌលសុខភាព ទីធ្លាវត្តអារាម ទីទួលសាធារណៈ និងនៅតាមលំនៅឋានជាដើម ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងសង្កាត់ ដើម្បីបម្រើផលប្រយោជន៍ ដូចអ្វីដែលបានលើកឡើងនៅក្នុងជំពូកទី២ នៃរបាយការណ៍នេះ ហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្ស និងលូតលាស់បានល្អ។

ចំណែកមច្ឆាជាតិ ដែលជាធនធានជលផលនៅក្នុងសង្កាត់ដែរនោះបច្ចុប្បន្ន មានតែតាមបែបធម្មជាតិនៅតាមបឹង ស្ទឹង អាងស្តុកទឹក ស្រះ ប្រឡាយទឹក និងស្រែ ដែលអាចឱ្យប្រជាពលរដ្ឋក្នុងសង្កាត់អាចទទួលផលជាលក្ខណៈគ្រួសារបានតិចតួចតែប៉ុណ្ណោះ។ តែទៅថ្ងៃអនាគត ក៏ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីថែមទៀត ដើម្បីបានផលគ្រប់គ្រាន់ផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់ សម្រាប់ប្រជាពលរដ្ឋក្នុងសង្កាត់ស្រយ៉ូវ។ ហើយចំពោះស្ថានភាពសមស្របនៅក្នុងសង្កាត់គួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម (តាមវាលស្រែ)ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែ ដែលបំផ្លាញផលដំណាំ ដូចដែលបានលើកឡើងជាអនុសាសន៍ក្នុងជំពូកទី២នៃរបាយការណ៍នេះផងដែរ។ ចំណែកធនធានសំខាន់ៗផ្សេងទៀតលើសពីការរៀបរាប់ខាងលើនេះ ពុំមានឃើញគួរកត់សម្គាល់ឡើយ។

### ៣.៤.២.គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយគ្រប់គ្រាន់ធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្ម និងធនធានសំខាន់ៗ សម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍ និងអភិរក្សដីធ្លីនិងធនធានធម្មជាតិក្នុងសង្កាត់ ចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោម៖

- សាងសង់ផ្លូវចាក់កៅស៊ូ
- ជួសជុលផ្លូវក្រាលគ្រួសក្រហម
- ជួសជុលសាងសង់ស្ពាន
- ជួសជុលសាងសង់ផ្លូវលំដីស
- ស្តារប្រឡាយស្រោចស្រព
- ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក
- ផ្តល់ម៉ាស៊ីនបូមទឹក
- ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
- បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
- បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
- តបណ្តាញទឹកស្អាតឱ្យដល់គ្រប់ភូមិ
- តបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- បង្កើតសហគមន៍កសិករ ដើម្បីជំរុញការអនុវត្តន៍ភូមិ១ ផលិតផល១
- ដោះស្រាយដីសម្បទានសង្គមកិច្ច
- ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់រូប
- ផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ
- ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ និងកុមារ
- ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
- ផ្សព្វផ្សាយពីច្បាប់ភូមិបាល ច្បាប់ជលផលជូនដល់ប្រជាពលរដ្ឋ

## ៣.៥.សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវក្នុងឆ្នាំ២០១៧នេះ បានឱ្យដឹងថាសង្កាត់ស្រយ៉ូវ ជាសង្កាត់មួយនៅក្នុងចំណោមសង្កាត់ទាំង០៨របស់ក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានភូមិចំនួន១៣ និងមានផ្ទៃដីសរុបចំនួន ២៨ ២៦២,៨៨ ហិកតា។ ក្នុងឆ្នាំ២០១៧ សង្កាត់ស្រយ៉ូវ មានប្រជាពលរដ្ឋរស់នៅចំនួន ៤ ៥១០ គ្រួសារ ប្រជាជនសរុបចំនួន ២០ ២២៣ នាក់ នៅក្នុងនោះមានស្ត្រីចំនួន ១០ ៩៣៧ នាក់ ហើយមានដង់ស៊ីតេប្រជាជនជាមធ្យម ៧២,៩នាក់/គ.ម២។ សង្កាត់ស្រយ៉ូវ មានសណ្ឋានភាពដីជាវាលទំនាបលិចទឹកនៅរដូវវស្សា ហើយជាប្រភេទដីកណ្តេងពណ៌ខ្មៅ ល្បាយខ្សាច់លាយឥដ្ឋពណ៌ស ខ្មៅ ប្រផេះ ដីកណ្តេងពណ៌ក្រម៉ៅល្បាប់ និងដីពពាយកណ្តុរពណ៌ខ្មៅ ត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង និងស្រែវស្សា ដែលបានផ្តល់មុខរបរសំខាន់ដល់ប្រជាពលរដ្ឋភាគច្រើនរហូតដល់ប្រមាណ ៧៣,៩ភាគរយ និងសេវាកម្ម ២៦,១ភាគរយ។ ទន្ទឹមនេះ សង្កាត់ស្រយ៉ូវមានប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពរស់នៅពីស្ទឹងសែន និងបឹងធម្មជាតិមួយចំនួនដែលអាចនាំទឹកមកប្រើប្រាស់តាមរយៈប្រឡាយមេ ២ខ្សែ ប្រឡាយរង ៣ខ្សែ និងប្រឡាយតូច១៨ខ្សែ។ បន្ថែមពីលើនេះ សង្កាត់ស្រយ៉ូវស្ថិតនៅជិតទីរួមខេត្តកំពង់ធំ និងមានផ្លូវជាតិលេខ៦ឆ្លងកាត់ ដែលជាការផ្តល់ឱកាសឱ្យសង្កាត់អាចទាញយកប្រយោជន៍ពីការអភិវឌ្ឍពីតំបន់ និងតាមផ្លូវនេះបាន ហើយសង្កាត់នៅមានផ្លូវផ្សេងទៀតគ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទនងពីភូមិមួយទៅភូមិមួយក្នុងសង្កាត់ និងអាចភ្ជាប់ទំនាក់ទំនងទៅសង្កាត់ និង

ស្រុកផ្សេងៗបានដោយងាយស្រួល។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា ក្នុងរយៈពេល១៥ឆ្នាំ ទៅមុខ រហូតដល់ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ២៤ ៤៦៩ នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូរ រកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន។ ទន្ទឹមនេះ ក៏បានរក ឃើញអំពីបញ្ហាប្រឈមមួយចំនួនទៅលើសកម្មភាពនៃការអភិវឌ្ឍសង្កាត់ស្រយ៉ូវបច្ចុប្បន្នផងដែរ ដូចជាការធ្វើស្រែ ដែលមានសក្តានុពលក្នុងការអភិវឌ្ឍសង្កាត់ មិនទាន់ទទួលបានផលស្រូវសមស្របអស់លទ្ធភាពនៅឡើយ ដោយ ដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងពី បច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយ ដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារការចំណាកស្រុកច្រើន គឺបាត់កម្លាំងពលកម្មជិតពាក់កណ្តាល នៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថេរភាពដោយឈ្មួញជាអ្នកកំណត់តម្លៃ។ល។ ទន្ទឹមនឹងការ រកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍសង្កាត់ ក៏បានរកឃើញថា ជាទូទៅការប្រើប្រាស់ដីនៅក្នុងសង្កាត់ ពេលបច្ចុប្បន្នបានចំទិសដៅនិងមានភាពសមស្រប ដូចជា ការប្រើប្រាស់ដីសម្រាប់លំនៅឋាន កសិកម្ម ប្រព័ន្ធផ្លូវ គមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគត ក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល។ បន្ថែមពីលើនេះក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរ សម្រាប់អនាគតដូចជាត្រូវសាងសង់បន្ទប់ រៀនបន្ថែមពង្រឹងការផ្តល់សេវាសុខាភិបាលឱ្យបានប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាតនិងប្រើប្រាស់ បង្គន់អនាម័យ ជួសជុលផ្លូវ ស្តាប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈ ជំរុញការចិញ្ចឹមត្រីតាមស្រែ។ ជាពិសេសការដោះស្រាយដី សម្រាប់លំនៅឋានក្នុងភូមិដែលមានស្រាប់ ដែលបច្ចុប្បន្ននៅទូលាយអាចផ្គត់ផ្គង់ ការសាងសង់លំនៅឋានបាន។ ដើម្បីដោះស្រាយនឹងកំណើនប្រជាជន នឹងជំរុញធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្តានុពល សម្រាប់ផ្គត់ផ្គង់ការហូបចុក និងអាចមានលទ្ធភាពនាំស្រូវ ចេញបានចំនួន ១៨៥ ៩៦០,៧៧ តោន/ឆ្នាំ ដើម្បីជួយផ្គត់ផ្គង់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុង សង្កាត់ឱ្យបានកាន់តែប្រសើរឡើង ស្របទៅនឹងកំណើនប្រជាពលរដ្ឋ ព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចក្នុង សង្កាត់។ ការរកឃើញភាពសមស្រប និងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងសង្កាត់នាពេលអនាគត បានមកពី ការវាយតម្លៃដ៏ត្រឹមត្រូវមួយ ដោយផ្អែកទៅលើធនធានដី រយៈកម្ពស់ដី ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និង សក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងសង្កាត់នេះ ដើម្បីធានាថាការប្រើប្រាស់ដីនៅក្នុងសង្កាត់ទៅអនាគត ប្រកប ដោយចីរភាព និងសមធម៌។

ដូច្នេះដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងសង្កាត់ សមស្របទៅតាមស្ថានភាពដី ជាក់ស្តែង និងសក្តានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបទៅដោយចីរភាព និង សមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នាពេលអនាគត ដូចបានរកឃើញមានចែងលម្អិត នៅក្នុងរបាយការណ៍បច្ចេកទេសនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធ ជាពិសេសនោះក្រុមប្រឹក្សាសង្កាត់ ដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងសង្កាត់ស្រយ៉ូវ ហើយមាន បេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងសង្កាត់ ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ ដែល បានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយធ្វើការបញ្ជ្រាបទៅនិងផែនការអភិវឌ្ឍសង្កាត់ឱ្យបានប្រកបដោយ ប្រសិទ្ធិភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ។

លេខៈ ៦៥១/២០

បានពិនិត្យ និង សូមគោរពជូន

**លោកអភិបាលនៃគណៈអភិបាលក្រុង និងជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និងនគរូបនីយកម្ម មេត្តាពិនិត្យ និងសម្រេច។**

ថ្ងៃ ច័ន្ទ ៣កើត ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

ស្រយ៉ូវ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០

**ចៅសង្កាត់ស្រយ៉ូវ**

**សោម នី**

លេខៈ ១៥៥៥/២០

បានពិនិត្យ និង សូមគោរពជូន

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។**

ថ្ងៃ ព្រហស្បតិ៍ ៥រោច ខែ កត្តិក ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

ស្ទឹងសែន ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលក្រុង និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងស្ទឹងសែន**

**ម៉ាក់ ប៊ុនហុង**

លេខ: ៥៤៨៥/២០២១

**បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**

ថ្ងៃ ព្រហស្បតិ៍ ... ខែ ... ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ចំ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ចំ**

សុខ_លុ

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ សង្កាត់ស្រយ៉ូវ



# ផែនទីប្រព័ន្ធធារាសាស្ត្រ សង្កាត់ស្រយ៉ូវ



# ផែនទីប្រើប្រាស់ដីសាមញ្ញ សង្កាត់ស្រយ៉ូវ



# ផែនទីគម្រោងវិនិយោគ សង្កាត់ស្រយ៉ូវ



# ឯកសារឧបសម្ព័ន្ធ




សកម្មភាពក្រុមការងាចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់សង្កាត់
ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន




សកម្មភាពប្រមូលទិន្នន័យនៅតាមមន្ទីររជុំវិញខេត្តរបស់ក្រុមការងាក្រុមហ៊ុន SBK




កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នសង្កាត់ស្រយ៉ូវ




សកម្មភាពក្រុមការងាចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់សង្កាត់ស្រយ៉ូវ




សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)




កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ស្រយ៉ូវ
ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ




កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងស្ទឹងសែន
ដើម្បីពិនិត្យ និងឯកភាពទៅលើសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ






សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅសង្កាត់ស្រយ៉ូវ

 

កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ
ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្ដីព្រាងផែនការប្រើប្រាស់ដីនៅក្នុងសង្កាត់ស្រយ៉ូវ

# ឯកសារយោង

# ឯកសារយោង

១. ឯកសារព័ត៌មានស្ថានភាពសង្កាត់ស្រយ៉ូវស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៣ របស់មន្ទីរផែនការខេត្ត
២. ឯកសារព័ត៌មានស្ថានភាពសង្កាត់ស្រយ៉ូវស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៤ របស់មន្ទីរផែនការខេត្ត
៣. ឯកសារព័ត៌មានស្ថានភាពសង្កាត់ស្រយ៉ូវស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៥ របស់មន្ទីរផែនការខេត្ត
៤. ឯកសារព័ត៌មានស្ថានភាពសង្កាត់ស្រយ៉ូវស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៦ របស់មន្ទីរផែនការខេត្ត
៥. ឯកសារព័ត៌មានស្ថានភាពសង្កាត់ស្រយ៉ូវស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ២០១៧ របស់មន្ទីរផែនការខេត្ត
៦. ផែនការអភិវឌ្ឍសង្កាត់រយៈពេលប្រាំឆ្នាំ(២០១៨-២០២២)របស់សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
៧. កម្មវិធីវិនិយោគសង្កាត់ស្រយ៉ូវ ឆ្នាំ២០១៧ របស់សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
៨.របាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឆ្នាំ២០១៧
៩. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប